ចិន្ត នាគ

សាស្ត្រាចារ្យសិល្បៈ

# ល្ខោនពោលស្រី

រក្សាសិទ្ធ

២០០៣_២០០៤

AMRITA
PERFORMING ARTS
អម្រឹតាសិល្បៈ

Technical and financial assistance provided by
Amrita Performing Arts
through support from the
Rockefeller Foundation.

First Printing 1,000 copies
May 2007 ISBN: 99950-850-0-3
Printing in Cambodia by Japan Printing House

# បច្ចេកទេស

## សិល្បៈ



## សំដែង

## ល្ខោន

# ពោលស្រី

03/2003 លោក ចិន្ត នាត

សាស្ត្រាចារ្យសិល្បៈល្ខោន ម.នាដសិល្បៈសាស្ត្រ (ស.ភ.វ.ស)









## ពាក្យឧទ្ទិស

សូមឧទ្ទិសវណ្ណកម្មបច្ចេកទេសសិល្បៈ (សំដែងល្ខោនពោលស្រី) ដែលប្រសូតមកពីការសំភី ស្វាធ្យាយ ព្យាយាម យកអស់ពីកម្លាំងកាយចិត្តកម្លាំងប្រាជ្ញាស្មារតី ចំណេះវិជ្ជាទាំងឡាយបានមកពី ការខិតខំបង្រៀនបណ្តុះបណ្តាលថែបំប៉នបំពាក់នូវជំហរមនសិការស្នេហាជាតិមាតុភូមិរបស់អស់លោកអ្នកជាឧបការីជន ។

សូមឧទ្ទិសអត្ថមនុញ្ញផល កើតមកពីសទ្ធានៃកុសលចិត្តក្នុងការប្រឹងប្រែងសរសេរសៀវភៅសម្រេចបានពេលនេះ ជូនចំពោះវិញ្ញាណខ័ន្ធលោកតា **ទ្រី ខ៉ាន** លោកឪពុក **ចិន្ត ឡូន** លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលមាននាមដូចខាងក្រោមនេះ :

លោកសាស្ត្រាចារ្យ **ហង្ស ធន់ហាក់** លោក **ពៅ យូឡេង** លោក **មាស គក** លោក **ឡូន កន** លោក **ហួត គឹមឈាង** លោក **ហង្ស ជួន** លោក **សុខ សោវណ្ណគុណា** លោក **លី គឹមអ៊ីង** លោក **ប៉ុល សំអឿន** លោកស្រី **អ៊ូ ចាន់ថន** លោក **ប៉ែន ណារុធ** និងជូនសេរីមង្គលបវរសួស្តីចំពោះលោក **វណ្ណា មូលីវណ្ណា** លោក **ឆេង ផុន** លោក **យិល ចន្ទ** លោកស្រី **អ៊ុយ រាំងស៊ីន** លោកយាយ **ខ៉ាន សុខហ៊ី** ជាម្តាយលោក **ជីញ លី** ជាឪពុកសូមឱ្យមានអាយុ វណ្ណៈ សុខៈ ពលៈ បរិបូរណ៍ដោយ ទ្រព្យសម្បត្តិសម្បូរណ៍សប្បាយរុងរឿង ។

ជាពិសេសសូមកុសលផលបុណ្យបានដល់កូនស្រីឈ្មោះ **ចិន្ត ច័ន្ទធីតា** ទទួលមរណភាពក្នុងជន្មាយុ ២១ឆ្នាំ (គិតមកដល់ឆ្នាំ ១៩៩២) កូនប្រុសឈ្មោះ **ចិន្ត ច័ន្ទរដ្ឋា** ទទួលមរណភាពក្នុងជន្មាយុ ៣២ឆ្នាំ គិតមកដល់ឆ្នាំ ២០០៣នេះ ដែលកូនបានជួយជ្រោមជ្រែងឪពុក (**ចិន្ត នាគ**) ក្នុងករណីធ្វើការស្រាវជ្រាវល្ខោនពោលស្រីដ៏កម្រនេះ ។ សូមអោយវិញ្ញាណខ័ន្ធកូនប្រុស កូនស្រី ទៅកើតក្នុងសុគតិភពប្រកបដោយភាពសម្បូរណ៍សប្បាយព្រមដោយសម្បត្តិ ៣ប្រការ គឺ **សម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន** កុំបីឃ្លៀងឃ្លាតឡើយ ។

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ចិន្ត នាគ** សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ អង្គការអម្រឹតាសិល្បៈដែល មានលោក **ហ្វ្រេដ ហ្វ្រីមបើក** ជានាយក បានជួយខំជ្រោមជ្រែងអស់ពីកម្លាំងកាយចិត្ត តាំងពីដំណើរការសំដែងល្ខោនពោលស្រីនៅសាលចតុមុខរហូតដល់ជួយរកអ្នកជួយឧបត្ថម្ភ ការរៀបចំបោះពុម្ពផ្សាយសៀវភៅល្ខោនពោលស្រីនេះឱ្យចេញជារូបរាងពេញលក្ខណៈ គឺអង្គការ **លីនក៏ (Linc)** មានលោក **សែមមីលំរ** ជាប្រធាន ដែលធ្វើឱ្យខ្ញុំមិនអាចបំភ្លេចទឹកចិត្តដ៏សប្បុរសរបស់លោកទាំងពីរឡើយ ព្រមទាំងបុគ្គលិក របស់អម្រឹតាសិល្បៈមានលោកក្នុយ **កខ ឫទ្ធីសាល** និងក្នុយ **ស្នួន ច៊ុនរិទ្ធ** សូមអស់ លោកទាំងអស់ ជួបតែសំណាងល្អ ជោគជ័យ ក្នុងជីវិត និងភាពញញឹមប្រីមប្រិយ ។

ហត្ថលេខា

អ្នកនិពន្ធ

## ពាក្យអរគុណ

ខ្ញុំបាទ **ចិន្ត នាគ** ម្ចាស់កម្មសិទ្ធវណ្ណកម្ម "ល្ខោនពោលស្រី" សូមថ្លែងអំណរគុណជាពន្លឹកចំពោះក្មួយៗ និស្សិត ដែលបានឆ្លៀតចំណាយពេលវេលា ដ៏មានតម្លៃ ក្នុងការវាយកុំព្យូទ័រអត្ថបទល្ខោនពោលស្រី ឱ្យមានវត្តមានក្នុងដែសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា លោកអ្នកអាន ជាទីគោរពនាពេលនេះ :

-លោក **ឱក ប៊ុនធឿន** សាស្រ្តាចារ្យបរិញ្ញា មហាវិទ្យាល័យសិល្បៈនាដសាស្រ្ត និង ជាសាស្រ្តាចារ្យភាសាអង់គ្លេស ។

-លោក **ណាំ ហេង** និស្សិតឆ្នាំទី៤ មហាវិទ្យាល័យគ្រប់គ្រង និងពាណិជ្ជសាស្រ្ត

-លោក **ស កុសល** និស្សិតឆ្នាំទី២ មហាវិទ្យាល័យសិល្បៈនាដសាស្រ្ត និង ជាបុគ្គលិកសិល្បករ នាយកដ្ឋានសិល្បៈទស្សនីយភាព ។

-លោក **ញ៉ូ ឫទ្ធី** និស្សិតឆ្នាំទី២ មហាវិទ្យាល័យសិល្បៈនាដសាស្រ្ត ។

-លោក **សុខ ម៉ាន់ថា** និស្សិតឆ្នាំទី២ មហាវិទ្យាល័យជាតិគ្រប់គ្រង និង ជាបុគ្គលិកស្ម័គ្រចិត្ត នាយកដ្ឋានសិល្បៈទស្សនីយភាព ។

សូមក្មួយៗ ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ និងសូមជូនពរក្មួយៗ សូមមានជោគជ័យក្នុងជីវិត និងភាពញញឹមស្រស់បំព្រង ។

សូមថ្លែងអំណរគុណជាពន្លឹកចំពោះលោកសាស្រ្តាចារ្យ ហ៊ុន សារិន ប្រធាននាយកដ្ឋានសៀវភៅ និង ការអាន ដែលលោកឆ្លៀតពេលវេលាដ៏មមាញឹកប្រកបដោយកុសលចិត្ត ជួយជ្រោមជ្រែងកែសម្រួលអក្ខរាវិរុទ្ធទាំងឡាយក្នុងសៀវភៅល្ខោនពោលស្រីនេះ ទៅតាមវចនានុក្រម សម្តេចសង្ឃនាយក **ជួន ណាត** សូមលោកទទួលបានជោគជ័យគ្រប់ភារៈកិច្ចដែលជាតិ និង ប្រជារាស្រ្តប្រគល់ជូន នឹងមានភាពរីករាយស្រស់បំព្រង ញញឹមប្រិមប្រិយ៍ជានិច្ច ។

សាស្រ្តាចារ្យ **ចិន្ត នាគ**

## ភូមិខ្លាត្រាំ ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល

ខ្ញុំសូមសម្តែងនូវអំណរសារទរ និងកោតសរសើរចំពោះ លោកសាស្ត្រាចារ្យ **ចិន្ត នាគ** ដែលបានខិតខំសិក្សាស្រាវជ្រាវ និងចងក្រងឯកសារ ល្ខោន ពោលស្រី ដ៏មានសារៈសំខាន់នេះ ។

ទង្វើរបស់លោក គឺជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ ខាងឯកសារវប្បធម៌សិល្បៈផង ពិសេសខាងផ្នែកសិល្បៈអរូបីយ និង រួមចំណែកពង្រឹងនូវគ្រឹះវប្បធម៌ជាតិក្នុងន័យអភិរក្ស ព្រមទាំងស្ថិតក្នុងគោលបំណង ធ្វើការអភិវឌ្ឍវិស័យវប្បធម៌របស់ជាតិ អោយបានរីកចម្រើនក្នុងពេលអនាគតផង ។

សូមអោយឯកសារល្ខោនពោលស្រីរបស់លោកសាស្ត្រាចារ្យ បានទៅជាផលប្រយោជន៍សម្រាប់ជាតិមាតុភូមិកុំបីអាក់ខានឡើយ ។

បណ្ណាល័យគ្រួសារ ភូមិខ្លាត្រាំ ថ្ងៃ ពុធ ទី០៦ កុម្ភៈ ឆ្នាំ ២០០៧

ហត្ថលេខា

**ពេជ្រ ធុំក្រវិល**

អ្នកនិពន្ធ, ដឹកនាំរឿង និងអ្នកស្រាវជ្រាវវប្បធម៌សិល្បៈខ្មែរ

**ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា**

## អារម្ភកថា

-សូមក្រាបថ្វាយបង្គំព្រះសង្ឃរាជទាំងពីរគណៈព្រះថេរានុថេរៈព្រះសង្ឃគ្រប់អង្គជាទីសក្ការៈ ។

-សូមក្រាបថ្វាយបង្គំព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរៈក្សត្រ និង ព្រះរាជអគ្គមហេសី **មុនីនាថ សីហនុ** ព្រះមហាវីរៈក្សត្រីយ៍ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

-សូមក្រាបថ្វាយបង្គំព្រះបាទព្រះមហាក្សត្រ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះចៅក្រុងកម្ពុជាធិបតី ព្រះរាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

-សូមថ្វាយបង្គំព្រះរាជវង្សានុវង្ស និងសូមគោរព សម្តេចទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាប្រិយ៍មិត្ត និស្សិតសិស្សានុសិស្ស យុវវ័យ ជំនាន់ក្រោយទាំងអស់ ជាទីស្រឡាញ់រាប់អានដោយស្មោះអស់ពីដួង ហឫទ័យ ។

សៀវភៅ **"ល្ខោនពោលស្រី"** ដែលស្ថិតក្នុងព្រះហស្តនិងដៃរបស់អស់លោកអ្នកពេលនេះ គឺជាក្បួនជាសៀវភៅបច្ចេកទេសសម្រាប់អនុវត្តក្នុងការកសាងវណ្ណកម្មទម្រង់ល្ខោនពោលស្រី ដោយទូលបង្គំជាខ្ញុំកត់ត្រាទុកនូវវិធីសាស្រ្តប្រាប់ពីរបៀបការងារទាំងអស់ ដើម្បីស្តែងឡើងបានជាផ្ទាំងទស្សនីយភាពមួយដែលមានឈ្មោះថា **"ទម្រង់ល្ខោនពោលស្រី"**។

ទូលបង្គំជាខ្ញុំ បរិយាយតាមគោលការណ៍ទាំង ១៦ ចំណុច (ទស្សនាទានលោកសាស្រ្តាចារ្យ **ចិន្ត នាគ**) ដើម្បីសាងសង់ជាជញ្ជាំងខ័ណ្ឌព្រំដែនជាជំនួយស្មារតីជួយក្រុមអ្នកកសាងល្ខោន (ផ្ទាំងទស្សនីយភាព) ទាំងអ្នកនិពន្ធរឿង ល្ខោនទាំងអ្នកដឹកនាំរឿងល្ខោន ទាំងសិល្បកររល្ខោនចាំពាក្យថា "ត្រូវស្គាល់ទម្រង់ល្ខោនខ្មែរអោយច្បាស់" ដើម្បីរក្សាកេរ្តិ៍ដំណែលដូនតាយើងអោយបានគង់វង្ស

ដែលលោកមានគំនិត ច្នៃប្រឌិតកម្រិតខ្ពស់បង្កើតបានរបៀបកសាងវណ្ណកម្មល្ខោនរហូតជាង ២០ទម្រង់ ។ សៀវភៅល្ខោនពោលស្រីរបស់ទូលព្រះបង្គំខ្ញុំបាទដែលរៀបរាប់ជូនតាមទំព័រខាងមុខទាំងឡាយពេលនេះ គឺមានគំនិតតិចតួចក្នុងការជួយទប់ស្កាត់កុំអោយច្រឡូកច្រឡំបល់ ឧទាហរណ៍: មិនដឹងកាយវិការណា? សំដែងពាក្យសំដីណា? សំដែងក្នុងទម្រង់ល្ខោនអី ចេះតែដាក់ ចេះតែធ្វើ ដោយមិនបានគិតពីពាក្យថា ទម្រង់ល្ខោនខ្មែរមានជាង ២០ទម្រង់ ដើម្បីកុំអោយអ្នកទស្សនាច្រឡំថា ខ្មែរមានល្ខោនជាង ២០ទម្រង់ឯណា បើឃើញដូចៗតែគ្នាសោះ ។

ទូលបង្គំ ខ្ញុំព្រះកុរណាខ្ញុំបាទ សូមអភ័យទោសនូវគំនិតដ៏សែនអភិរក្សក្នុងការរក្សាមរតកជូនតានេះ ហើយជានិច្ចកាលក្នុងការកសាងវណ្ណកម្ម ល្ខោន តែងតែសួរខ្លួនឯងថា "**អភិរក្សដើម្បីអភិវឌ្ឍន៍ហើយអភិវឌ្ឍន៍ក្នុង អភិរក្សឈរលើមូលដ្ឋានគ្រឹះចរិតលក្ខណៈ និងព្រលឹងមូលដ្ឋានខ្មែរ**" ខ្មែរមិនមែនយឺតហើយជឿនលឿនមិនមែនសុទ្ធតែបរទេសទាំងអស់នោះទេ (និយាយដោយឡែក ក្នុងលក្ខណៈថែរក្សាប្រពៃណីវប្បធម៌ជាតិ) ព្រោះបញ្ហា សាកលភាវូនីយកម្មលើបញ្ហាវប្បធម៌នេះជារឿងពិបាកព្រោះពូជសាសន៍ខ្មែរ ជាជាតិសាសន៍មួយមានវប្បធម៌សំបូរបែប..... ប្រាសាទបូរាណស្ថានជាង ១០០០ ទៅជាង ២០០០ ទាំងតូចទាំងធំ (ឯកឧត្តម **ជុច គឿន** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជម្រាបជូនព្រឹទ្ធសភាជាតិ ក្នុងពេលការពារច្បាប់សិទ្ធអ្នកនិពន្ធ ឬ សិទ្ធប្រហាក់ប្រហែល) បទភ្លេងបុរាណប្រពៃណីខ្មែរយើងរកឃើញមកហើយមានចំនួន ១១៧០បទ ឧបករណ៍តន្ត្រី ពី ៨០ ទៅជាង ១០០ ឧបករណ៍ (ស្រាវជ្រាវដោយអ្នកស្រី **កែវ ណារុំ**) ល្ខោនមានជាង ២០ ទម្រង់ ដោយមានវិធីសំដែងបែបខុសៗគ្នា ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមខន្តីអភ័យទោសទុកជាមុននូវរាល់ចំណុចទាំងឡាយ ដែលអធិប្បាយទៅ ឬ មួយធ្វើការសិក្សាស្រាវជ្រាវមិនទាន់បានស៊ីជម្រៅ ហើយយកមកសរសេរជាភាសាសរសេរ ឬភាសានិយាយ ខ្ញុំសូមអស់លោកអ្នកប្រាជ្ញ រាជបណ្ឌិត រៀមច្បងកវីនិពន្ធ ទាំងឡាយជួយ កែលម្អទាំងឃ្លាឃ្លោង

ទាំងអត្ថន័យ ខ្លឹមសារ ទាំងបន្ថែម ឯកសារស្រាវជ្រាវទាំង អក្ខរាវិរុទ្ធ សូមកុសលផល បុណ្យពុទ្ធពរទាំងបួនប្រការជួបសម្បត្តិសុខទាំងបី សម្បត្តិមនុស្សលោក សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន ចូរមានដល់សាធុជនដែលមានកុសលចិត្តចំពោះសៀវភៅល្បោនពោលស្រីទូលបង្គំជាខ្ញុំនេះ ។

ហត្ថលេខា

**សាស្ត្រាចារ្យ ចិន្ត នាគ**

បឹងសាឡាង ២២ /១២/ ០៣

០១២ ៨៤ ៣៦ ២៤

# បញ្ជីអត្ថបទ


១ - និយមន័យ

២ - លក្ខណៈពិសេស របស់ល្ខោនពោលស្រី

៣ - លក្ខណៈពិសេសក្នុងការបង្ហាញតួអង្គ

៤ - ប្រភពល្ខោនពោលស្រី

៥ - ប្រវត្តិល្ខោនពោលស្រី

- រណ្តាប់ល្ខោនពោលស្រី រាំ ថ្វាយព្រះ

- រណ្តាប់សំពះគ្រូ (ក្បួនសំពះគ្រូល្ខោនពោលស្រី)

៦ - ពិធីសំពះគ្រូ ឬ ពិធីថ្វាយខ្លួន

៧ - ឆាកសំដែងល្ខោនពោលស្រី

៨ - ការតុបតែងលម្អឆាក

៩ - ការបំភ្លឺភ្លើង

១០ - ពិធីហោមរោងមុនការសំដែង

១១ - វិធីសាស្ត្រ និង មធ្យោបាយសំដែង (សមាធិ)

- ឧទាហរណ៍រឿងជ័យសែន (ទម្រង់ល្ខោនពោលស្រី)

- បញ្ហាសមាធិ របស់ក្រុមល្ខោនពោលស្រី

- របៀបសំដែង

១២ - ការសំដែងកាយវិការ

១៣ - ការសំដែងពាក្យសំដី

១៤ - ការតុបតែងកាយតួអង្គ (សម្លៀកបំពាក់តុបតែងក្បាល)

១៥ - វង់តន្ត្រីប្រគំជាមួយការសំដែងល្ខោន

១៦ - អំពីទំនុកច្រៀង និង របៀបរៀបចំចុងចួន ចងក្រងពាក្យពេចន៍

(ល្ខោនវិទ្យុ, ទូរទស្សន៍, លើឆាក)

- ទីកន្លែងដែលល្ខោនពោលស្រីធ្លាប់ទៅសំដែង
- ប្រវត្តិក្រាំងល្ខោនពោលស្រី
- កំណត់ហេតុការស្រាវជ្រាវ

# ល្ខោន ពោលស្រី

## ១. និយមន័យ :

ល្ខោនពោលស្រី ជាទម្រង់ល្ខោនមួយសំដែងតាមបែបទម្រង់ល្ខោនក្បាច់បុរាណ និង ល្ខោនខោល ប៉ុន្តែតួអង្គសំដែងមាននិយាយពាក្យសំដី(១) និង ច្រៀង, សំដែងប្រកបជាមួយភ្លេងពិណពាទ្យ, មានពាក្យពោល មានចម្រៀងជាក្រុម ច្រៀងជូនកាយវិការ (ក្បាច់) តួទាំងអស់ត្រូវអោយដៃ(២) ទៅតាមពាក្យពោល និងចម្រៀង ។

ល្ខោនពោលស្រី តួសំដែងសុទ្ធតែជានារីភេទទាំងអស់ (តួស្វាក៏ ស្រីសំដែង) មានតួតុ្កកជាបុរស ពីរនាក់ជាអ្នករ៉ាប់រងកិច្ចការធូន់ៗ ។

ល្ខោនពោលស្រី មានអ្នកគ្រូម្នាក់ ឬ តាម្នាក់ជាអ្នកពោល កាត់កងឆាក ។

ល្ខោនពោលស្រីជាទម្រង់ល្ខោនបែបរាប់រឿងមានចរិតលក្ខណៈប្រពៃណីខ្មែរសុទ្ធសាធ ។

## ២. លក្ខណៈពិសេសរបស់ទម្រង់ល្ខោនពោលស្រី :

ល្ខោនពោលស្រី មានលក្ខណៈពិសេសគឺ អ្នកពោលដឹកនាំរឿង ពោលពាក្យបញ្ជាកាត់កងឆាក (ជានារីភេទ) សង្កត់ធ្ងន់ទៅលើអត្ថន័យរបស់ពាក្យពោលស្រី ។

ល្ខោនពោលស្រី គឺប្តូរមនុស្សសំដែងតួកណ្តាលសាច់រឿង (មានពីរលក្ខណៈ)

១-ប្តូរតួពីតូចទៅធំ

២-ប្តូរតួដែលមានសម្លៀកបំពាក់ដូចគ្នា ចេញសំដែងជំនួសគ្នា ពេលសំដែងហត់ខ្លាំងពេក បានសេចក្តីថា សម្រេចតាមពាក្យពេចន៍ពោល ពោល ថាតួសំដែងនេះឈ្មោះ...

---

(១)និយាយដោយឥតព្រាងទុក (ពាក្យសាមញ្ញក្នុងជីវិត ន័យត្រង់ៗ) ព្រោះ សិល្បការិនីមិនចេះអក្សរ ។

(២)អោយដៃពាក្យបច្ចេកទេស មានគ្រូពោលពាក្យ និង ចម្រៀងជាក្រុមជូន សិល្បការិនីដាក់ក្បាច់តាម ។

(ឈ្មោះតួក្នុងរឿង) គឺតួមុននោះឯងសំដែង បន្តសាច់រឿង (តួអង្គសំដែងយូរហើយហត់ពេក ដូរម្នាក់ទៀតអោយជួយសំដែងគ្នា) ។

អ្នកពោលមានតួនាទីសំខាន់ (ក្នុងដំណើរការសំដែង, ការដឹកនាំរឿង, កាត់កងឆាក, ពោលជូនកាយវិការគ្រប់តួ, ពោលប្រាប់ដំណើររឿង ជាមនុស្សសំខាន់បំផុតរ៉ាប់រងផ្ទាំងទស្សនីយភាពទាំងមូលពីដើមរហូតដល់ចប់) ។

ខ្លឹមសារពាក្យពោល គឺកំណត់ (សន្មត់) ឆាក, សាច់រឿង, ទីកន្លែង, បរិយាកាស... ។ល។

ដំណើររឿងវិវឌ្ឍន៍ទៅមុខ តែតួសំដែងមិនដូរទីតាំង ។

## ៣~ <u>លក្ខណៈពិសេសក្នុងការបង្ហាញតួ</u> :

ចំពោះតួ នាយរោង ឬ តួនាង (តួសំខាន់, តួឯក) ទោះបីតួនោះចេញសំដែងដំបូងទី ឬក៏កណ្ដាលសាច់រឿងក៏ដោយ ភ្លេងដើតចេញមកដល់មុខឆាក (កណ្ដាលឆាក) តែងតែសំពះគោរពភ្ញៀវជាមុនសិន ប្រាប់ឈ្មោះ (តួ) ប្រាប់ពីសកម្មភាពបម្រុងធ្វើដល់ទស្សនិកជន ទើបអាចសំដែងបន្តបរិយាកាសឆាកក្នុងសាច់រឿងតទៅទៀតបាន ។

## ៤~ <u>ប្រភពល្ខោនពោលស្រី</u> :

យើងខ្ញុំសុំដកស្រង់ប្រសាសន៍ ឯកឧត្ដម **ពេជ្រ ទុំក្រវិល** ប្រធានក្រុមស្រាវជ្រាវវប្បធម៌ និង សិល្បៈរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈដែលសរសេរក្នុងសៀវភៅទស្សនីយភាពខ្មែរមកជូនដើម្បីធ្វើការប្រៀបធៀបសម្រាប់ អ្នកសិក្សាជំនាន់ក្រោយស្វែងយល់មានដូចតទៅ (ល្ខោនពោលស្រីជាទម្រង់ល្ខោនច្រៀង, រាំបុរាណមួយដែលមានលក្ខណៈស្រដៀងគ្នា និងសិល្បៈល្ខោនក្បាច់បុរាណដែរ ទាំងតន្ត្រីជូនល្ខោនទាំងសម្លៀកបំពាក់ សំពត់, ស្បៃ, មកុដ, ក្បាំង, ប្រដាប់ដៃជើង និងអ្នកសំដែងគឺសុទ្ធតែ ស្រីទាំងអស់ សូម្បីតែតួអង្គប្រុសក៏ដោយ ។

ប៉ុន្តែបើពិនិត្យលើរបៀបសំដែងវិញ យើងសង្កេតឃើញថា មានភាពខុសគ្នាឆ្ងាយអំពីទម្រង់ល្ខោនក្បាច់បុរាណខ្មែរ ឬ ល្ខោនព្រះរាជទ្រព្យព្រោះល្ខោនក្បាច់បុរាណខ្មែរ ដែលតួអង្គសុទ្ធតែស្រីៗ បញ្ចេញតែកាយវិការដ៏ទន់ភ្លន់ប្រណីតទៅតាមទំនុកច្រៀងរបស់អ្នកចម្រៀងជាពួក មិនមាននិយាយ ឬ ច្រៀងដោយខ្លួនឯងឡើយ ។ ផ្ទុយទៅវិញ ក្នុងទម្រង់ល្ខោន ពោលស្រី ក្រៅពីពាក្យពោលដែលរៀបរាប់សាច់រឿង ឬ កាត់កងឆាក ដោយអ្នកពោលប្រុស ឬ ស្រី សិល្បការិនីអ្នកសំដែង, ទាំងតួអង្គប្រុស, តួអង្គស្រី (យក្ខិនី) យក្ខ, ស្វា... (បើកមុខរុញឡើងលើ) សុទ្ធតែត្រូវរាំច្រៀង ឬ និយាយដោយខ្លួនឯងទាំងអស់ ដែលពាក្យបច្ចេកទេសនៅក្នុងទម្រង់ល្ខោននេះ និយមហៅថា (ច្រៀងរាំឯង) ។

ចំពោះប្រភព និងកាលបរិច្ឆេទ កំណើតរបស់ទម្រង់ល្ខោនពោលស្រីនេះវិញ បើតាមការសង្កេតឃើញថា ទម្រង់ល្ខោននេះមាននៅក្នុងស្រុកខ្លះៗនៅតាមខេត្តកណ្តាលប៉ុណ្ណោះ ។ ហើយបើតាមព័ត៏មានដែល យើងបានទទួលរួចមកហើយនោះនាំអោយយើងមានគំនិតជាបណ្តោះអាសន្នថា ល្ខោនពោលស្រីជាកូនបង្កើតរបស់ **"ល្ខោនព្រះរាជទ្រព្យ "** ហើយប្រហែលជាកើតឡើងក្នុងពេលដែល ព្រះរាជសម្ភារ **ពញាតូ** (គ.ស ១៦២២) ជាព្រះមហាក្សត្រខ្មែរមួយអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យយ៉ាងខ្លាំងក្នុងវិស័យអក្សរសាស្រ្ត ដោយព្រះអង្គទ្រង់បានថ្វាយកិច្ចការផែនដីទៅ **ព្រះឧទ័យ** ជាម្ចាស់មារ មើលកិច្ចការជំនួស ហើយព្រះអង្គទ្រង់យាងចេញពីព្រះរាជវាំង (ឧត្តុង្គ) មកគង់នៅព្រះរាជវាំងកោះឃ្លោក (ស្រុកខ្សាច់កណ្តាល) ដើម្បីបំពេញព្រះរាជកិច្ចក្នុងផ្នែកអក្សរសាស្រ្តជាដើមដែលកាលណោះ ក្រោយពីកើតមានវិបត្តិផ្ទៃក្នុងព្រះបរមរាជវាំង (ឧត្តុង្គ) ព្រះរាជសម្ភារ (គ.ស ១៦២២) ព្រះអង្គបានភៀសព្រះកាយទៅតាំងរាជវាំងនៅកោះឃ្លោក (កោះឧញ៉ាតីសព្វថ្ងៃ) ។

ព្រះអង្គមានទេពកោសល្យខាងអក្សរសិល្ប៍ខ្ពស់ ពិសេសខាងសិល្បៈតែងកំណាព្យក្បួនច្បាប់ផ្សេងៗ និងល្បែងរបាំទៀតផង ។

ជាធម្មតា តាមទម្លាប់ព្រះមហាក្សត្រខ្មែរ បើលើករាជវាំងទៅតាំងនៅ

ទីកន្លែងណាមួយហើយ តែងតែនាំក្រុមរបាំព្រះរាជទ្រព្យទៅជាមួយដែរ។

ក្រោយមក **ព្រះរាជសម្ភារ** កើតមានវិវាទយ៉ាងខ្លាំងជាមួយម្ចាស់មារ គឺ **ព្រះឧទ័យ** បានរៀបអភិសេកជាមួយព្រះនាង **ចំន្ទទត្តី** ដែលត្រូវជាគូរដណ្ដឹងរបស់ព្រះរាជសម្ភារ ។ កាលណោះព្រះឧទ័យបានបញ្ជារកងទ័ពនៅក្រុងឧត្តុង្គ វាយលុកយកបានបន្ទាយកោះឃ្លោក ហើយព្រះរាជសម្ភារក៏ត្រូវបានគេបាញ់ទម្លាក់ពីលើចុងត្នោត ទ្រង់ក៏សោយទីវង្គត់ទៅ ។ ចំណែកក្រុមសិល្បៈ ក៏បែកខ្ញែកគ្នាទៅរស់នៅក្នុងស្រទាប់ប្រជារាស្ត្រអស់ទៅហើយដែរ ។

**៥~ប្រវត្តិល្ខោន ពោលស្រី :** (*ព័ត៌មានបន្ថែម*)

តាមការស្រាវជ្រាវដែលយើងទទួលបានជាព័ត៌មានបន្ថែម ចំពោះល្ខោន (ស្រី) គឺជាលក្ខណៈពិសេសរបស់ខេត្តកណ្ដាល ដែលនៅគ្រប់ខេត្តទូទាំង ព្រះរាជាណាចក្រកម្ពុជា គ្មានល្ខោនបែបនេះទេ គឺមានតែនៅតាមតំបន់ខ្លះ របស់ខេត្តកណ្ដាល ជួរតាមដងទន្លេមេគង្គប៉ុណ្ណោះ ឃើញមានទម្រង់ល្ខោនបែបនេះសំដែង (គឺមានសំដែងចាប់ពីព្រែកពោធិ៍ចុះមករហូតដល់អ្នកលៀង ហើយនិងនៅស្រុកខ្លះតាមដងទន្លេតូចជាចុងជាយខេត្តព្រៃវែង) ។ នេះជា ប្រសាសន៍របស់លោកតា **កែវ សួន** វរៈសិល្បករផ្នែកតន្ត្រីបុរាណ លោក មានជន្មាយុជាង ៨០ឆ្នាំហើយ ក្នុងឆ្នាំ ២០០៣នេះ ។

លោកមានប្រសាសន៍ថា គាត់ឃើញមានការសំដែងល្ខោនបែបនេះ តាំងតែពីរូបគាត់នៅតូចស្រពេចស្រពិលចាំមិនច្បាស់ ! ។

នៅវត្តព្រះវិហារសួគ៌ មានព័តមានបន្ថែម (០៣-០៣-២០០៦) ខ្ញុំបានជួបជាមួយគ្រូភ្លេងពិណពាទ្យមួយរូបឈ្មោះ **តា សាន់** អាយុ ៨៥ឆ្នាំ, នៅ វិហារសួគ៌ ឬ ហៅស្រុកត្នោតគាត់ជាកូនរបស់គ្រូភ្លេងពិណពាទ្យដែរឈ្មោះ **តា ខែន** (សក់កណ្ដាញ់) បានឱ្យព័ត៌មានថា មានល្ខោនស្រីពីរវង់ គឺវង់ល្ខោន **យាយ គង់** និងវង់ល្ខោន **តា ចាន់** អ្នករាំល្ខោនស្រីទាំងនោះឈ្មោះ **យាយ ម៉ិច** ក្រោយមកកូនគាត់ឈ្មោះ **យាយ ណារ៉ុ** (រៀនតពីម្ដាយ), **យាយ ម៉ើ**, **យាយ គួរ**

(ឈ្មោះយាយៗទាំងនេះសុទ្ធតែជាតួឯកល្ខោននៅក្នុងក្រុម) ។

ដូច្នេះកាលពីអំឡុង ៧០-៨០ ឆ្នាំមុន យើងឃើញមានក្រុម ល្ខោនស្រី នៅកោះឧញ៉ាតី អ្នកបើកក្រាំងឈ្មោះ តា **(គង់)** ។

នៅមាត់ក្រសះ អ្នកបើកក្រាំងឈ្មោះ តា **(មាស)** តួយក្ខដ៏ល្បី យាយ **(សុខ)** នៅវត្តកៀនស្វាយ យើងរកឃើញពីរតំណមនុស្សទី១ លោកតា **(ម៊ុន)** ទី២ លោកតា(ជាដែក) តួកមានពីរនាក់ ដែលមានប្រជាប្រិយ៍បំផុតគ្រាន់តែដើរកាត់ឆាកប្រជារាស្ត្រស្រែកហ៊ោអំណរអបអរសាទរ គឺតា **គង់** និងតា **ខាវ** (ឪពុកតាដែក) ។

តាៗទាំងពីររូបនេះ តាំងពីលោកយាយ **ខាវ មុត** វរៈសិល្បការិនីនៅអាយុពេញក្រមុំ ១៧-១៨ឆ្នាំ ឥឡូវគាត់មានអាយុជិត ៨០ឆ្នាំហើយ (ឆ្នាំ ២០០០) ។ លោកតា **(គង់)** យើងបានព័ត៌មានពីលោកតា **នៅ ខាវ** មានមាឌធំចម្លែករូបរាងសឹងមនុស្សយើងពីរនាក់កម្ពស់ប្រហែលពីរម៉ែត្របន្តិចបន្តួច លីអង្គរម្តងប្រហែល (២០០ គីឡូក្រាម) ២បាវត្រួតលើគ្នា ។ ដើមឫស្សីមួយដើមកាប់លួសមែកចេញ ហើយគាត់ចាប់ខាងចុងតែដៃម្ខាង គាត់លើកឡើងលើរហូតត្រង់ភ្លីង ។

លោកតា **គង់** ក៏ជាទីគាប់ព្រះរាជហឫទ័យរបស់ព្រះករុណាព្រះស៊ីសុវត្ថិ **មុនីវង្ស** ដែរក្រៅពីគាត់ជាតួកល្ខោន គាត់ជាអ្នកកាន់ក្បាលទូក **"ខ"** វត្តកៀនស្វាយក្រៅពេលមកប្រណាំង បុណ្យអុំទូករាល់ឆ្នាំ (ព្រោះទូក **"ខ"** វត្តកៀនស្វាយក្រៅជាទូកមានល្បឿនលឿនក្នុងចំណាត់ថ្នាក់ ។

លោកតា គង់ បើគាត់រស់នៅរហូតដល់សព្វថ្ងៃគាត់មានអាយុប្រហែល ១៣០ឆ្នាំផ្លាយហើយ (ឆ្នាំ២០០០)។ ខ្ញុំ ចិន្ត នាគ អ្នកស្រាវជ្រាវ និងជាស្ថាបនិកក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ អោយរស់ឡើងវិញពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០០។ ខ្ញុំបាទនាំក្រុមល្ខោននេះទៅសំដែងក្នុងពិធីបុណ្យឆ្លងសហស្សវត្សរ៍ នៅខេត្តសៀមរាប ប៉ុន្តែឥឡូវនេះក្រុមល្ខោននេះក៏បានស្លាប់ទៅវិញ ដោយគ្មានការជួយឧបត្ថម្ភ (គ្មានឆាកហាត់ និងគ្មានសកម្មភាពសំដែង)។ សូមបញ្ជាក់ថា ក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ ជាក្រុមល្ខោន (សហគមន៍) ដោយមានសិស្សហាត់រៀន ក្បាច់ចំនួន ៦ ភូមិ ជាកូនចៅរបស់

ប្រជារាស្ត្រឃុំ ភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ក្រុមសិល្បៈល្ខោនពោលស្រី ទៅចូលរួមសំដែងនៅអង្គរវត្ត ខេត្តសៀមរាបនេះ ក្នុងនាមតំណាងក្រុមសិល្បៈ ខេត្តកណ្តាល ដែលមានខេត្ត ចំនួន ៥ ជាតំណាងទូទាំងកម្ពុជាចូលរួម :

១- ខេត្តកណ្តាល

២- ខេត្តកំពង់ស្ពឺ

៣- ខេត្តសៀមរាប

៤- ខេត្តតាកែវ

៥-ខេត្តពោធិ៍សាត់

(ដែលរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជម្រើសរកលក្ខណៈ ពិសេសរបស់ក្រុមសិល្បៈតាមបណ្តាខេត្តទូទាំងប្រទេស) ។ យើងងាកមករៀបរាប់តា **គង់** ជាបន្ត ខ្ញុំអ្នករៀបរៀងអត្ថបទទម្រង់ ល្ខោនពោលស្រី ខ្ញុំសូមលើកស្នាយ កិត្តិយសជូនអ្នកល្ខោនខ្មែរ មួយរូបនេះជា (វីរៈបុរស) អ្នកតំណាងល្ខោនខ្មែរមួយរូបដែលបានពលី (ស្លាប់) ក្នុង ឆាកល្ខោន លើឆាកល្ខោន ពេលល្ខោនកំពុងសំដែង ពេលទស្សនិកជនកំពុងស្រែក អបអរសាទរហ៊ោកញ្ជ្រៀវសប្បាយរីករាយយ៉ាងខ្លាំង តាមរយៈកាយ វិការកំប្លុកកំប្លែង របស់គាត់ បែរជាគាត់ត្រូវដួលដាច់ខ្យល់ស្លាប់មួយរំពេចពេល ដើរងាកចូលឆាកវិញ ពេលនោះស្រាប់តែគាត់ដួលប្រូស (ជើងនៅក្រៅឆាក ក្បាលនៅក្នុងឆាក) ផុតដង្ហើម មួយរំពេចក្បែរផ្លូវចេញចូលខាងឆ្វេងដៃឆាក (គឺគាត់ស្លាប់ក្នុងឆាកល្ខោនវត្តកៀនស្វាយ ក្រៅហ្នឹងតែម្តង ក្នុងរដូវបុណ្យភ្ជុំបិណ្ឌទឹកលិចភូមិ ពេលអ្នកស្រុកអុំទូកមកចតទូកមើល ល្ខោនត្រៀបត្រាពេញ ផ្លាមុខព្រះវិហារ) គាត់ស្លាប់ក្នុងពេលគាត់កំពុងសំដែងជាតួត្លុក កំប្លែងក្នុង រឿង **ព្រះជិនវង្ស** ត្រង់ឈុតព្រះជិនវង្សយាងចូលទៅចង់ស្រី សួរគាត់ថា មើលនាយ **គង់** ដំណើរទៅចង់ស្រីធ្វើបែបម៉េចទើបស្រីស្រឡាញ់នោះ? គាត់(តាគង់) ក៏សំដែងដំណើរបែបកំប្លែង ថ្វាយព្រះជិនវង្សទត ហើយថ្វាយបង្គំព្រះអង្គអោយរៀន ធ្វើតាមទស្សនិកជនស្រែកហ៊ោកញ្ជ្រៀវ សប្បាយយ៉ាងខ្លាំង ព្រោះព្រះជិនវង្សត្រាប់ តាមដំណើរគាត់នោះក៏យាងចូលទៅជំណាក់នាង... ហើយហៅគាត់ជូនដំណើរទៅ

ជាមួយ គាត់ថា (ទូលបង្គំមិនទៅទេ ព្រះអង្គយាងមួយអង្គឯងចុះ ទូលបង្គំចាំព្រះអង្គនៅត្រង់នេះហើយ) តួព្រះជិនវង្សយាងចូលផុតគាត់ក៏ដាក់ក្បាច់ចូលកាត់ឆាកដែរ... ស្រាប់តែ ដួលភ្លាមដាច់ខ្យល់ស្លាប់តែម្តង ខណៈនោះមនុស្សម្នារួមទាំងអ្នកសំដែងឆោឡោភ្លាមពេញរោង ក្រុមល្ខោន គ្រូល្ខោន ក៏យកគាត់ទៅដាក់មុខព្រះវិហារ គ្របក្រណាត់សចោលមួយយប់ក្រែងគាត់រស់ឡើងវិញ តាមពិតគាត់ស្លាប់ប្រាកដមែន (គ្មានមូលហេតុ) ទើបបងប្អូន ក្រុមសិល្បៈក៏នាំគ្នាធ្វើពិធីបូជាសពតាមប្រពៃណីជាសូរេចហោង ។

តួត្លុកកំប្លែងតា **ខាំ** ឪពុកតា **ដែក** (ឪពុកសំដែងតួកំប្លែងកូនប្រុសគាត់ តាដែក ពោល អ្នកបើកក្រាំង) បាត់ដៃគូ ក្រុមល្ខោននេះគ្មានតួកំប្លែងចេះតែរោយទៅៗ... ។

កត្តាទី ២ គ្មានអ្នកគាំទ្រ គឺគ្មានអ្នកមានមាសប្រាក់កាសណាចេញមុខឧបត្ថម្ភ (កាលណោះមានចៅកែម្នាក់ឈ្មោះ **ឈី** ជាអ្នកឧបត្ថម្ភ លុះគាត់ស្លាប់ទៅគ្មានអ្នកណាឧបត្ថម្ភ) រហូតមកដល់ទស្សវត្សរ៍ទី៦០ក៏បញ្ចប់សកម្មភាពនេះទាំងក្រុមតែម្តងទៅ ។ គួរអោយអាសូរនៅសល់តែយាយចាស់ៗ៦រូបនាំគ្នាសំដែងរំលឹកគុណគ្រូល្ខោនរាំថ្វាយទសបារមីព្រះអង្គក្នុងព្រះវិហារ (វត្តកៀនស្វាយ) ពេលថ្ងៃពេញបូរមី និងថ្ងៃខែដាច់រៀងរាល់ខែជាប់ជាប្រចាំ សំពះគ្រូរៀងរាល់ឆ្នាំ ចង់បន្តប្រពៃណីចង់អោយល្ខោនពោលដែលគាត់ធ្លាប់សំដែងរស់ឡើងវិញ... ។

កំណត់ហេតុអ្នកស្រាវជ្រាវ សូមជម្រាបបញ្ជាក់ថា លោតា **គង់** នេះគឺជាស្នូលរបស់ក្រុមល្ខោន គាត់ស្ទាត់មុខគ្រប់តួអង្គក្នុងរឿងដែលល្ខោនពោលស្រីវត្តកៀនស្វាយក្រោសំដែងចំនួន ៧រឿង ដែលក្រាំងបានចារទុកនេះ (ព័ត៏មានពីលោកយាយៗបានអោយដឹងថា បាត់ក្រាំងសៀវភៅខ្មៅ មួយរកមិនឃើញមិនដឹងអ្នកណាបន្លំយកទៅបាត់ ពេលដែលវត្តកៀនស្វាយក្រោមានវិបត្តិឈ្លោះទាស់ទែងបែកសាមគ្គីគ្នាមានរហូតដល់កាប់បំផ្លាញសំភារៈសំដែងមុនទៅសំដែងនៅអង្គរវត្ត (សៀមរាប) ។

ចំពោះប្រវត្តិល្ខោនពោលស្រីនេះ យើងខ្ញុំអ្នកស្រាវជ្រាវសាកល្បងធ្វើការវិភាគវិនិច្ឆ័យខ្លះ ដោយយោងទៅលើសមត្ថកម្មខ្លះ ពាក្យថា ភាណៈ ប្រែថា ពោល

(វចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ទំព័រ ៨១៥ ប្រែថា ពោល នី. នារី ឬ ស្ត្រីភេទ) ហើយពាក្យ (ភាណី) មានក្នុងសិលាចារឹក **K99** នាសតវត្សរ៍ទី... ថាជាល្ខោនប្រុស គឺល្ខោនខោលនោះឯង (យោងតាមឯកសារល្ខោនខោលរបស់លោក **ពេជ្រ ទុំក្រវិល** បោះពុម្ព ឆ្នាំ ២០០០ ទំព័រទី ៣០) ។

សូមអាធ្យាស្រ័យចំពោះលោក ពេជ្រ ទុំក្រវិល មិនមែនខ្ញុំថានេះចង់ប្រកួតប្រជែង ឬ បង្វែរ ទិសដៅអ្វីនោះទេ តែខ្ញុំគ្រាន់តែលើកកត្តាសំអាងខ្លះទុកគ្រាន់អ្នកស្រាវជ្រាវជំនាន់ក្រោយស្វែងយល់នូវទម្រង់ល្ខោននេះព្រោះ តួនាទីស្ត្រីមានធំធេងណាស់សម័យខ្មែរជាមហាអាណាចក្រ ស្ត្រីធ្វើទ័ព កាត់សក់ផ្កាថ្កូវចេញច្បាំងស្ត្រីធ្វើអង្គរក្សការពារព្រះរាជាខ្មែរ មេទ័ព (ទ្រមាក់ ចៃវគុណ) ខ្ញុំភ្លេចរូបថតស្ត្រីមេទ័ពកាត់សក់ផ្កាថ្កូវហើយស្លៀកប៊ីងដូចទ័ពបុរសដែរ ។

ព័ត៌មានដែលយើងមាន រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ព្រះនាងឥន្ទ្រទេវីបាននាំរាជបុត្រីសំដែង រឿងជាតកនៅរាជវិហារ គឺប្រាសាទតាព្រហ្ម ។ ចម្លាក់ទាំងឡាយដ៏ច្រើនសន្ធឹកសន្ធាប់នៅតាមជញ្ជាំងបណ្តាប្រាសាទនានា អ្នកភ្លេងជានារីភេទ តើមានល្ខោនស្រី ឬទេ ? (អ្នកសំដែងជាស្ត្រីសុទ្ធ) ។

ចំពោះពាក្យថា **ល្ខោនពោលស្រី** នេះនៅលើក្របក្រាំង ដែលមានចំណាស់ជិត២០០ឆ្នាំ (ពាតំណមនុស្ស) មានសរសេរពាក្យថា (ក្រាំងសម្រាប់ពោលលេងល្ខោន) ។ ហើយយោងទៅលើមូលដ្ឋាននៃការដែលអ្នកស្រុកចាស់ៗមានឃើញល្ខោនស្រីនេះសំដែងដូចខ្ញុំជម្រាបជូនខាងលើ (គឺតាមមាត់ទន្លេមេគង្គ និងតាមមាត់ទន្លេតូច) ។ បើយើងគិតពីរាជធានីខ្មែរតាំងពីពេល បែកអង្គរមកព្រះរាជាខ្មែរ ព្រះបាទ **ស្រីសុគន្ធបទ** (១៥០៤-១៥១២) តាំងរាជធានីនៅ ទួលបាសាន្តមានព្រះរាជា៨ព្រះអង្គ (ឯកសារគ្រឹងងារទំព័រ១៦៥) សោយរាជ្យ (គឺព្រះបាទស្រីសុគន្ធបទ និងព្រះពញាយ៉ាត (១៣៩៣-១៤៦៣ សៀវភៅប្រវត្តិសាស្ត្រខ្មែរគ្រឹងងាទំព័រ១៣៨-១៣៤) ពេលគៀសសង្គ្រាមចុងសម័យអង្គរ មុនព្រះរាជាខ្មែរតាំងរាជធានីនៅបន្ទាយលង្វែក) ក្នុងស្រុកស្រីសន្ធរ គឺស្រីសឈរ ហើយស្តេចប្អូនតាំង បន្ទាយការពារនៅភ្នំពេញ ។

លង្វែកបែកនៅឆ្នាំ ១៥៩៤? ។ រាជធានី ឧត្តុង្គ កសាងដោយព្រះបាទជ័យជេដ្ឋាទី ២ **ព្រះរាជសម្ភារ ឬ ពញាវត្ត** ជាព្រះរាជបុត្ររបស់ព្រះបាទជ័យជេដ្ឋាទី ២ (១៦២២) តែនេះវាគ្រាន់តែជាសមត្ថិកម្ម ល្ខោនពោលស្រី ជាកូនបង្កើតរបស់ល្ខោនព្រះរាជទ្រព្យខ្មែរ ។ នៅក្នុងក្រាំងមាន ៧រឿង សុទ្ធសឹងជារឿងក្នុងសាស្ត្រា ល្បែង គឺអក្សរសិល្ប៍ក្នុងសម័យលង្វែក យើងសង្កេតក្នុងអង្គរឿងគ្មានចលនាពុទ្ធនិយមទេ (នៅក្នុងរឿងជ័យសែន គឺ មានអន្តរាគមន៍ពីព្រះឥន្ទ្រាធិរាជពេលតួអង្គប្រុសមានទុក្ខ) គឺអក្សរសិល្ប៍មានចលនាព្រហ្មនិយម សូមជួយពិចារណា ដើម្បីកំណត់កាលបរិច្ឆេទ របស់ល្ខោនពោលស្រីអោយច្បាស់លាស់ យើងខ្ញុំគ្មានលទ្ធភាពក្នុងផ្លូវសំភារៈដើម្បីធ្វើការស្រាវជ្រាវទេ ។

យើងគ្មានឯកសារយោងជាលាយលក្ខណ៍អក្សរគ្រប់គ្រាន់ ឯកសារ **ជីវតាក្វាន់** ក្នុងខែទី ៨ គេ **រាំអៃឡាំ** នៅទីក្រុង...។ មាននារីជា ទេវទាសី ស្រីរបាំ (ប្រាសាទដែលល្បីៗ របស់ព្រះបាទ **ជ័យវរ្ម័នទី ៧** មាន ស្រីរបាំរាប់ពាន់ (១១៨១-១២១៨) ក្នុងពេលនោះប្រាសាទតាព្រហ្ម មានស្រីរបាំចំនួន ៦១៥នាក់ ប្រាសាទព្រះខ័នស្រីរបាំ មានរហូតដល់ទៅ ១០០០នាក់ឯណោះ) ប្រវត្តិ ល្ខោនខោល លោក **ពេជ្រ ទុំក្រវិល** ទំព័រ ១៨)។

-ទម្រង់ល្ខោនក្បាច់បូរាណ សំដែងរឿងរាមកេរ្តិ៍ (ល្ខោនស្រី)

-ទម្រង់ល្ខោនពោលស្រី មិនសំដែងរឿងរាមកេរ្តិ៍ទេ មានសំដែងតែរឿងដែលមានចារនៅលើស្លឹករឹត គឺនៅសម័យ លង្វែកដើមសម័យឧត្តុង្គ (អ្វីដែលស្លាប់វាក៏មិនស្លាប់ភ្លាមដែរ ពាក្យនេះប្រើចំពោះ វិស័យវប្បធម៌ វានៅមានតម្រុយ និង វាអោយតម្រុយខ្លះមុនវាកើត វាស្លាប់នេះ) ។ ទ័ពស្រី, អ្នករបាំស្រី, អ្នកលេងភ្លេង ចុះល្ខោនពោលស្រី? មិនយុគអង្គរ មិនមែន ជាសករាជស្ត្រីដែរទេឬអី? យើងអាចកំណត់ប្រវត្តិគឺជាមតិកខ្មែរសុទ្ធសាធដែលមាន មកពីឰដ៏ព្រេងនាយ ហើយអ្វីដែលវាកើតក៏មិនអាចកើតភ្លាមដែរក្នុងប្រទេសយើងជា មហាអាណាចក្រ ។

យើងអាចសន្និដ្ឋានបានថា ល្ខោនពោលស្រីជាមតិកមួយរបស់អាណាចក្រខ្មែរពីសតវត្សរ៍ទី ៩ ដល់សតវត្សរ៍ទី ១៥ (សម័យមហានគរ)ហើយពាក្យ ក្នុង

សិលាចារិក K99 **ល្ខោនភាណី** នេះឯង ។ ចង្កោមល្ខោនពោល គឺ ល្ខោនព្រះរាជទ្រព្យ, ល្ខោនពោលប្រុស ឬ ល្ខោនខោល, ល្ខោនពោលស្រី, ល្ខោនស្បែកធំ, ល្ខោនស្បែកពណ៌, ល្ខោនយីកេ... ។ ល្ខោនទាំង ៦ ទម្រង់នេះ តែគ្មានពាក្យពោល គឺបាត់សាច់រឿង ។

## (ការសន្និដ្ឋានទី២)

## មតិសរុប : មតិសរុបប្រមូលផ្តុំព័ត៌មាន កំណត់ប្រវត្តិល្ខោនពោលស្រី

-ព័ត៌មានដំបូងបានមកពីលោកតា **លឹម ប៉ែន** (១) ថា (ខ្ញុំដឹងថា មានសល់ក្រាំងល្ខោនខោលមួយ នៅនឹងស្រុកកៀនស្វាយ... គឺក្រាំងល្ខោន ខោល ។

-អ្នកខ្លះហៅល្ខោនដែលយើងដាក់ថា ល្ខោនពោលស្រីនេះ គឺល្ខោនខោលបុរាណសំដែងបើកមុខ ។

-យាយៗអ្នកសំដែងហៅល្ខោននេះថា (ល្ខោនស្រី) ទម្លាប់ពីដូនតាតរៀងមក ។

-ល្ខោនពោលស្រីនេះ ក៏ស្ថិតនៅក្នុងវត្ត និង របៀបរបបឧបត្ថម្ភដោយព្រះសង្ឃ ហើយបើពិនិត្យលក្ខណៈសំពះគ្រូល្ខោន គឺសំពះមុនថ្ងៃចូលឆ្នាំថ្មី និង ថ្ងៃកោរ មុនភ្ជុំបិណ្ឌ បុណ្យភ្ជុំបិណ្ឌគឺបុណ្យព្រះពុទ្ធសាសនា ។

-លោក **នួន កន** មានប្រសាសន៍ថា វត្តព្រះពុទ្ធសាសនាខ្មែរបានបង្កើតបណ្តុះវប្បធម៌សម្រាប់សង្គមជាតិ ។

-ព្រះនាងឥន្ទ្រទេវី ព្រះអគ្គមហេសីព្រះជាយាព្រះបាទជ័យវរ្ម័នទី ៧ ពុទ្ធសាសនូបត្ថម្ភ ទំនុកបម្រុងព្រះពុទ្ធសាសនានិកាយមហាយាន ព្រះនាងបាននាំព្រះរាជកុមារីទៅព្រះរាជវិហារសំដែងរឿងជាតក ។

-ក្រោយពីការសិក្សាស្រាវជ្រាវ ដោយមានអំណះអំណាងផងសមត្ថិកម្មផង យើងកំណត់ប្រវត្តិល្ខោនពោលស្រី គឺ ល្ខោនភាណី ដែលជា ពាក្យចារ ក្នុងសិលាចារឹក K99 ដូច្នេះចង្កោម (**ល្ខោន ភាណីល្ខោនពោល**) មានល្ខោន

ពោលប្រុស, ល្ខោនខោល, (សំដែងបានតែរឿងរាមកេរ្តិ៍) ល្ខោនពោលស្រីឃើញមានសំដែង៧រឿង, ល្ខោនក្បាច់បុរាណ ឬ ល្ខោនហ្លួង ល្ខោនស្រី សំដែងបានរឿងរាមកេរ្តិ៍ (តែបច្ចុប្បន្ន ល្ខោនក្បាច់បុរាណនេះមានសំដែងរឿងព្រេង**កថា** ផងដែរ) ។

## រឿងទាំង ៧ ដែលមានចារទុកក្នុងក្រាំង

១- ជ័យសែន
២- ជ័យទត្ត
៣- ព្រះជិនវង្ស (បាត់)
៤- ព្រះឃោ ប៊ុត (បាត់)
៥- លិនថោង (យាយ១ហៅចាប់ត្រីឆ្លិនមាស)
៦- ព្រះសុធន នាងកែវមនោរា
៧- ព្រះភិណ្ណវង្ស

.................................................................................................

១ លោកតា **លឹម ប៉ែន** ស្គាល់យាយ **ជា មុត** ដំបូងនៅលើកោះ មុខកោះ ប្រាក់ដោយតា **ប៉ែន** អ្នកពោល យាយ **ជា មុត** (អោយដៃ) ត្រូវសម ។

*សូមរង់ចាំអានប្រវត្តិល្ខោនខ្មែរ និពន្ធដោយលោកសាស្ត្រាចារ្យ **ចិន្ត នាគ** និង មានចេញផ្សាយក្នុងពេលឆាប់ៗខាងមុខនេះ ។

<u>**កំណត់ចំណាំ**</u> : រយៈពេលជិត ៤០ឆ្នាំនេះ ក្រុមល្ខោនពោលស្រីបាត់បង់ការសំដែងជាផ្ទាំងទស្សនីយភាព គឺស្លាប់ក្នុងទសវត្សរ៍ទី ៦០ ពេលដែលព្រះរាជាណាចក្រកម្ពុជាកំពុងឈានឡើងរីកចម្រើនស្ទើរគ្រប់វិស័យ ចុះហេតុអ្វីបានជាល្ខោនពោលស្រីស្លាប់ឈប់មានការសំដែង តើអ្នកស្រុកអ្នកភូមិមិនស្រឡាញ់កេរមត៌កស្នាដៃសិល្បៈលក្ខណៈពិសេសទូទាំងកម្ពុជាឬ?... មិនមែនទេ គឺស្លាប់ព្រោះទប់មិនឈ្នះ និងការរីកចម្រើនរបស់ទម្រង់ល្ខោន ថ្មីក្រោយៗ(បាសាក់) មិនឈ្នះទម្រង់ល្ខោនថ្មី ទាញយកប្រជាប្រិយ៍ភាពក្នុងចំណោមទស្សនិកជន ចំណុចទី២ ស្លាប់ព្រោះបាត់មេកើយខ្លាំងៗគ្មានអ្នកមានធនធានណាលោកចេញមុខឧបត្ថម្ភទ្រទ្រង់ល្ខោន?... (ល្ខោនដែលល្អគ្មានពីរនៅកម្ពុជាអាចស្លាប់ ចុះនោះទសវត្សរ៍ទី៦០ ល្ខោនស្លាប់ ចុះក្នុងឆ្នាំ ២០០០ ល្ខោនកើតហើយស្លាប់វិញដែរ? ដើងវត្តឈ្លោះគ្នា គាស់ទ្វារកុដិលោក កាប់បំផ្លាញសម្ភារៈល្ខោនយ៉ាងម៉េចទៅវិញ?)

ក្រោយទសវត្សរ៍ទី ៦០ ការសំដែងទ្រង់ទ្រាយធំស្លាប់ មានតែរាំថ្វាយព្រះក្នុងព្រះវិហារដោយយាយៗ ៦រូប តាភ្លេង ១រូប ចុះឥឡូវក្រោយឆ្នាំ ២០០០ មានកូនសិស្សដែលរៀនបានជាប់រហូតចំនួន៧៨រូប តើល្ខោនពោលស្រីអាចបាត់រូបឬទេ? សុំយើងសួរគ្នាយើង ខ្មែរសម័យនេះអាយុស្របាលៗគ្នាមើល តើអ្នកណាជាអ្នកទទួលខុសត្រូវ?

## វណ្ណាប់ល្បោនពោលស្រី រាំថ្វាយបារមីព្រះអង្គក្នុងព្រះវិហារ




គុតម្កល់ក្រាំង
ដូងខ្សៅ
អ្នករបាំ



លោក **ចិន្ត នាគ** (សមាជិកអចិន្ត្រៃយ៍) គណៈកម្មការ ស្រាវជ្រាវសិល្បៈវប្បធម៌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ (រូបថតមុខស្ពានថ្មចូលប្រាសាទបាពួន)



លោកយាយ **គុំ** ប្រពន្ធតា **ជា ជែក** និង
ក្រាំងល្ខោនពោលស្រីកេរដំណែលដែលតាបានបន្សល់ទុក

កិច្ចពិភាក្សាជាមួយភិក្ខុ **យង់ ចំរើនភក្តី** និង
(គណៈកម្មការអាចារ្យវត្តដើម្បីបង្កើត ក្រុមសិល្បៈ)





ពិធីថ្វាយខ្លួន (សំពះគ្រូ) ក្រុមល្ខោនយាយ **ជា មុត** វត្តកៀនស្វាយក្រៅ

បដានេះជាសំបុត្រកំណើតបញ្ជាក់ពីការរស់ឡើងវិញរបស់ទម្រង់ **ល្ខោនពោលស្រី**
វត្តកៀនស្វាយក្រៅជាលើកទី២ (១៣-០៥-១៩៩៨)





លោកយាយ **ជា មុត** បួងសួងសុំព្រលឹងយាយគ្រូជួយបង្កើត
និងថែរក្សាក្រុមល្ខោន (យាយមុត ជាឆ្មបបុរាណ)

លោកយាយ **ជា មុត** តួនាយរោងឯក
លោកយាយសំដែងតួឯកគ្រប់រឿងដែលមាន ចារទុកនៅក្នុងក្រាំង





កិច្ចពិភាក្សាដើម្បីស្រង់ព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ទម្រង់ **ល្ខោនពោលស្រី**
នៅវត្តកៀនស្វាយក្រៅ

(១)យាយ យីន តួយក្ស (២)យាយ គិន យិន តួយក្សតួស្វា
(៣)យាយ សាន់ យីន តួនាយរោង (សំដែងជាតួបុរស)





(១)លោក **ហាង សុត** ប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព
មានវត្តមានក្នុងថ្ងៃប្រារព្ធពិធីថ្វាយខ្លួនសិស្សថ្មីដើម្បីហាត់រៀនក្បាច់ល្ខោនពោលស្រី





សិស្សទាំង៦ភូមិ ក្នុងឃុំភូមិធំ ជាង១៥០នាក់ ចូលរួមប្រារព្ធពិធីថ្វាយខ្លួន

(១)លោក **ចិន្ត នាគ** ពិភាក្សា និង រិះរកវិធីដើម្បីភាពរីកចម្រើន និងភាពគង់វង្សរបស់ក្រុមល្ខោន (២)វរៈសិល្បករតា **កែវ ស្វន** គ្រូភ្លេងពិណពាទ្យនៅនាយកដ្ឋានសិល្បៈ ទស្សនីយភាព (៣)លោក **សុខ អឿន** ប្រធានមន្ទីរ វប្បធម៌និងវិចិត្រសិល្បៈខេត្តកណ្ដាលចូលរួមក្នុងពិធី





ការប្រុងប្រៀបត្រៀមលក្ខណៈប្រយ័ត្នប្រយែងរំលឹកកិច្ចការទាំងឡាយ
ដែលយាយគ្រូធ្លាប់ធ្វើ (ត្រួតពិនិត្យមុនចាប់ផ្ដើម)

ពិធីដុតទៀនធូបសំបូងសង្រូង អញ្ជើញគ្រូតូចគ្រូធំមកកាន់រោងពិធី





គ្រូពោលប្រុសចាប់ផ្ដើមសូត្រតាមក្បួនពិធី
សំពះគ្រូ (ឯកសារ) លោកតា **ខាំ ជែភ** កត់ត្រាទុក

យាយៗរំលឹកក្បាច់ និងបង្ហាញក្បាច់ចំពោះព្រលឹងយាយគ្រូ





យាយគ្រូត្រៀមខ្លួនទទួលយកកុមារី ដើម្បីបង្ហាត់ទៅតាមឯកទេស

លោក **ចិន្ត នាគ** ពិភាក្សាស្រង់ព័ត៌មានពីសំណាក់យាយៗ
ដើម្បីបង្គ្រប់ជាព័ត៌មានបន្ថែមក្នុងថ្ងៃប្រារព្ធពិធី





សេចក្តីសង្ឃឹម និងភាពមោះមុត

ឆន្ទៈខ្ពស់បំណងរក្សាវប្បធម៌ប្រពៃណីខ្មែរ





លោកយាយៗផ្លាស់សម្លៀកបំពាក់ធម្មតាចេញ
ដូរភាពទៅជារស់ក្នុងភាពជាសិល្បការនី

ចរិតស្លូតបូតសុភាពរៀបសារនារីខ្មែរលើកស្ទួយថែរក្សាសិល្បៈវប្បធម៌ខ្មែរ





ដូរភាពយាយ **ជា មុត** ជាកសិករ ពីលោកយាយជាឆ្មបបុរាណបង្កើតកូនឱ្យអ្នកនៅភូមិជាមួយទៅជាតួឯកល្ខោនពោល លើកដៃឡើងរាំទន្ទាំបោយបក់ពេនពន់យ៉ាងសង្ហារអស្ចារ្យ





ក្រុមឯកទេសយក្សបង្ហាញក្បាច់

អ្នកគ្រូ សិល្បការិនី ផ្នែករបាំបុរាណនៅនាយកដ្ឋានសិល្បៈ ទស្សនីយភាពចុះជួយក្នុងការជម្រើសសិស្ស បែងចែកតួនាង តួនាយរោង តួយក្ស ដើម្បបង្ហាត់ឯកទេស





ការស្រេងស្ថិតិសិស្សទៅតាមឯកទេស (១)អ្នកគ្រូ ប៉ែន សុខជា (ស្ថាបនិក) ប្រធានការិយាល័យស្រាវជ្រាវរបាំក្បាច់បូរាណខ្មែរ (ល្ខោនហ្លួង)



អ្នកគ្រូនៅនាយកដ្ឋានសិល្បៈ ឯកទេសទៅតាមលក្ខណៈតួមិនមែនឱ្យសុំរាំតាមចិត្តចង់នោះទេ



ព្រះភិក្ខុ **យង់ ចំរើនភក្តី** គង់សង្កេតជួយស្តាបនា ដោយទឹកព្រះទ័យជ្រះថ្លា

(១)យាយ **ជា មុត** (២)តា **នៅ ជា** ម្ចាស់ឧបករណ៍តន្ត្រីពិណពាទ្យ

(៣)តា............ប្រធានភូមិត្នោត ចូលរួមឱ្យយោបល់ក្នុងការកសាងក្រុមល្ខោន





កិច្ចពិភាក្សារបស់ក្រុមគ្រូ

កិច្ចពិភាក្សាពិគ្រោះយោបល់






កិច្ចពិភាក្សា (១)លោក **ស៊ុំ ចាន់ធឿន** សមាជិកគណៈកម្មការ ស្រាវជ្រាវសិល្បៈវប្បធម៌ខ្មែរនៅក្រុមស្រាវជ្រាវរបស់នាយកសិល្បៈ

កិច្ចពិភាក្សា និងការស្តាប់ដោយយកចិត្តទុកដាក់របស់ យាយ តា ដែលជាស្ថាបនិកក្រុមល្ខោនវត្តកៀនស្វាយក្រៅ



**<u>កំណត់ចំណាំ:</u>** ល្ខោនពោលប្រុស ឬ ល្ខោនខោលរស់នៅក្នុងវត្ត មានពិធី (ដើរថ្វាយព្រះ) មុនចូលឆ្នាំ (ពិធីសំពះគ្រូប្រារព្ធធ្វើនៅថ្ងៃសៅរ៍) ។

-ល្ខោនពោលស្រីរាំថ្វាយព្រះក្នុងព្រះវិហាររៀងរាល់ថ្ងៃពេញបូរមី និងថ្ងៃខែដាច់ (ពិធីសំពះគ្រូធំធ្វើបានតែពីរដងក្នុងមួយឆ្នាំ គឺមុនថ្ងៃចូលឆ្នាំមួយថ្ងៃ និងថ្ងៃកោរមុនភ្ជុំបិណ្ឌមួយថ្ងៃ)

-ល្ខោនក្បាច់បុរាណ ល្ខោនព្រះរាជទ្រព្យសំពះគ្រូប្រារព្ធធ្វើនៅថ្ងៃ ព្រហស្បតិ៍ ។



**រៀបតាមរូបថត**

ធ្វើពិធីសំពះគ្រូធំ ឡើងគ្រូ ឬ ដំឡើងគ្រូ គឺធ្វើ (ពិធីថ្វាយខ្លួន)

**<u>កំណត់ចំណាំ:</u>** ចំពោះចរិត លោកយាយៗល្ខោនពោលស្រីទាំងអស់ពេលណាក៏ដោយ អោយតែមានក្រាំងល្ខោនពោលលោកយាយនៅចំពោះមុខ លោកយាយបត់ជើងថ្វាយបង្គំក្រាំងល្ខោនជានិច្ច ។

ក្បួនដំឡើងគ្រូកត់ត្រាដោយលោកតា (**ជា ដែក**) មុនពេលគាត់អនិច្ចកម្ម ទៅក្រោយឆ្នាំ១៩៧៩ (ចម្លងតាមសៀវភៅជាសំណៅដើមទាំងស្រុង) ភូមិធំ ចាប់សរសេរ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៧៩ ត្រូវនឹង ថ្ងៃ ៦កើត ខែពិសាខ [១] ។

## (ភ្លេង_ត្ញុំ)

អញខ្ញុំ លុតលើក ទសករ អញ្ជលី ថ្វាយវវន្ទា ទៀងទៅសម្តេច ព្រះព្រហ្មា ព្រះឥសូរ៉ា កោសី ព្រះវិស្ណុការ នៅព្រះពាយ បារមីសុសសាយ ព្រះមាតុលី ព្រះភ្លើង ព្រះភិរុណ ធរណី ទេវបុត្រ ចតុលោក ព្រះមេខលា ទាំងនាងឧមាភគវតី នាងឧមាវៃសច្ចាតា នៅអស់ព្រះស្រីកញ្ញា យើងខ្ញុំ នេះរៀបអស់ភោជនា នូវក្បាលជ្រូកមាន់ទា បាយសីផ្កាភ្ញី ទៀនធូបចំណី ខៅដក ដកម៉ែ ផ្កាលាឈៀនគិន ម៉ាកប្រាវយ៉ា ស្រាបាយយ៉ា ឡៅឡាន កម្សាន្តកាយ ក្សត្រាខុសឆ្គងម្តេចម្តា ក្តីណាតាមតែត្រង់មេត្តាប្រណី យើងខ្ញុំសឹងតែក្មេងសេចក្តីតាមតែប្រាណប្រោសប្រណីករុណា យើងខ្ញុំនេះហោង។

## (ភ្លេង_សាធុការ)

បពិត្រអើយ យើងខ្ញុំបង្គំវន្ទា សម្តេចនរនាថព្រះចក្រី ក្នុងផែនភពព្រះធរណី ឥតបីនរណានៅ ស្មើបាន ។ ខ្ញុំថ្វាយបង្គំទេវតា តូចធំសព្វឋានសោឡស សួគ៌ាវិមាន ជ្រោះជ្រងជ្រលងដងគីរី ទើបស្ថិតហេមពាន្តដ៏ពិធី សូមជ័យដ៏ប្រសិទ្ធី រំងាប់បំបាត់ចង្រៃ ។

សូមឈ្នះទុក្ខសោកសារពើ នៅរោគាភាភ័យគ្រប់ ទាំងសម្ភោរស្គរជ័យ ស្រឡៃបង្គំគ្រូរៀន ។ គ្រូខ្ញុំអ្នកតែងណែ ប្រាប់តាមដោយសណ្តាប់នៅរបៀនអោយ

........................................................................................................

(១)យើងចម្លងទាំងស្រុង នូវខ្លឹមសារតែកែអក្ខរាវិរុទ្ធឱ្យត្រឹមត្រូវតាមវចនានុក្រម ។

អស់ទាំងយើង ខ្ញុំរៀនគូសវាស ទម្លុះក្បាច់ ធ្លាក់ ។ ស្រេច ហើយយក ស្បែកព្រះគោ មកគូរកាត់ កាត់ជារូបព្រះឥសូរ ទ្រង់លាក្ខ គង់ក្អែន បីអាណាក់ អាណែកកណ្តាល គរវិហារ ព្រះអាទិត្យស្ថិតនៅបូព៌ា ព្រះច័ន្ទតីវ៉ា ភ្លឺជ្រះស្រឡះ តំពពក ។

ពោរពាសដេរដាស មីរមករូហាន បីរលក ក្រទាក្រតើន ខ្វែនស្ទាត់ ។

ពលភ្លើងឆេះតំពីមាត់ ខ្លះក៏គង់នីពាត់ ពើបពះ ប្រយុទ្ធឥតក្រែង ។

ពុំលង់ឡើយ ស្តេចក៏ទ្រង់ផ្លែងសព្រហ្មា យល់ស្តែង កើតក្លាយជាពលព្រះរាមា ។

## ភ្លេង ជើត ឈិង

យើងខ្ញុំសូមនិយាយរឿងរាមកេរ្តិ៍ គូសវាសសរសេរ ទម្លុះដាប់ធ្លាក់អស់សេចក្តី ធ្លាក់ជារូបនាង សីតា មហេសី នៅរូបព្រះលក្សណ៍ នរបតីគង់គាល់ចក្រីទាំងពីរពង្ស ។

គូរធ្លាក់ជារូប ជាអង្គ ជាពានពង្ស ជាកេរ្តិ៍ ជាយសព្រះរាម្នា ។ ដៃឆ្វេងខ្ញុំបង្គំរាធនា ដៃស្តាំខ្ញុំវន្ទា សម្តេចព្រះនារាយណ៍ អវតារ ។ រឿងនេះមិនជួជាតិសាមាន្យ មានមកអំពីបុរាណ កុំអ្នកទាំងឡាយនិន្ទា ។

ខ្ញុំសូមបង្គំព្រះឥសី សិទីជៃយ៉ា តេជះព្រះនារាយណ៍រាមា សូមសិទ្ធីពរគ្រប់អង្គ ។

## ភ្លេង ព្រាហ្មឡេងវ៉ាតាំងនី

**(តាំងនមោតស្សបីបទ)**

ឥតិ សិទ្ធី ចពុទ្ធំ សម្មាធិ
ឥតិ សិទ្ធី ចធម្មំ សម្មាធិ
ឥតិ សិទ្ធី ចសង្ឃំ សម្មាធិ
ឥតិ សិទ្ធី ចសីលំ សម្មាធិ
ឥតិ សិទ្ធី ចទានំ សម្មាធិ
បារមីតា រក្ខន្តុ សព្វទា ។

**(មន្តទឹកព្រោះ "ប្រស់")**

យើងខ្ញុំសូមបង្គំបាទព្រះសង្ឃ ភាវ៉ានាត្ត ព្រះភូមិទាំងដែនភព ព្រះធរណី ឥតអ្នកណាពីរនៅស្មើបាន ។ ស្ដេចគង់ឧសភរាជថ្មើងថ្កានអស់ទេវតាមានហិចហោះ ដង្ហែត្រៀបត្រា ខ្ញុំសូមបង្គំព្រះនារាយណ៍កាឡា ស្ដេច គង់គ្រុទ្ធា ក៏ជាជំនិះរីទ្ធីរុង ។

ខ្ញុំសូមបង្គំព្រះពិស្ណុការ ក៏កន្លងព្រះអង្គតែងរងផ្ទផ្ទង គឺត្រការទាំងសម្ពាយ ។ ខ្ញុំសូមបង្គំព្រះឥសី សិទ្ធិសឹងមានរីទ្ធីសែងសាយមហាឥសីទាំងឡាយ(១០៨)អង្គហោង ។ ទាំងឥសីអគ្គីនេត្រកន្លង ឥសីភ្លែក តោផងជាច្បងទាំងពីរអង្គារ ។

ខ្ញុំសូមអញ្ជើញ ទេពទសទេវា ទាំងឆកាមាសព្វឋាន ។ ទាំងអារក្ខសិទ្ធី ស័ក្តិម៉ឺនមានអ្នកស្ថិតដោយដាន ហេមពាន្ត សឹងសព្វបុព្វតា ។

ខ្ញុំសូមបង្គំ គ្រូល្បែងទាំងបី ល្ខោនយ័ន្តស្បែកក្តី សូមជ័យតេជះឥត ក្រែង ។ ខ្ញុំសូមបង្គំ ទាំងលោក គ្រូភ្លេងទាំងប្រាំ ជាក់ស្តែងស្រឡៃសម្ភោរ រនាត គង ។ សូម រម្ងាប់អស់ទាំងចង្រៃផង កុំអោយសៅហ្មង ទាំងអ្នក ក្រាបស្រីង្គារ ។ ទាំងអ្នកពំនោល ចែងចា ។ តាមក្បួនបុរា បុរាណទុក កេរវែងឆ្ងាយ ។ ប្រដាប់សម្រាប់ដាក់ថ្វាយ ទៀនធូបស្រាបាយ បង្អែមចង្អាប ឆ្វេង ស្តាំ ។ គ្រប់សព្វតាមដោយចំណាំដែល បុរាណចាំសរសេរកត់ទុកអោយមកមានទាំងដូងឡៅខោដក ធ្វើទុកអោយមកជ្រះចង្រៃ ស្រេចហោង ។ ស្រេចហើយអ្នកហៅបីដងឲ្យឮ គឹកកងភ្លេងផងប្រគំប្រគាល់ថ្វាយ ។

**(មន្តទឹកព្រោះ "ប្រស់")**

ឧកាស នមោបីហ្វំ សរណំ សីលំ ភវន្តុមេ

| | | | |
|---|---|---|---|
| ពុទ្ធំ | | | ទុតិយម្បិ |
| ធម្មំ | អារក្ខណំ ករោមិ | | |
| សង្ឃំ | | | តតិ យម្បិ |

អ្នកចម្លង **ឈាង ឆ៉ាត**

អ្នកផ្តើម **ខា ដែត**

## ៦. ពិធីសំពះគ្រូ ឬ ពិធីថ្វាយខ្លួន : *(ល្ខោនពោលស្រី)*

ក្រុមល្ខោនពោលស្រី មានរណ្តាប់ សម្រាប់សំពះគ្រូដូចមានក្នុងរូបថត

ក្រុមល្ខោនពោលស្រី រៀបចំពិធីសំពះគ្រូធំ ឬ (ពិធីថ្វាយខ្លួន) នៅពេលដែលសិស្សចាប់ផ្តើមហាត់ដំបូង ។ ធ្វើពិធីសំពះគ្រូធំរួចហើយ ទើប (យាយគ្រូ) ចាប់ផ្តើមបង្ហាត់ កាច់ក្បាច់ កាច់ដៃ កាច់ជើង សិស្សល្ខោន ។

### ពិធីសំពះគ្រូ ប្រចាំឆ្នាំ

ល្ខោនពោលស្រី រៀបចំសំពះគ្រូពីរដងក្នុងមួយឆ្នាំ ។ មួយថ្ងៃមុន ថ្ងៃចូលឆ្នាំ (ទោះបីត្រូវថ្ងៃកោរ ឬ មិនត្រូវថ្ងៃកោរក៏ដោយ) ។ ម្តងទៀតត្រូវ ថ្ងៃកោរ មុនថ្ងៃបុណ្យភ្ជុំបិណ្ឌ (ត្រូវនឹងថ្ងៃដាក់បិណ្ឌចុងក្រោយមុនថ្ងៃភ្ជុំ) ។

ឃើញថា ពិធីសំពះគ្រូល្ខោនពោលស្រី គឺខុសពីពិធីសំពះគ្រូល្ខោន ខោល គឺសំពះថ្ងៃសៅរ៍ សំពះគ្រូ ក្រុមល្ខោនព្រះរាជទ្រព្យ គឺសំពះថ្ងៃ ព្រហស្បតិ៍ ។

ពេលសំពះគ្រូធំរៀងរាល់ឆ្នាំ ដូច្នេះហើយពេលហាត់រឿងថ្មីបាន ឬ មុនពេលទៅសំដែងកន្លែងណា នោះគឺឥតមានសំពះគ្រូធំទៀតទេ គឺគ្រាន់តែរៀបចំល្អម១ប៉ុណ្ណោះ ពេលទៅដល់កន្លែងសំដែងដាក់ មាន់ស្ងោរ ស្រា ចេក ផ្លែឈើបន្តិចបន្តួចជាការស្រេច ។

## ៧. ឆាកសំដែង ល្ខោនពោលស្រី :

វាហាក់ដូចជាសាមញ្ញពន់ពេកណាស់ ចំពោះទីតាំងដែលជាឆាកសំដែងល្ខោនពោលស្រី អ្នកចាត់ចែងគ្រាន់តែរើសដី ឬ ទីទួលណាខ្ពស់ (ឬសង់រានខ្ពស់) ដូចជាខឿនព្រះវិហារ ហើយរៀបចំការសំដែងទៅជាការស្រេច ធ្វើយ៉ាងណាអោយតែទស្សនិកជនអាចមើលឃើញគ្រប់ទិសទី ។ វាំងននបាំងពីក្រោយបន្តិចទុកជាចំណាំឆាកចេញចូលឆ្វេងស្តាំ ។ កាលណាយើងនិយាយពីឆាកសំដែង វាមិនមែនជាខឿនព្រះវិហារ តែវាជាឆាកសំដែងសម្រាប់សំដែងល្ខោន ពេលណាខឿនព្រះវិហារ?

ពេលណាឆាកល្ខោន ?

## ៨. <u>ការតុបតែងលម្អឆាក</u> :

ពីដើមដល់ចប់ ឃើញមានតែកូនគ្រែមួយក្រាលកន្ទេលក្រហម ឬ សំពត់ស្អាតប៉ុណ្ណោះនៅជាប់នឹងរាំងននដែលគេខ្ចីពីព្រះសង្ឃ ឬ ឧបាសក ឧបាសិកា ចំណុះជើងវត្តយកមកចងបិទបាំងអោយមានមុខមានក្រោយតែប៉ុណ្ណោះ (គ្រែមួយនេះជានិមិត្តរូបទាំងអស់ វាំង រាជដំណាក់ ព្រៃព្រឹក្សា សមុទ្រ ទន្លេ ភ្នំ...)។ល។ តាមការសន្មត់របស់អ្នកពោល ឬ ពាក្យនិយាយ របស់តួសំដែង ។ គេក្រាលកន្ទេលខៀវ (កន្ទេលក្រហមវែង២) កុំអោយប្រឡាក់ខោអាវ ឬ មុតជើង ព្រោះសិល្បការិនីទាំងអស់ពេលសំដែងគឺជើង ទទេ ។

តួសំដែងទាំងអស់ ពេលសំដែងនៅក្នុងសាច់រឿង ត្រូវចេញពីឆ្វេងដៃចូលឆាកខាងស្តាំដៃ (នេះខាងឆ្វេងដៃ និង ខាងស្តាំដៃទស្សនិកជន តែសិល្បការិនីចេញមកសំដែងខាងស្តាំ សំដែងអស់សកម្មភាពតួខ្លួនគឺចូលទៅតាម (ទ្វារ) ឆ្វេងដៃរបស់ខ្លួនគ្រប់តួអង្គទាំងអស់) ។ គឺម្ខាងសម្រាប់ចេញសំដែង ហើយម្ខាងទៀតសម្រាប់ចូលវិញ មិនមានតួណាចេញចូលបញ្ច្រាសគ្នាទេ នេះជាក្រឹត្យក្រមដូនតា ។ (នេះក៏ជាចំណុចចាប់អារម្មណ៍ដែរ គឺ ទស្សនៈ (វិលកើត វិលស្លាប់) ។

ឆាកល្ខោនយើងមានតែគ្រែមួយប៉ុណ្ណោះ... ដូច្នេះក៏គ្មានអ្វីជាការតុបតែងលម្អដែរ យ៉ាងច្រើនបំផុតគឺគេបាំងហ៊ុំព័ទ្ធរាជវ័ធ (រនាំងប្រដើសឫស្សីជាក្រឡាច័ក្កច័នដើម្បីកុំអោយអ្នកមើលចូលទៅជិតអ្នកសំដែងពេក) ។

គេបិទបាំងកន្លែងណាមួយបន្តិចបន្តួច (ឬលើផ្ទះអ្នកស្រុក ឬ លើរានហាលកុដិលោក សម្រាប់តុបតែងខ្លួន កន្លែងយ៉ាងសមរម្យ) សម្រាប់ដេរសម្លៀកបំពាក់តុបតែងកាយ ។ ដើម្បីកុំអោយអ្នកមើលចូលទៅកៀកអ្នកសំដែង ព្រោះសុទ្ធតែជានារីភេទ (ក្រមុំ) ក្មេងកំលោះតែចូលទៅជិតជ្រើមខ្លាំងណាស់ ។ ខ្លះគេកាប់ស្លឹកដូងស្លឹកជ្រៃក្រឹមយកមកចងជារបៀបរោងបុណ្យសម្រាប់ប្រជារាស្ត្រខ្មែរធ្វើបុណ្យទាន គេ

កាត់ហែកផាងដូងយកទៅ ចងធ្វើជាក្លោងទ្វារសម្រាប់ចេញចូល ។

ឧទាហរណ៍: ថាជាព្រៃសម្រាប់សត្វស្វាបេះផ្លែឈើ (បញ្ហានេះទាក់ទងនឹងបច្ចេកទេសដឹកនាំរឿងតាមទម្រង់ល្ខោន) អ្វីដែលកើតមានមែនទែន តែបន្តិចបន្តួចប៉ុណ្ណោះ គឺគេឧបមាភាគច្រើន ។

## ៩. <u>ការបំភ្លឺភ្លើង</u> :

ល្ខោនពោលស្រី ជាទម្រង់ល្ខោនខ្មែរបុរាណដ៏មានចំណាស់ **យើងដឹង**ហើយថា ការបំភ្លឺភ្លើងដោយអំពូលភ្លើងអគ្គិសនី គឺសម័យស្រុកទេសរុងរឿងជឿនលឿន ។ តើយុគសម័យអង្គរគេបំពងសំឡេងយ៉ាងម៉េច? គេបំភ្លឺភ្លើងយ៉ាងម៉េច? ឬក៏មានវិទ្យាសាស្ត្របែបណាមួយដែលកប់បាត់ទៅតាមកាលសម័យ... ព្រោះប្រជារាស្ត្រខ្មែរសម័យសតវត្សរ៍ទី ១២ មានជាង ១២ លាននាក់ តើទីក្រុងអង្គរភ្លឺចិញ្ចែងចិញ្ចាចដោយវិធីណា?... យើងប្រមើលឃើញថា អ្វីដែលនាំអោយឆេះបានមិនរាលដាលដូចខ្លាញ់ត្រី ជ័រទឹកដាក់កម្ទេចឈើធ្វើទៅជាចន្លុះ គ្រាប់ធញ្ញជាតិមានគ្រាប់ល្ហុងខ្វង ល្ហុងខ្មែរ មានត្បូងបំភ្លឺរាត្រី បំភ្លឺដុត បំពួកភ្លើង ឬ ក៏សំដែងពេលថ្ងៃព្រោះលោក យាយៗដូចជាគ្មានចាប់អារម្មណ៍ពីបញ្ហាបំភ្លឺឆាកល្ខោននេះសោះ។ល។ គិតយ៉ាងណាដែលអាចនាំអោយមានជាពន្លឺ ក្រោយមកមានម៉ាំងសុង ជាចង្កៀងសប់ខ្យល់ប្រើដោយថាមពលប្រេងកាតមានប្រឆេះតាមបែបទំនើប (ឆេះហើយនៅប្រើបានទៀតមិនធ្លាក់ដាច់ភ្លាមៗដុតបី ឬ បួនយប់ ទើបដូរប្រឆេះថ្មី គេធ្វើបែបលក្ខណ:វិទ្យាសាស្ត្រ) ។

ការបំភ្លឺភ្លើងរបស់ទម្រង់ល្ខោនខ្មែរបុរាណ យើងមិនសូវឃើញមានទម្រង់ណាយកបច្ចេកទេស ភ្លើង **(Jeue de Lumière)** មិនរិះរកវិធីសំដែងភ្លើងអោយខ្លាំងលើសលប់ល្ខោនទេ (សោភ័ណសិល្ប:) គឺអោយតែភ្លឺមើលមុខឃើញគ្រប់តួពេញឆាកទៅជាការស្រេចគឺអោយតម្លៃទៅលើសាច់សិល្ប: សុទ្ធសាធ (ក្បាច់រាំសំឡេងច្រៀងរូបសម្ផស្សរបស់កូនណោងកូនឡាំ) ។

ចំណុចនេះហើយ ដែលចោទជាសំណួរថា តើសោភ័ណសិល្បៈ (មាន ឬ គ្មាន) បើក្បាច់រេរាំ នីមួយៗយូរៗដដែលៗហើយកាលណោះ យ៉ាងម៉េចបានជាមានទស្សនិកជនទ្រាំមើលទល់ភ្លឺបាន... បាទ ! ថាឥឡូវនេះ សម័យវិទ្យាសាស្ត្រគេទៅដល់លោកខែហើយបាទ... សុំធ្វើការវិវឌ្ឍ តែវិវត្តន៍នៅលើមូលដ្ឋានគ្រឹះជាខ្មែរ គឺមិនមែនជឿនលឿនជាបរទេសនោះទេ ។ អ្វីជាចំណែកមិនជឿនលឿនត្រូវធ្វើការ វិវត្តតែសោភ័ណនៅជាព្រលឹងខ្មែរ ។ ល្ខោនពោលស្រីករណីខ្លះគេរៀបចំសំដែង ពេលថ្ងៃគឺអង្គុយទស្សនាក្រោមពន្លឺថ្ងៃ ។

**<u>កំណត់ហេតុ</u> :**

ចំពោះទុព្វលសម្ភារៈ (សម្ភារៈកំប៉ិកកំប៉ុកក្នុងការសំដែង) គ្មានអ្វីជាដុំកំភួនគួរជាការកត់សម្គាល់ទេ ឧទាហរណ៍... ដំបងខ្លី (សម្រាប់ច្បាំងគ្នា) ធ្នូ, ព្រះខ័ន, ឈើច្រត់ យ៉ាងសាមញ្ញបំផុត យ៉ាងតិចបំផុត ដែលអាចដំណើរការសំដែងបានបំព្រួមបំផុត និម្មិតរូបបំផុត សោះនឹងអត់តែប៉ុណ្ណោះ ។

## ១០~ <u>ពិធីហោមរោងមុនការសំដែង</u> :

លក្ខណៈងាយស្រួលសាមញ្ញបំផុត... ក្រុមល្ខោនពោលស្រីត្រូវបានគេអញ្ជើញអោយទៅសំដែងនៅទីកន្លែងណាមួយ ឥតមានត្រូវរៀបរណ្តាប់ឡើងគ្រូអ្វីទាំងអស់ ព្រោះមួយឆ្នាំឡើងគ្រូតែពីរដង គឺពេលបុណ្យភ្ជុំបិណ្ឌមួយដង និងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិមួយដងទៀតជាការស្រេច ។ បើល្ខោនមានការសំដែងទៀតគឺមានតែផ្កាមួយថូ ចេកមួយស្និត មាន់ស្ងោរមួយ ស្រាមួយដប ផ្លែឈើបន្តិចបន្តួចមួយចានទៀត ហើយនឹងកំប៉ុងដើងធូប សម្រាប់សិល្បការិនី អុជទៀនដោតធូបសំពះរំលឹកគុណយាយគ្រូតែប៉ុណ្ណោះ ។ សិល្បការិនីរៀបចំខ្លួនហើយស្រេចទាំងអស់គ្នា ដោយមានយាយគ្រូៗនាំមុខសំពះបួងសួងដោតធូបហើយនាងៗក៏នាំគ្នាថយមកអង្គុយបត់ជើងស្ងៀមចាំជួយច្រៀងបន្ទរ នៅខាងឆ្វេងឆាកល្ខោនលើឆាក

សំដែង ។ (ពួកតា១ភ្លេងរៀបឧបករណ៍ភ្លេងនៅខាងស្តាំឆាក)... ។

ភ្លេងប្រគំកំដរឆាកល្ខោនរហូតមកដល់លោកយាយគ្រូបញ្ជាឆាកថា... ទៅ... ចប់សព្វគ្រប់ហើយ... ភ្លេងដូរលេងបទសាធុការមួយចប់ សិល្បការិនីទាំងអស់ថ្វាយបង្គំ "ក្រាំង" ថ្វាយបង្គំឆាកល្ខោន ៣ដង ហើយលើកដៃប្រណម្យសំពះលុះចប់ភ្លេង ។ ពិធីហោមរោងចប់សព្វគ្រប់ ដាក់ភ្លេងដើតបន្តិចអោយត្លុកចេញជម្រាបជូនរឿង ហើយល្ខោនក៏ចាប់សំដែងលំដាប់លំដោយតរៀងទៅ លុះរយៈពេលកំណត់ឈប់សំដែង ។

ចប់ភ្លេងសាធុការដាក់ដើតក៏បានដាក់បទកំប្លុកកំប្លែងអោយត្លុកទាំងពីរនាក់ចាក់ក្បាច់ឡកតាមចង្វាក់ភ្លេង មកនិយាយកំប្លុកកំប្លែងបន្តិចបន្តួច ហើយក៏សូមជូនរឿង... ដូចតទៅ ។ ផ្ទាំងទស្សនីយភាពក៏ចាប់ផ្តើមជាបន្តបន្ទាប់... ។

យើងដឹងហើយថា ល្ខោនពោលស្រី ដូច្នេះសិល្បការិនីសុទ្ធសឹងជានារីភេទទាំងអស់ ត្លុកពីរនាក់ហ្នឹងដែលជាបុរស ជាជើងកាងការពារក្រុម... សុទ្ធសឹងជាតា១ចេះក្បាច់គុណ មេដឹកនាំក្រុមល្ខោន យាយ **ជា មុត** ល្ខោនវត្តកៀនស្វាយក្រៅនេះប្តីអ្នកគ្រូ **ជិញ** "គេហៅគ្រូស្រី១" គាត់ហ្នឹងជាមេអ្នកលេង (អ្នកមែនទែនកាប់គឺកាប់) ជើងគុនដាវអ្នកណាមកឆាឆៅកូនស្រីប្រពន្ធគាត់ដេញកាប់គ្មានញញើតអ្នកណា... ៥នាក់ចូលគាត់មិនចុះទេបានគ្នាពីរនាក់តាគង់ជើងខ្លាំងដូចគ្នាគ្មានចេះញញើត... អ្នកភ្លេងសុទ្ធតែចាស់១ តា១ គ្មានកំលោះរញ៉េរញ៉ៃជាមួយក្រុមល្ខោនស្រីនេះទេ ព្រោះអ្នកស្រុកអ្នកភូមិគេទុកចិត្តទើបគេអោយកូនក្រមុំគេមកហាត់ ឧទាហរណ៍... ពេលទៅសំដែងនៅតំបន់មួយឈ្មោះស្រុក... រកាជ្រលឹង... អន្លង់ទ្រា... ព្រះម្លូ... ជាតំបន់ដាច់ស្រយាល (កាលណោះ) ព្រំប្រទល់ខេត្តកំពង់ចាម... ខេត្តព្រៃវែង និងខេត្តកណ្តាល ។

ល្ខោនពោលស្រី វត្តកៀនស្វាយក្រៅជិះកប៉ាល់ចេញពីមុខវត្តឧណ្ណាលោមទៅដល់ស្រុកស្រីសន្ធរ (ព្រែកពោធិ៍) ដេកផ្លូវមួយយប់ ម៉ោង១២ថ្ងៃត្រង់ មានរទេះគោចំនួន ១២គ្រឿងមកទទួលក្រុមសិល្បៈដាក់អីវ៉ាន់ខ្លះ ដើរតាមរទេះខ្លះ... (គ្រឿងភ្លេង និងសំពត់អាវ សម្ភារៈសំដែងបន្តិចបន្តួច) ម៉ោងជិត ១០យប់ ទៅដល់កន្លែង

បុណ្យវត្តមួយដែលគេធ្វើបុណ្យបញ្ចុះសីមា (ភ្លេចឈ្មោះវត្ត)កាលណោះស្រុកនេះជាស្រុកព្រៃនៅចុងស្រុកដាច់ស្រយាល ពួកទស្សនិកជនមកមើលល្ខោនសុទ្ធតែមានកាន់ដាវកាន់លំពែង (អួតដាក់គ្នាចង់សាកគ្នា) ការពារខ្លួនព្រោះកាលណោះស្រុកមានអសន្តិសុខ ។ សិល្បការិនីទាំងអស់ទៅដល់កន្លែង មិនមានពេលសម្រាកយកកម្លាំងទេ រៀបចំតែងខ្លួនសំដែងតែម្តង តាមពិតពួកល្ខោនអស់កម្លាំងណាស់សំដែងមិនបានទល់ភ្លឺ ចង់ឈប់តែម្ចាស់បុណ្យមិនអោយឈប់ ព្រោះមិនទាន់ភ្លឺអ្នកស្រុកបរទេះគោមកពីភូមិស្រុកឆ្ងាយៗទៅសម្រាកឯណា?... ពួកអ្នកលេងក្រវែលរោងល្ខោនតាៗ... អ្នកដឹកនាំក្រុមសម្រេចចិត្តសំដែងទល់ភ្លឺ... គេធ្វើរោងដូចរោងបុណ្យមានផ្ទើរ នាងៗសិល្បការិនីមិនហ៊ានទៅបត់ជើងតូចឆ្ងាយទេ (យើងនិយាយដូចកំប្លែង) ពួកកូនល្ខោនស្រីៗបត់ជើងតូចដោយតាៗឈរជុំវិញដូចស្រោក់ដៃគ្នាការពារកូនមាន់ដែលខ្លែងកំណាចបម្រុងឆាបយកទៅជាចំណី... ភ្លឺឡើងចប់ការសំដែងគេអោយទៅសម្រាកលើផ្ទះឈើមួយខ្ពស់ពីដី តាៗសម្រាន្តចំមាត់ជណ្តើរ... ។ អ្នកលេងបីនាក់លីដាវមកសុំកូនល្ខោនពានាក់មែន មានស្រួលឯណា...? គេថាសុំតួស្រីបីនាក់យកទៅរាំជូនលោកធំ តាៗប្រកែកថា គ្មានសន្យារបៀបនេះទេ អាបីនាក់មិនព្រមនៅរឹងឡើងជណ្តើរ តាៗភ្លេងលោតចុះដី ស្រីៗស្លៀកខោទាំងអស់គ្នាប្រុងប្រយ័ត្នពួកអ្នកលេងប្រុងឡើងចាប់កូនល្ខោនលីទាំងថ្ងៃ... ពេលនោះលេចមុខប្តីគ្រូស្រី និងតាគង់មកដល់ពួកវាដឹងថាគាត់ជាអ្នកមែនជើងខ្លាំង... ពួកអ្នកលេងវាយកែងហើយទាន... (ព័ត៏មានបានពីលោកតានៅជាគ្រូភ្លេងក្រុមល្ខោនវត្តគៀនស្វាយក្រៅ)។

ចំណុចនេះយើងធ្វើការវិភាគលើការថែរក្សាការពារក្រុម តើកើតមកពីឆន្ទៈស្មារតីមនសិការ ឬក៏មានអ្នកណាបង្ខិតបង្ខំក្នុងការថែរក្សាកេរដំណែលវប្បធម៏សិល្បៈប្រពៃណីជាតិខ្លួន ។ កូនល្ខោនអោយតែឮថាពេលហាត់ "ញ៉រខ្លួន" នៅផ្ទះមិនសុខទេ មកពីអ្វី ?

## ១១. ទិធីសាស្ត្រ និងមធ្យោបាយសំដែង (សមាធិ) :

បើពិនិត្យតាមរយៈក្បាច់រាំទាំងឡាយ ដែលមានសល់នៅជាមួយលោកយាយចាស់ៗ (លោកយាយ ជា មុត វរៈសិល្បការិនី លោកយាយ គិន យិន លោកយាយមាស ហួរ លោកយាយ សាន់ យឹន (ទទួលមរណៈភាពខែ ៩ ឆ្នាំ ២០០៣) លោកតា នៅ ជា គ្រូភ្លេងបុរាណដែលលោកតាលោកយាយទាំងអស់នេះអាយុពី ៧០ឆ្នាំ ខ្លះ៨០ឆ្នាំទៅហើយនោះ គាត់បានរៀនចេះចាំតពីរបីតំណមនុស្សទៅហើយ គឺគាត់នៅចាំទាំងចម្រៀង ទាំង ភ្លេង ទាំងក្បាច់ (ធ្វើក្រាប់ "អោយដៃ" តាមពាក្យពោល ពាក្យនិយាយ ឬ ពាក្យចម្រៀង) ប្រាកដច្បាស់ជាងនេះទៅទៀតពួកយាយៗមិនចេះអក្សរទេតែយាយនៅចាំពាក្យនិយាយ ពាក្យពោលពាក្យច្រៀងលំនាំរឿងដែលមាននៅក្នុងក្រាំងបន្សល់ទុកមកជិត២០០ឆ្នាំមកហើយនោះ ។

ល្ខោនពោលស្រី គឺជាល្ខោនក្បាច់ច្រៀងរាំ ហើយចាក់ជាក្រឡាចុះឡើងមើលមួយភ្លែតភ្លាមស្មានថាល្ខោនហ្លួង (ល្ខោនក្បាច់បុរាណរាំខុស) គឺវាភ្លូកៗជ្រាយៗមិនណែនមិនហាប់រាងបែបរហ័សរហួនមានធាតុមានលក្ខណៈជាមហាជន ។ យើងសង្កេតឃើញមានធាតុល្ខោនខោលខ្លះ (ពាក្យពោល) ធាតុល្ខោនហ្លួងខ្លះ (ច្រៀងជាពួកជូនកាយវិការអ្នករាំ) ដូចទម្រង់ល្ខោនច្រៀងរាំខ្មែរបុរាណដទៃទៀតដែរ ហើយនិយាយពីបំណងទៅមុខ និងពីសកម្មភាពកំពុងធ្វើមានការសំដែងមនោសញ្ចេតនា (តាមក្បាច់និងតាមទឹកមុខ) ច្បាំងគ្នាបែបល្ខោនបុរាណ មានរួ មានដើត មានលា មានស្នើ(ស្នឹ) មានឱត(អួត) (មានមនោសញ្ចេតនាសប្បាយពាក្យសំដីសប្បាយ និងក្បាច់រាំសប្បាយ) មិនមែនល្ខោនហ្លួងរាំខុសទេ គឺទម្រង់ល្ខោនពោលស្រី ។

ក្បាច់រាំចេញពីក្បាច់ឆាបញ្ចុះដូចគ្នា យាយៗក៏ហៅក្បាច់បាតក្បាច់ឆាបញ្ចុះដែរ តែវាមិនមែនជាក្បាច់ឆាបញ្ចុះរបស់ក្រុមល្ខោននៅព្រះបរមរាជវាំង វាដោយឡែកក្បាច់ឆាបញ្ចុះរបស់គាត់ ក្បាច់បាតយាយៗល្ខោនកៀនស្វាយ កូនសិស្សហាត់តែបីខែ អាចរាំជាសាច់រឿងបាន (នេះនិយាយចំពោះកូនសិស្សសាលាចំណេះទូទៅទាំង ៦ភូមិ របស់ភូមិធំដែលទៅរៀនអក្សរឯសាលាព្រឹកមកហាត់ល្ខោនពេលល្ងាច បើទៅ

រៀនអក្សរពេលល្ងាចមកហាត់ល្ខោនពេលព្រឹក) ។

យើងខ្ញុំអ្នកស្រាវជ្រាវបានផ្ទៀងផ្ទាត់ក្បាច់គ្នាសាកល្បងមើល ដោយអោយនាង ចិន្ត ច័ន្ទស៊ីដា សិស្សសាលាល្ខោនក្បាច់បុរាណនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាងមានចំណេះវិជ្ជាខាងសិល្បៈ របាំក្បាច់បុរាណរៀនជិតដល់ថ្នាក់ប្រឡងស្នាតកប័ត្រសិល្បៈទៅហើយ អោយនាងរាំធៀបជាមួយកូនសិស្សយាយៗក្នុងភ្លេងឆាបញ្ចុះតែមួយមិនដូចគ្នាទេតែស្រដៀងគ្នាបែរខុសគ្នា លើកជើង លើកដៃខុសគ្នាចំណុចខ្លះៗចប់មុនចប់ក្រោយគ្នាបន្តិចបន្តួចតែចេះតែទៅជាមួយគ្នាបាន ហាក់ច្រឡំគ្នាតែមួយចប់ហ្នឹង ។

ចំណុចនេះឯងហើយដែលលោក ពេជ្រ ទុំក្រវិល មានប្រសាសន៍ថា ល្ខោនពោលស្រី ជាកូនបង្កើតរបស់ល្ខោនព្រះរាជទ្រព្យ ហើយមានចរិតមហាជន (ប្រជារាស្ត្រ) ច្រើននៅក្នុងនោះ (រហ័សរហួនមិនសូវជានួនពេកទេ) ។



ពិធីបង្រៀនតាមបែបបុរាណ នូវក្បាច់គ្រឹះទាំងឡាយរបស់ល្ខោនពោលស្រីមុន និងឈានចូលទៅបង្ហាត់សាច់រឿង (តួយក្សបង្ហាត់ដោយលោកយាយ **គិន យិន**)

ក្រុមតួនាងបង្ហាត់ដោយលោកយាយ **មាស ហូ**





លោកយាយ **មាស ហូ** បង្ហាត់តួស្រី (តួនាង)

លោកយាយ **សាន់ យឺន** អតីតតួនាយរោង (តួប្រុស)
បង្ហាត់ក្មេងៗជំនាន់ក្រោយ





លោកយាយ គិន យិន កាលពី នៅក្មេងក៏បានហាត់តួយក្ស និង តួស្វា ក្នុងទម្រង់ល្ខោនពោលស្រី ចូរជ្ជេះលោកយាយទទួលភារៈកិច្ច បង្ហាត់តួយក្សផង និងតួស្វាផង



រូបទាំងនេះ គឺជាភាពមោះមុត ប្រកបដោយឆន្ទៈខ្ពស់ស្រួចស្រាល់ រវាងសិស្សក្មេងជំនាន់ក្រោយជា អ្នកហាត់ និងបំណងប៉ងប្រាថ្នា ខ្ពស់របស់លោកយាយចាស់ៗចង់ ឱ្យល្ខោនពោលស្រីរស់ឡើងវិញ



លោកយាយ **មាស ហូ**

ពត់រង្វង់ខ្នាតតួ (ក្រុមតួនាង)



លោកយាយ **ណាម**

បង្ហាត់ក្បាច់កាន់ដំបងច្បាំង

ក្នុងក្រុមតួយក្ស



យាយៗបានបែងចែកក្មេងៗ
ជាពីរក្រុម គឺក្រុមក្មួយតូចៗ
អាយុក្រោម១៨ឆ្នាំ



ក្រុមនាងៗអាយុពី
១៩ឆ្នាំឡើងទៅ



ពួកក្មួយៗអង្គុយ និងឈរ ហាត់ទៅតាមពួក តាមក្រុមតួ

-តួនាងដោយក្រុមនាង

-តួនាយរោងតាមក្រុម នាយរោង

-តួយក្សទៅតាមក្រុម តួយក្ស





ទាំងនេះក៏ជាវិន័យរបស់ក្រុម ល្ខោនពោលស្រី ផងដែរ ដើម្បីងាយស្រួលក្នុងការចាប់ បង្ហាត់ក្បាច់របស់យាយៗ





នាយកដ្ឋានសិល្បៈទស្សនីយភាពតែងបានបញ្ជូនអ្នកគ្រូរបស់ល្ខោនក្បាច់បុរាណ
ទៅថែបំប៉នលក្ខណៈបច្ចេកទេសរវាងល្ខោនក្បាច់បុរាណ និងល្ខោនពោលស្រី

(១)ប្រធានភូមិ (២)ប្រធានការិយាល័យវប្បធម៌ស្រុកកៀនស្វាយ
អញ្ជើញចុះជួយលើកទឹកចិត្តយាយៗគ្រូ និងក្មួយៗរៀនសូត្រ





ក្មួយៗសំដែងតួស្វាក្នុងរឿងជ័យសែន (តួស្វាក៏សំដែងដោយនារីភេទ)

កិច្ចពិភាក្សាពិគ្រោះយោបល់ក្រោយការបង្ហាត់បង្រៀនចប់ម្តងៗ
ពីក្រុមអ្នកគ្រូរបាំក្បាច់បុរាណនៅនាយកដ្ឋានសិល្បៈ





ការទស្សនាដើម្បីពិភាក្សា ធ្វើការប្រៀបធៀបរកឱ្យឃើញចំណុចខុសគ្នា និងចំណុចស្រដៀងគ្នារវាងទម្រង់ល្ខោនទាំងពីរ

ជាប្រពៃណីក្នុងក្រុមសិល្បៈគឺការប្តូរយោបល់ដើម្បីរកការជឿនលឿនរីកចម្រើនក្នុងការបែងចែកក្បាច់សម្រាប់ទម្រង់ល្ខោនពោលស្រី និងក្បាច់សម្រាប់ទម្រង់ល្ខោនក្បាច់បុរាណ





អ្នកនាងយកព័ត៏មាន
តំណាងខាង
វិទ្យុអាស៊ីសេរី ចុះស្រង់
ព័ត៏មានក្រុមសិល្បៈ
ល្ខោនពោលស្រី
វត្តកៀនស្វាយក្រៅ

លោក **ចិន្ត នាគ** ឆ្លើយសំណួរ និងជូនបទសម្ភាសន៍ដល់វិទ្យុអាស៊ីសេរី





កិច្ចពិភាក្សាស្រង់ព័ត៌មាន និងថតសំឡេងកិច្ចសម្ភាសន៍

ស្រង់ព័ត៌មានជា
សំឡេងផ្ទាល់ជាមួយ
សកម្មភាពសំដែង





លោកមេឃុំ ឃុំភូមិធំ (ស្រុកកៀនស្វាយ)
អានសារព័ត៌មានក្នុងស្រុកមួយ (កាសែតរស្មីកម្ពុជា)
ដែលមានចុះផ្សាយពីការកកើតរស់ឡើងវិញរបស់ទម្រង់ល្ខោនពោលស្រី
វត្តកៀនស្វាយក្រៅ



**យើងលើកឧទាហរណ៍ក្នុងការសំដែងរឿង មកបង្ហាញបន្តិចបន្តួច ដូចតទៅ:**

ត្លុក... សូមជូនរឿង "ជ័យ សែន" ដូចតទៅ :

**ឆាកទី ១**

**ភ្លេងស្មើ (ស្មឹ)** *(ជ័យសែនចេញ)*

ជ័យសែន : ...(និយាយ-មុននិយាយសំពះគោរពទស្សនិកជន) ខ្ញុំទ្រង់ព្រះនាមហៅថា ជ័យ សែន ថ្ងៃនេះខ្ញុំកាន់តែធំពេញវ័យហើយ គិតចង់លាព្រះមាតា ព្រះបិតា ទៅរៀនសិល្បវិជ្ជាការដើម្បីការពារព្រះបុរី (ភ្លេងព្រះមាតា ព្រះបិតាចេញ) ជ័យសែន... ច្រៀងបទព្រះសំង៉ា ដល់ហើយឱនកាយ ថ្វាយបង្គំ (ច្រៀងខ្លួនឯងព្រមទាំងដាក់ក្បាច់ទៅតាមពាក្យពេចន៍ទៀតផង) បិតាជាធំលើសិរសា ថាកូនសូមលាទៅរៀនសិល្បការសូមព្រះបិតាមេត្តាកូន ។

**(សាច់ភ្លេង)**

ជ័យសែន : ... (និយាយ) បុត្រសូមក្រាបថ្វាយបង្គំ ព្រះមាតាបិតា...

បិតាជ័យសែន : ... អើល្អហើយបុត្រ ថ្ងៃនេះតើបុត្រមានកិច្ចការយ៉ាងណាដែរដូចជាមានព្រះទ័យសប្បាយរីករាយម្ល៉េះបុត្រ...

ជ័យសែន : ... បពិត្រព្រះបិតា ព្រះមាតា បុត្រសូមឱនកាយថ្វាយបង្គំលាព្រះបិតាព្រះមាតាទៅរៀនសិល្បរិទ្ធិរុង ដើម្បីឆោមយុងការពារបុរី ។

ព្រះមាតា : ... នែ៎ ! បុត្រមាតាៗមិនអោយបុត្រទៅទេពីព្រោះបុត្រនៅក្មេងណាស់

ជ័យសែន : ... ក្រាបទូលព្រះមាតា បើមិនអោយទូលបង្គំទៅទេ... តើថ្ងៃក្រោយ បាននរណាការពារព្រះនគរក្រាបទូល...

បិតាជ័យសែន : ... អើ ! បុត្រ បើបិតាមាតាឃាត់បុត្រមិនព្រមទេទៅក៏ទៅចុះណាបុត្រ។

ជ័យសែន : ... បើអញ្ចឹងបុត្រសូមក្រាបថ្វាយបង្គំលាសិនហើយ...ព្រះបិតា ព្រះមាតា

បិតា+មាតា : ... អើ ! ទៅចុះអោយបានសុខ... ពោល (តួធ្វើកាយវិការគ្រាប់

តាមពាក្យពោល) ពីរក្សត្រកាត់ព្រះទ័យប្រតិពង្សទៅចុះឆោមយង់ អោយសិទ្ធី ។

**ភ្លេងឱត(អូត) (យំសោកបែកគ្នា)**

ពោល : ... កាលអើយកាលណោះអង្គព្រះជ័យសែនអរតេតពីរ បង្គំបិតុរង្គ អង្គជនី ឡើងជិះពាជីចរឈ្លាឈ្លៃ (ភ្លេងជើត) (ពាជីចេញ) (មាតាបិតាចូល ជ័យសែនសំដែងបន្ត)

ជ័យសែន : ... ឱ ! ខ្លួនខ្ញុំអើយ ខ្ញុំបានលាព្រះមាតាព្រះបិតាមកដល់ពាក់កណ្តាលព្រៃ ហើយមិនបានជួបនឹងលោកតាមុនីឥសីសោះ បើអញ្ចឹងខ្ញុំគិតរាប់ព្រៃកម្សាន្តកាយាសិន... ។ ច្រៀង... (បទរាយ) ឱ ! ដើមស្រឡៅខ្ពស់ស្រលូត ដើមទ្រាដុះគ្រួត លើខ្លុងត្បែង ណាគ្រីគគីរដុះម្នាក់ឯង តែខ្ញុំខំស្វែងរកឥសី... ។

ជ័យសែន : ... (និយាយ) ព្រះសុរិយាក្តៅខ្លាំងណាស់ ហើយខ្ញុំក្រឡេកទៅឃើញដើមជ្រៃមួយដើមធំសាខាណាស់ បើអញ្ចឹងខ្ញុំចូលទៅសម្រាកកាយសិន... យី ! ខ្ញុំឃើញសត្វព្រៃច្រើនណាស់ បើអញ្ចឹងខ្ញុំគិតចាប់សត្វព្រៃមកឆ្អើរចម្អែតផ្ទៃសិន... ។ (ជ័យសែនចូល)

**(ភ្លេងរូ)**

*(ចុងភ្លេងរូ យក្ស មហេសី និង បុត្រី ចេញ) (ភីលៀង ៤នាក់)*

នព្វវង្ស : ... (និយាយ) ទ្រង់ព្រះនាមនព្វវង្សពង្សធិបតី មហេសីនាមឈ្មោះសូផាណា បុត្រីនាមឈ្មោះ សាឡីបុប្ផ សោយរាជ្យនៅនគររតនាខ្ទី... ថ្ងៃនេះអផ្សុកក្នុងព្រះទ័យខ្លាំងណាស់ សូផាណាអូន បងសុំលាអូនទៅកម្សាន្តនៅក្នុងព្រៃបានមួយថ្ងៃអូន... សូផាណា... ព្រះពរព្រះស្វាមី សូមស្តេចយាងក្រាបទូល... !

នព្វវង្ស : ... បងលាអូនសិនហើយ... បិតាលាបុត្រីសិនហើយសាឡីបុប្ផបុត្រីបិតា

សូផាណា+សាឡីបុប្ផ: ... ព្រះពរ... ស្តេចយាងក្រាបទូល...

*(ភ្លេងក្រេវណៃ ដើត... សូជាណា សាឡីបុប្ផ ចូល...)*

*(នព្វវង្សមកមុខឆាក ជ័យសែន ចេញមកដេកលើគ្រែ)*

នព្វវង្ស : (ពោល)... ដល់ព្រៃដើរព្រោង ប្របជើងភ្នំ ត្រូវថ្ងៃចូលផ្ទំក្រោម ព្រឹក្សា ព្រះពាយរំភើយក្លិនមំសាដែលរាជកុមារឆ្អើរនោះណី ... (និយាយ) យី៎ះ ! ជំក្លិនអ្វីក៏ឈ្ងុយម្ល៉េះ ... ! (ពោល) ... ស្រក់ ទឹកមាត់ច្រោក ក្រោយឡើងមើលឃើញក្រោមម្លប់ឈើ ឆ្អើរសត្វព្រៃ យល់ទាំងកុមាររូបល្អមល្ហៃ ថាមានលាភជ័យថ្ងៃនេះណា៎ ... ។

នព្វវង្ស : ... ស៊ីសាច់ ស៊ីទាំងក្មេងនេះឯង ... យី ! មិនកើតទេអាត្មាអញ សេពមន្តវិជ្ជាការសណ្តំកុមារនេះអោយលង់លក់ទើបបាន ...។

*(ភ្លេងរូ ដើត) (នព្វវង្សចូលស៊ីសាច់) (កាយវិការក្បាច់)*

យី ! សាច់ឆ្អើរនេះឆ្ងាញ់ណាស់អាត្មាអញយកសាច់ពីរដុំនេះផ្ញើសូជាណា និង សាឡីបុប្ផអោយបានឆ្ងាញ់មាត់ផង ... ។

*(នព្វវង្សចូល) (ជ័យសែន ដឹងខ្លួនច្រៀងជាក្រុមជូនកាយវិការ)*

ចម្រៀងជាក្រុម : ... (បទប្រែប្រាណ) ស្តែងស្តេចប្រែប្រាណព្រះកាយា តើនចាក កាលណា បាត់ពុំឃើញ... (សាច់ភ្លេង ជ័យសែនរត់រកមើលសាច់ របស់ខ្លួន...) (ភ្លេងឱត)

ជ័យសែន : ... យី ! នរណាចិត្តហានក្លា លួចយកមំសាអាត្មាអញដូច្នេះ នេះ មកពីអាត្មាគ្មានរិទ្ធីចេស្តា(ជ័យសែនបួងសួង) ឱ! ព្រះឥន្ទ្រ ព្រះព្រហ្ម អើយ សូមលោកចុះមកជួយខ្ញុំម្ចាស់ភ័យខ្លាំងណាស់ (ជ័យសែនមក ដាក់ក្បាច់ឱតខាងមុខឆាក "ភ្លេងរូ" ព្រះឥន្ទ្រចេញ...)

*(បទផឹនប៉ាងឡាង)*

ចម្រៀងជាក្រុម : (ពោល) ...តេជះបុណ្យព្រះវិសេសសល់ក្តៅដល់ព្រះឥន្ទ្របើកទិព្វចក្ខុ ។

**(សាច់ភ្លេង)** *(និយាយ)*

ព្រះឥន្ទ្រ : ...ខ្លួនខ្ញុំជាព្រះឥន្ទ្រ ថ្ងៃនេះក្តៅអាសនៈខ្លាំងណាស់ បើអញ្ជើងខ្ញុំបើក

ទិព្វចក្ខុមើលទៅឋានកណ្ដាលមើល៍ តើមានរឿងអ្វីកើតឡើង ។

**(ភ្លេងរូ)** *(សំពះបង្វិលខ្លួន)*

ឥឡូវឃើញថា ព្រះរាជកុមារ ជ័យសែនកំពុងតែមានទុក្ខ ដូច្នេះខ្ញុំប្រញាប់ចុះទៅជួយសិន ។ ក៏ប៉ុន្តែខ្ញុំទៅជាព្រះឥន្ទ្រអញ្ជើងមិនកើតទេ ខ្ញុំត្រូវប្រែក្រឡាជាតាបស ដើម្បីយកបង្កាត់ពេជ្រ ខ្សែចងដីបងវាយទៅអោយជ័យសែនសិន ។ (ព្រះឥន្ទ្រដាក់ក្រណាត់ពានាពីលើ និងកាន់ឈើច្រត់) ។

**(ភ្លេងរូ+ជើត)**

ព្រះឥន្ទ្រ : ...នែ៎ ! ចៅៗស្គាល់តាទេចៅ តានឹងហើយជាព្រះឥន្ទ្រ ណាំចៅ... ។

ជ័យសែន : ... ចៅសូមថ្វាយបង្គំលោកតា

តាបស : ... អើ ! ល្អហើយចៅ (ពោល) ... ដល់ភ្លាមទ្រង់ហុចបង្កាត់ពេជ្រ ទោះយក្សធ្វើម្ដេចចៅកុំភ័យ បើយក្សអួតខ្លាំងតាំងជាញជ័យ មាសមែក្រលុកវាអោយទ្រមអោយបានការ ។ (ធ្វើកាយវិការតាមពាក្យពោល)

តាបស : ... បើអញ្ជើងតាលាសិនហើយណាចៅ ...។

ជ័យសែន : ... ករុណាលោកតា និមន្តលោកតា ...

**(ភ្លេងជើត)**

*(លោកតាចូល ជ័យសែនទៅម្ខាងឆាក កន្ទុយភ្លេងនព្វវង្ស ចេញ)*

ពោល... (បន្ថយភ្លេង...) អាសូរីពុំស្កប់ចិន្តាចូលដល់នគរហើយ កាលណារូតរះចូលក្នុងព្រឹក្សព្រៃ

**(ភ្លេងជើត)**

នព្វវង្ស : ... យី ! ម៉េចក៏បាត់កុមារនេះទៅណាអញ្ចេះ អាត្មាអញត្រឡប់មកវិញថានឹងចាប់កុមារនេះស៊ីទាំងស្រស់អោយឆ្ងាញ់មាត់តែម្ដង ។

ជ័យសែន : ... យើងនៅខាងណេះណាំ ក្រុងមារ នែ៎ ! ក្រុងមារឯងចិត្តសា

មានយ្យណាស់លួចបានមំសាយើងហើយឥឡូវតាមមករកស៊ីយើងទៀត ឬ ក្រុងមារ

*(ជ័យសែន និង នព្វវង្ស ច្រៀងតគ្នា)*

*(ក្រុមច្រៀងជូនតួដាក់ក្បាច់)*

វើយ១ ! ក្រុងមារចោរចិត្តសាមាន្យលួចប្លន់បំពានមិនគិតខ្លួនក្ស័យ... ។

...នែ៎ ! វើយកុមារ អ្នកឯងអាងអីថាយើងក្សិណក្ស័យដោយសារដៃឯង

**(សាច់ភ្លេង)**

ជ័យសែន : ... (និយាយ) បើអញ្ចឹង ឯងចូលមកចុះណា៎ ក្រុងមារ

*(ចឹត រ៉ូ) (ចូលច្បាំងគ្នា ជ័យសែនផ្សង)*

(ពោល)... ចង់អួតអានុភាពនិងកុមារ ស្ទុះឆ្លាចូលទៅដូចគេរីត បង្កាត់ពេជ្រគេចរួបជិត យក្សមិតគេចដោះអស់ប្រាជ្ញា...

*(ជ័យសែនប្រើសិល្ប៍បង្កាត់ពេជ្រចងនព្វវង្ស) (ភ្លេងឱត)*

ជ័យសែន : ... ម៉េចទៅក្រុងមារឯងសុខចិត្តចុះចាញ់យើងហើយឬនៅក្រុងមារ។

នព្វវង្ស : ... នែ៎ ! ម្នាលកុមារឱសូមចុះចាញ់តេជដៃកុមារឯងហើយណា៎ ...។

(ពោល)... គិតហើយត្រាស់ថាឱចាញ់ជាក់ សូមស្ម័គ្រទុកអ្នកជាកូនស្នេះ។

ជ័យសែន : ... បើក្រុងមារ ព្រមចុះចាញ់យើងហើយ មិនអីទេយើងទុកជីវិតអោយរស់តទៅទៀតណា៎ ... (បួងសួង) សូមបួងសួងដល់ព្រះឥន្ទ្រាធិរាជ្យ ដែលលោកបានប្រទានបង្កាត់ពេជ្រនឹងខ្សែចងដំបងវាយអោយខ្ញុំសូមអោយសេពមន្តវិជ្ជាការទៅកាលណា ស្រាយយក្សានេះដូចសេចក្តីប្រាថ្នា (ភ្លេងរូ) (នព្វវង្សរួចពីសិល្ប៍)

ពោល... (នព្វវង្សចូលថ្នមជ័យសែន) ព្រះព្រមចូលថ្នមហើយស្រាយដោះ យក្សាពរផ្ញើះហោះទៅរាជក្រុងក្រៃ ។

*(ភ្លេងជើត)*

## ចប់ឆាកទី១

**<u>កំណត់ចំណាំ</u>** : យើងធ្វើវិភាគលើខ្លឹមសារ ដើម្បីធ្វើការដឹកនាំរឿងបែបល្ខោនខ្មែរ ។

-ដំណើររឿងវិវឌ្ឍន៍

-ការសំដែង (ទឹកមុខ កាយវិការ) របស់សិល្បការិនី

-ទីតាំង និង បរិយាកាសឆាក

-ចម្រុះទៅដោយក្បាច់រាំ ច្រៀងទោល ច្រៀងជូន ពោល និយាយ...

-ល្ខោនច្រៀងរាំ មានចាក់ជាក្រឡា ។

បើតាមអ្នកស្រាវជ្រាវ យើងដឹងជាបណ្តោះអាសន្ន គឺដើមសម័យឧត្តុង្គ (១៦២២) ទម្រង់ល្ខោននេះ ចេញពីព្រះបរមរាជវាំង កោះឃ្លោក ទៅនៅជាមួយប្រជារាស្ត្រជិត ៤០០ឆ្នាំទៅហើយ (គិតមកដល់ឆ្នាំ ២០០០) ហើយអ្នកស្រុក (ប្រជាជន) ទូទាំងកម្ពុជា ២៤ខេត្តក្រុងស្គាល់ នឹងធ្លាប់បានទស្សនាល្ខោននេះតិចគ្នាណាស់ គឺមានតែប្រជាជនក្នុងចំណោមភូមិភាគព្ទសាន្ត របស់ទឹកដីខេត្តកណ្តាលប៉ុណ្ណោះដែលធ្លាប់ឮចាស់ៗនិយាយប្រាប់ ឬក៏ចាស់ៗ អាយុពី ៧០ឆ្នាំថ្លាយឡើងទៅទើបស្គាល់ល្ខោននេះ ព្រោះក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅដែលជាក្រុមល្ខោន នៅមានការសំដែងចុងក្រោយ ក្រុមដ៏ទៃទៀត រហូតមកដល់ទសវត្សន៍ទី ៦០ ទើបក្រុមលោកយាយជិញ (គ្រូស្រី) ឈប់លែងមានការសំដែង គឺជាង ៤០ឆ្នាំកន្លងមកហើយ រហូតមកដល់ថ្ងៃទី ១៣ ខែ ៥ ឆ្នាំ ១៩៩៨ ទើបមានការប្រារព្ធពិធីបើកបង្រៀនល្ខោនពោលស្រីឡើងវិញ នៅវត្តកៀនស្វាយក្រៅ ដោយការខិតខំរបស់ក្រុមស្រាវជ្រាវនាយកដ្ឋានសិល្បៈ ដឹកនាំការស្រាវជ្រាវដោយលោក **ចិន្ត នាគ** ជាស្ថាបនិកក្រុមល្ខោនពោលស្រី វត្តកៀនស្វាយក្រៅ នឹងដោយមានការគាំទ្រជាកម្លាំងកាយកម្លាំងសម្ភារៈ ទឹកព្រះទ័យព្រះភិក្ខុ **យន់ ចំរើនភក្តី** (ស្ថាបនិក) ។

ទម្រង់ល្ខោនពោលស្រី ជាមត៌ករបស់ដូនតាយើងមានសល់នៅតែក្នុងខេត្តកណ្តាលមួយគត់ក្នុង ២៤ខេត្តក្រុង។

## + បញ្ហាសមាធិរបស់ក្រុមល្ខោនពោលស្រី

រាល់ការសំដែងគ្រប់ទម្រង់ទាំងអស់ របស់ទម្រង់ល្ខោនខ្មែរបញ្ហាសមាធិជាបញ្ហាចម្បង ព្រោះសុទ្ធសឹងតែប្រើឧបមាណវិធីទាំងអស់ នៅលើឆាកដែលទទេស្អាតមានតែគ្រែមួយ ឧបមា : - ស្ថានលើ ស្ថានកណ្តាល ស្ថានក្រោម (នរក) សមុទ្រ ទន្លេ បឹង បួរ ព្រះរាជវាំង ព្រះរាជដំណាក់ សួនច្បារ ព្រៃភ្នំក្រំថ្ម។ល។ គឺតែមួយកន្លែងហ្នឹងសោះ តែដំណើររឿងចេះតែវិវឌ្ឍន៍ ទៅមុខមានសកម្មភាពប្រព្រឹត្តិទៅតាមនាដវិធី ការប៉ិនប្រសប់របស់សិល្បការិនីដែលដើរតួ នាំឱ្យទស្សនិកជនជក់អារម្មណ៍ ស្លុងតាមសាច់រឿងទៅជាមួយជីវិតតួដែលធ្វើសកម្មភាពលើឆាក។

ជាវិធីសាស្រ្ត ចិត្តសាស្រ្តបុរាណរបស់ដូនតាយើង ឧទាហរណ៍ : មិនឱ្យបោះនាឡិចូលខ្នុះអង្ករទេព្រោះអភ័ព្វខ្លួនកូនស្រី តាមពិតគាត់ខ្លាចបែកត្រឡោកបែកនាឡិ ដាក់ឱ្យចំកណ្តាលខ្នុះ (ឆ្នាំងធំដាក់អង្ករ) ទើបមិនអភ័ព្វខ្លួន។

វិធីថែរក្សា ក្រាំងល្ខោនពោលស្រី របស់គ្រួសារតាដែក យាយកុំក្រោយពីតាដែក អ្នកពោលដ៏ចំណានរបស់ក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅទៅ យាយកុំ ជាប្រពន្ធ បានថែរក្សាក្រាំងល្ខោនពោលដោយយកចិត្តទុកដាក់ ទឹកចិត្តស្រឡាញ់និងគោរពក្រាំងល្ខោនពោលជាទីបំផុត គឺគាត់យកទៅតម្កល់លើជើងពាន ដាក់លើកូនតុជាអាសនៈ ដែលតាំងរូបថតតាដែកគោរពបូជាចំពោះវិញ្ញាណក្ខ័ន្ធប្តីរបស់គាត់ ហើយគាត់បានប្រាប់កូនចៅរបស់គាត់ ដែលមិនមែនជាសិល្បការិនីថា អ្នកណាហ៊ានបើកសន្លឹកក្រាំងនេះមើលប្រយ័ត្នខ្វាក់ភ្នែក (កូនចៅគាត់ប្រាប់អ្នកស្រាវជ្រាវពេលដែលលោក **ចិន្ត នាគ** និង លោក **ពេជ្រ ទុំក្រវិល** ទៅរកផ្ទះតាដែកឃើញហើយមិនទាន់បានជួបយាយកុំ) នេះឯងហើយដែលយើងកំណត់បាននូវមនសិការស្នេហារតនមរតកដ៏កម្ររបស់ខ្មែរយើង ដែលក្រាំងល្ខោនបែបនេះ គ្មានពីរក្នុងដែនកម្ពុជារដ្ឋទាំងមូល ។ តើស្មារតីលោកយាយ កុំ មានកម្រិតណា? បើខ្លួនគាត់មិនមែនសិល្បការិនីផង សិល្បការិនីទាំងអស់ (យាយៗ) សុទ្ធតែថ្វាយបង្គំក្រាំងទាំងអស់គ្នា ។

ចំពោះក្រុមសិល្បៈល្ខោនពោលស្រី មានរឿងចម្លែកមួយថែមទៀត លោក

យាយ សាន់ យីន ដែលជាតួនាយរោង ហើយក៏ជាស្ថាបនិកក្រុមល្ខោនពោលស្រី វត្តកៀនស្វាយក្រៅលើកទី ២ មួយរូបក្នុងចំណោម ៧រូប ចាស់ៗជំនាន់គាត់ គាត់បាន អនិច្ចកម្មក្នុងខែ ៥ ឆ្នាំ ២០០០នេះ គាត់គ្មានឈឺអ្វីរ៉ាំរ៉ៃសោះ តែជីវភាពគ្រួសារ ជុនជាបពេក មានកូនកំលោះម្នាក់ឡប់ក៏មិនដឹងអី កូនស្រីមេម៉ាយម្នាក់ និងម្នាក់ទៀត មានប្តីជាកសិករក្រីក្រ គ្រួសារនេះកំសត់ណាស់ ជីកេរលោកយាយប្រវែងជាង១០០ម លក់ស៊ីរហូតនៅសល់តែទំហំប៉ុនកូនខ្ទម ៤មបួនជ្រុង មុនលោកយាយដាច់ខ្យល់ស្លាប់ អារម្មណ៍របស់គាត់នៅជាប់ជំពាក់ជាមួយក្រុមល្ខោន មិត្តភក្តិគាត់គ្រូល្ខោន និងក្បាច់ ល្ខោនរបស់គាត់ គាត់ប្រាប់កូនស្រីរបស់គាត់ (នាងមេម៉ាយ) ថាឱ្យយកក្បាលជ្រូក និងមាន់ស្ងោមួយ ទៅថ្វាយគ្រូល្ខោនរបស់គាត់ជាចុងក្រោយ... ពេលនោះគាត់លើក ដៃឡើងរាំទាំងខ្លួនប្រាណសម្រាន្តនៅលើកន្ទេលស្លកស្លឹង... រាំហើយដាក់ដៃចុះដង្ហើម ចុងក្រោយក៏រលត់ដំណាលគ្នានេះដែរ ។ គួរឱ្យសោកស្តាយលោកយាយ សាន់ យីន ពន់ពេកប្រមាណ លោកយាយបានលាមិត្តភក្តិគាត់ទាំងអស់គ្នាហើយ លាមិត្តភក្តិគាត់ ហើយលាយើងហើយ លាសិស្សតំណគាត់ ៧៥នាក់ ដែលហាត់រៀនជាមួយគាត់។

តើល្ខោនពោលស្រី គេសំដែងរបៀបណា គេធ្វើសមាធិដូចម្តេច? របៀបធ្វើ សមាធិ : សិល្បការិនី សុទ្ធសឹងជាក្រមុំព្រហ្មចារីយ៍ និងវ័យជំទង់តែមានប្តីនិងមានកូនគេ ឈប់សំដែងល្ខោនហើយ បើសំខាន់ណាស់ ឬបើស្រឡាញ់ណាស់រៀបអាពាហ៍ពិពាហ៍ ហើយមានកូនមួយគេឈប់ហើយ រឿងនេះសុទ្ធតែជារឿងពិបាក (ព្រាយល្ខោនកាន់) ព្រោះធ្វើពិធីថ្វាយខ្លួន ដល់ពេលហាត់ ឬ ឮស្គរទូងហើយ នៅផ្ទះមិនសុខទេទោះជាប់ រវល់កិច្ចការអ្វីក៏ដោយ (លោកយាយ យិន បានមានប្រសាសន៍ប្រាប់ខ្ញុំថា : មានកូន មួយទៅហើយ ពេលនោះនៅស្ទូងស្រូវឯស្រែសោះដល់ពេលម៉ោងហាត់... ឆក់បានតែ ក្រមារត់មកដល់រោងល្ខោនដោយមិនដឹងខ្លួន)... សុទ្ធតែជាកសិករក្រីក្រទីទ័លចុះហេតុ ដូចម្តេចក៏មកហាត់ល្ខោន មកសំដែងល្ខោន គ្មានប្រាក់ខែ ឬ រង្វាន់ខាន់ខៅអ្វីសោះ នោះ ចេះតែសិប់ងប់ងល់ជាមួយសិល្បៈទៅទៀត?... មូលហេតុអ្វី?... ថាវាស្រឡាញ់... តើក្រុមល្ខោនស្រីវិន័យប៉ុណ្ណា?... បើពាក្យចាស់លោកថាមានកូនក្រមុំដូចមានប្រហុក

មួយពាងដាក់មុខផ្ទះ ចុះក្រុមល្ខោនពោលស្រី មានចំនួនមនុស្សជិត ៣០នាក់ ស្អាតៗ លាបម្សៅតែងគ្រឿងទៅទៀត... អត់ទាស់... នេះហើយការពិបាកទៅណាទៅទាំងផ្ទាំង ព្រោះឆ្កែចចកវារង់ចាំឱកាស តែកូនចៀមបែកហ្វូងដាច់សង្វែងទេហ្នឹងអាលចាប់យកទៅធ្វើជាចំណី។

សូមអាធ្យាស្រ័យ មកដល់ចំណុចនេះយើងខ្ញុំអ្នករៀបរៀងអត្ថបទ សូមលើកយកករណី នាង អៀច សារ៉េត កូនសិស្សក្រុមល្ខោនពោលស្រី លើកទី២ ដែលមានឈ្មោះថាក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅនេះ មកជម្រាបជូនមិត្តអ្នកអានបន្តិច គឺនាងដើរតួយក្ស ហាត់តួយក្ស សំដែងក្នុងរឿងជ័យសែន នាងបានទៅចូលរួមសំដែងនៅឆាកអង្គរបុណ្យឆ្លងសហស្សខេត្តសៀមរាបដែរក្នុងវ័យ ១៧ឆ្នាំ នាងជាកូនកសិករ ក្រីក្របំផុតជាកូនកំព្រាតាំងពីតូចគ្មានបងប្អូន ឪពុកម្តាយស្លាប់ចោលតាំងពីនាងអាយុបាន ៥ឆ្នាំម្ល៉េះ រស់នៅជាមួយជីដូនចាស់ក្នុងកូនខ្ទមកំសត់... ជីដូនរបស់នាងធ្វើការអ្វីលែងកើតហើយ ព្រោះគាត់ចេះតែឈឺ... នាងរៀនបានចំណេះវិជ្ជាមិនចប់ថ្នាក់បឋមទេ ព្រោះនាងរវល់ទៅបេះត្រកួនជួយកាត់ជី បេះជីឱ្យអ្នកជិតខាងដើម្បីបានបាយ ឬ បបរហូបជាមួយជីដូននិងចៅ... ពីខ្ទមនាងមកសាលារៀន មានចម្ងាយ ៦គម នាងដើរទៅរៀនផង ត្រឡប់ទៅដាំបបរជូនជីដូននាងផង ដាំបបរទុកជូនជីដូននាងពិសាពេលថ្ងៃត្រង់ នាងទៅបេះជី ឬ ត្រកួនឱ្យគេ ហើយមកហាត់រាំទៀត... ខ្ញុំលើកឈ្មោះនាងមកជូនជាឧទាហរណ៍នេះព្រោះនាងមានទេពកោសល្យ ក្នុងការសំដែងជាសិស្សមួយរូបដែលចាប់យកក្បាច់បានពីយាយៗគ្រូក្នុងចំណោមសិស្សមិនច្រើនប៉ុន្មានដែលទទួលកេរក្បាច់របាំបានពីយាយៗ គ្រូនាងនោះ (ក្បាច់ល្ខោនពោលស្រីតែនួនពេកងាកមករកក្បាច់ល្ខោនហ្លួង គឺខុសចូលប្រឡំទម្រង់គ្នា...) គឺនាងមានការអំណត់កស៊ូមួយថ្ងៃៗ គឺរិលដូចកន្ទេះឡង់ ខ្លួននាងជួនកាលបានបាយលោកហូបឯវត្ត ឬ ហូបបាយផ្ទះយាយៗគ្រូ គាត់អាណិតស្រឡាញ់សិស្សគាត់ណាស់ នាងគ្មានសម្លៀកបំពាក់អ្វីជាថ្មីទេរហែកប៉ះមុខប៉ះក្រោយ អ្នកគ្រូ ប៉ែន សុខជា អាណិតទិញសម្លៀកបំពាក់ឱ្យនាង... ។

យើងពិនិត្យមើលវិធីការងារ ចាត់ចែងបែបផែនសំដែងរបស់ក្រុមល្ខោន ពោលស្រី សិល្បការិនីកូនល្ខោនត្រូវចេញមកអង្គុយក្នុងឆាកទាំងអស់គ្មានសល់ម្នាក់នៅខាងក្នុងទេ ដើម្បីសមាធិ... ផ្ចង់ស្មារតីដើម្បីច្រៀង ឬជួយបន្ទរគ្នា... ។ សិល្បការិនីអង្គុយជុំគ្នាទាំងអស់មុខគាត់ ងាយស្រួលការពារគ្នា ព្រោះកាលណោះ ឆ្នាំ១៩៣០ផ្ទាយប្រទេសជាតិស្ថិតក្នុងភាពអសន្តិសុខ មនុស្សកំលោះមិនបានទេ បើស្រឡាញ់នាងណាហើយចាប់លីទាំងកណ្តាលថ្ងៃត្រង់... ចំពោះតួកពីរនាក់ មិនបាច់ចាំចេញមកអង្គុយក្នុងឆាកទេអាចជាអ្នកការពារក្រុមល្ខោនដូចតា គង់ (តួកស្លាប់ក្នុងឆាក) តាពិន ប្តីអ្នកគ្រូស្រីសុទ្ធជាអ្នកមែន ដើរក្រវែលរោងល្ខោន ៧នាក់ទល់ ១នាក់ គ្មានបញ្ហាអាចរ៉ាប់រងបាន ។ (ខ្ញុំលើក ឧទាហរណ៍ជូន : ដូចក្រុមល្ខោនជាតិនៃប្រទេសកម្ពុជាដែរពេលកើតដំបូងដើរសំដែងតាមបណ្តាខេត្ត ក៏មានក្រុមសន្តិសុខ ពិសេសគឺលោក ហង្ស ជួនជាអ្នកការពារក្រុមល្ខោនដែរ... ឡើងសំដែងផងអស់តួចុះពីលើឆាកដើរក្រវែលការពារក្រុម)។

អង្គុយមុខឆាកតាមដានសាច់រឿងទាំងអស់គ្នា តើអារម្មណ៍អ្នកសំដែងវាមូលប៉ុណ្ណា? មិនតាមដានរឿងសំដែងខុស តែខុសហើយ មិនធម្មតាទេ គ្រូស្រី យាយគ្រូកាចណាស់មុខតែមូលភ្លៅ ទឹកភ្នែករហាមខុសរឿង រួចអារឿងទឹកភ្នែកហើយហ្នឹងប្រយ័ត្នទៀតតែឃើញធ្ងន់... ! មួលហើយមិនឱ្យយំ... តើគាត់ គ្រូស្រី កាចប៉ុណ្ណា...? នោះហើយ ជាវិន័យដែកវិន័យកងទ័ពអនុវត្តដោយភ្ញាក់រលឹកសមាធិដោយមិនមានគិតថាជាសមាធិរាល់ថ្ងៃរាល់ពេលទៅវាទៅជាទម្លាប់ធម្មជាតិ... គេងើបចេញទៅក្រោយវាំងនន ចូលមកសំដែង គេចេញទៅវិញតាមច្រកខ្លោងទ្វារឆ្វេងពេលអស់តួសំដែងគេចូលទៅអង្គុយកន្លែងដដែលវិញជួយច្រៀងជួយបន្ទរធម្មតា ។

តទៅនេះខ្ញុំសុំលើកយករបៀបសមាធិរបស់ទម្រង់ល្ខោន ២ គឺទម្រង់បែបប្រាកដនិយម (ល្ខោននិយាយ) និងទម្រង់ល្ខោន បែបអណ្តែតអណ្តូងនិយមប្រាកដនិយមខ្លះ (ល្ខោនបាសាក់) មកអធិប្បាយជាឧទាហរណ៍ខ្លះៗគ្រាន់ជាការប្រៀបធៀបជូនជាការពិចារណាដូចតទៅ :

ឧទាហរណ៍ : ទម្រង់ល្ខោននិយាយ អនុវត្តទ្រឹស្ដីចំណាំង ដើម្បីដំណើរការសំដែងជាសកម្មភាពគ្រប់តួទាំងអស់នៅក្នុងរឿង... សិល្បករទាំងឡាយត្រូវសំដែងកាយវិការឱ្យមានសច្ចៈភាព ដើម្បីតថភាពសង្គមលេចធ្លោឡើងក្នុងអង្គរឿង។ សិល្បករប្រើអព្ភន្តរញ្ញាណ (វិញ្ញាណទី ៦ គឺប្រើវិចារណញាណទៅក្ដោបក្ដាប់ព្រឹត្តិការណ៍ទាំងឡាយមកធ្វើជារឿងផ្ទាល់ខ្លួន) ដើម្បីឱ្យមានរំញោចក្នុងអារម្មណ៍មានផស្សៈមានរំជួលចិត្តរបស់តួ... ។ សំដែងដោយចិត្តរំភើបធ្វើឱ្យអ្នកផងរំភើបជាមួយ។

ល្ខោននិយាយ បរិយាកាសជាធំ សង្គមជាគ្រូ ការស្ងប់អារម្មណ៍ជាមាតាបង្កើតសិល្បៈ លែងអារម្មណ៍ឱ្យប្រមើលមើលទៅក្នុងតថភាពសង្គម ស្វែងរកតួដែលត្រូវត្រង់ត្រាប់យកមកសំដែង... ដំណាក់កាលនៃការតាំងសមាធិចិត្តមាន៥ដំណាក់កាល តាមទស្សនាទានលោក ចិន្ត នាគ ប្រមូលអារម្មណ៍ តាំងអារម្មណ៍ ផ្ដោតអារម្មណ៍ ចាប់អារម្មណ៍ ត្រួតពិនិត្យអារម្មណ៍ ស្រមោលតួបានលេច ប្រត្យក្សឡើងក្នុងអារម្មណ៍យើង ស្រមោលតួប្រមឹក ស្រវឹង ងល់ ១បានគ្របសណ្ឋិត បុគ្គល ក ក្នុងរឿងហ្នឹង ជាតួចឹមអ្នកប្រមឹកស្រវឹងស្រាវាយប្រពន្ធ... តួ ចឹម បានសណ្ឋិតបុគ្គល ក ទាំងចិត្ត (ចិត្តសាស្ត្រតួ) ទាំងកាយ (កាយវិការតួ) តែបុគ្គល ក គឺត្រូវមាននៅសល់ ១០ភាគរយ ឬ ៥ភាគរយ សម្រាប់ត្រួតពិនិត្យ តួ ចឹម ប្រមឹក កុំឱ្យវាយប្រពន្ធតួនាង ឃ មែនទែន គឺវាយក្នុងបច្ចេកទេសសិល្បៈ (បច្ចេកទេសល្ខោន) វាយឱ្យដូចមែនទែនតែក្នុងមិនមែន តែមិនមែនទែន គឺ (ប៉ិនប្រសប់ក្នុងការសំដែង) ព្រោះបុគ្គលនាង ឃ តថភាពក្នុងជីវិត នាងមិនមែនជាប្រពន្ធ បុគ្គល ក ឯណា? គឺដើរតួក្នុងរឿងជាសិល្បការិនីដែលមានសិល្បិ៍វិធីសំដែងខ្ពស់គ្មានអ្នកណាសំដែងល្អដូច។

ក្នុងការចូល តួ ចឹម នេះស៊ប់ទៅក្នុងបុគ្គល ក... បុគ្គល ក ជាចិត្តសាស្ត្រប្រលែងគ្រប់អារម្មណ៍ទាំងអស់ឱ្យទៅ តួ ចឹម សណ្ឋិតដោយដឹងខ្លួនក្នុងមិនដឹងខ្លួន។ តួ ចឹម បានសណ្ឋិតទាំងកាយវិការ ទាំងចិត្ត តែបុគ្គល ក ក៏មិនទៅណាឆ្ងាយពី តួ ចឹម ដែរគឺនៅមានបុគ្គល ក យ៉ាងតូចព្រាល១មួយត្រួតពិនិត្យសកម្មភាពរបស់ តួ ចឹម ខ្លាចវាមែនទែនវាយតួនាង ឃ ឱ្យស្លាប់ក្នុងសាច់រឿង តែបុគ្គលនាង ឃ ក៏ស្លាប់មែន

ទែនដែរមានល្ខោនឯណា? អព្ភន្តរញ្ញាណ គឺ វិញ្ញាណទី ៦ ឱ្យចំណាប់អារម្មណ៍ និង ស្តែងអារម្មណ៍ នាដកម្មកើតឡើង ស្តែងឆាកល្ខោន ឱ្យក្លាយជាពិភពលោកទាំងមូល សម្រាប់សិល្បករ សិល្បការិនី។ គឺបំភ្លេចអារម្មរណ៍តាំងអារម្មណ៍ ឱ្យទៅប្រមូល អារម្មណ៍របស់រូបកាយមួយទៀត ឱ្យចូលមកសណ្ឋិតក្នុងអារម្មណ៍ តាំងនៅក្នុង អារម្មណ៍ របស់យើងជាអ្នកសំដែង... ឋាមពល (ឋាមភាព) របស់អ្នកសំដែងជះ ចំហាយរកគ្នាទៅវិញទៅមកបង្កើតបានជាចក្រវាឡធាតុរួមមួយ (តួទាំងអស់សំដែងនៅលើ ឆាក) បង្កើតបានជា សោភ័ណ រវាងទស្សនិកជន និងក្រុមអ្នកសំដែងនៅលើឆាក។

**យើងសូមអធិប្បាយដោយត្រួសៗសូមអាធ្យាស្រ័យ**

តទៅនេះ យើងសូមអធិប្បាយអំពីវិធីសមាធិបែបល្ខោនបាសាក់មួយដែល ខ្ញុំបាទបានយល់ដឹងអំពីលោកគ្រូល្ខោនបាសាក់មួយរូបឈ្មោះ "តាល្ខោន" លោក សា រឿន ជាគ្រូដឹករឿងល្ខោនបាសាក់មួយរូបធ្លាប់សំដែងនៅក្នុង ក្រុមល្ខោន គីឡូម៉ែត្រលេខ ៦ មុនព្រឹត្តិការណ៍ឆ្នាំ ១៩៧០ គាត់បានទៅស្លាប់ចោលឆ្អឹង នៅសហករណ៍ភ្នំដិប្បតេយ្យ ក្នុងក្រុមទី ១០ ភូមិបឹងកន្ទួត (ហៅក្រុមបង សឹម) : ជាឈ្មោះនារីមេក្រុមមួយរូបក្នុង សម័យរបប ប៉ុល ពត ដែលអង្គការដាក់ទិសមកពីស្រុកលើ ស្រុកមិនដែលស្គាល់ ឡានមកកាន់ក្តាប់ប្រជាជនចំនួន ១០គ្រួសារ មានមនុស្សជិត ៤០នាក់ ស្លាប់ជិតអស់ពី ក្នុងក្រុម ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ។ សូមជម្រាបបញ្ជាក់ថាសហករណ៍ ភ្នំធិប្បតេយ្យពេលចុះពីរទេះភ្លើងប្រជាជន សារុបមានចំនួនជិត ៩ពាន់នាក់ ពេលរំដោះជិតបែក១៩៧៩ នៅសល់ប្រជាជនជាង ២០០០នាក់ ប៉ុណ្ណោះ...) ។ ប្រពន្ធគាត់ឈ្មោះបង រឿន ជាតួឯកស្រីដ៏មាន រូបឆោមស្រស់... សំឡេងពីរោះក្រអួន ក្រអៅ ។ នៅមុនពេលឈឺធ្ងន់ ដោយអត់បាយ បាក់កម្លាំងឈឺធ្ងន់ ៤ទៅ១០យប់ មុន ស្លាប់ តាល្ខោនគាត់សុំឱ្យប្រពន្ធគាត់ បង រឿន ច្រៀងបទបាសាក់ឱ្យគាត់ស្តាប់រាល់ យប់ (នេះជំនួសចាស់ៗឈឺធ្ងន់គេសូត្រធម៌ សូត្រកែវដាអោយស្តាប់) រហូតដល់យប់ មួយពាក់កណ្តាលអាធាត្រគាត់ដាច់ខ្យល់ស្លាប់ ចោលកូនប្រុសគាត់ម្នាក់មុខមាត់រាងរៅ ដូចគាត់បេះដាក់ជាមួយ បង រឿន កណ្តាលវាលវដ្តសង្សារដ៏ធំធេងនេះ... ។

និយាយចូលមករឿងសមាធិបែបល្ខោន បាសាក់ដែលគាត់បាននិយាយប្រាប់ខ្ញុំ យកមកចែកជូនប្អូនៗ សិល្បករល្ខោនបាសាក់ជំនាន់ក្រោយគ្រាន់ជាការពិចារណា គាត់ប្រាប់ខ្ញុំថា គាត់មានវិធីពិសេសម្យ៉ាងមុនសំដែង (គាត់ជាតួឯកប្រុសមួយរូបដែរតួកុមារ ឬគេហៅគាត់ថា តាកុមារៗ ! ... ល្ខោនបាសាក់មានហោមរោងច្រៀងមុនបើកឆាកកំដរបរិយាកាសដើម្បីឱ្យវាស្លុងទៅក្នុងសាច់រឿង (សំឡេងភ្លេង ស្គរទ្រហឹងអឹងអាប់ )... វិធីពិសេសរបស់គាត់ គឺគាត់ទំពារស្លឹកម្លូ ៤ ទៅ ១០ សន្លឹកឱ្យខ្ទេចហ្មត់ជីកស្រាមួយកូនពែងកាត់ស្លេស្មឡើងផិលស្លឹកមុខ... រួចហើយក៏ចេះតែដំណើរការសំដែងតរឿងទៅ...មានកាលមួយនោះគាត់ដឹករឿង (មោងសមោងខ្មៅ) អាមុខស និងអាមុខខ្មៅវាវាយគ្នាមិនឈប់សោះអស់ពីកាប់សាបមកដៃទល់ និងដៃវាយគ្នាទៅត្រូវគ្នាឈឺរៀងខ្លួនខឹងរៀងខ្លួនវៃគ្នាលែងចូលឆាក... គាត់ផ្លុំកញ្ចែបើកវាំងននព្រៃមួយទៀតទៅជួបតួមួយទៀត ចេញមកដាល់បំបែកអ្នកទាំងពីរទាល់តែគ្រាកចូលឆាករៀង១ខ្លួន ទើបគាត់ផ្លុំកញ្ចែ បិទឆាកកែសាច់រឿង តម្រូវបន្តសាច់រឿងតទៅមុខទៀត...។

តើចំណុចដូចខ្ញុំបាទជម្រាបជូននេះ អាចចាត់ជាការប្រមូលអារម្មណ៍ បែបមួយ (សមាធិ) ឬទេ?... សូមជួយពិចារណា?...

ចំណុចដែលមានលក្ខណៈពិសេសៗ ដែលខ្ញុំបាទចង់បញ្ជាក់ ជាឧទាហរណ៍ជាគម្លាតទាំង (១៦ ចំណុច) របស់ទស្សនាទានខ្ញុំបាទ (ទម្រង់ល្ខោនមួយខុសគ្នាទៅនឹងទម្រង់ល្ខោនមួយទៀតគឺមាន ១៦ចំណុច)

**+ របៀបសំដែង**

ល្ខោនពោលស្រីជាល្ខោនរាប់រឿង រាំច្រៀង ពោលនិងនិយាយ ចម្រុះគ្នាជាសម្ល កកូរបែបខ្មែរ ក្រុមភ្លេងពិណពាទ្យ ជាង ២៥០បទ យកមកប្រើក្នុងមនោសញ្ចេតនាតាមតម្រូវការរបស់គ្រូដឹករឿង (ល្ខោនពោលស្រីត្រូវការគ្រូឯកទេសតន្ត្រីបុរាណពិណពាទ្យ) មូលដ្ឋានចម្បងក្នុងរបៀបសំដែងល្ខោនពោលស្រី គឺ រាំ ក្បាច់រាំ មួយរយភាគរយ ភ្លេង ច្រៀងជូន ចិតសិបភាគរយ ច្រៀងខ្លួនឯង ដប់ភាគរយ

ពោល (គ្រូពោល) ដប់ភាគរយ និយាយខ្លួនឯង ដប់ភាគរយ ពេលកំពុងសំដែងមានករណីខ្លះចាត់ចេញជាក្រឡាររបាំដែរ។

ល្ខោន = ការសំដែងពាក្យសំដី + ការសំដែងកាយវិការ + តួ

**-ការសំដែងកាយវិការ**

រាំមានជំនាញជាសិល្បការិនី របាំ មានមូលដ្ឋានជាអ្នករាំ (ល្ខោនក្បាច់បុរាណ) តែមិនសូវជាន្ទួនដូចល្ខោនក្បាច់បុរាណពេកទេគឺ = វាភ្លូក២ជ្រាយ២សឹងតែយល់ច្រឡំថា: (អ្នករាំល្ខោនក្បាច់បុរាណខុស) ប៉ុន្តែគឺវាជ្រាយអញ្ចឹងភ្លូក២អញ្ចឹងមិនន្ទួនពេកទេ (តែវាល្អ) ស្រដៀងប្រហែល២គ្នា... មានក្បាច់ត្រាប់ **(mimer)** តាមពាក្យពោល ពាក្យច្រៀង មានក្បាច់ លោម លា ហៅ ចង់ ខិត(អួត)... ពាក្យបច្ចេកទេស ហៅតាមពាក្យល្ខោនក្បាច់បុរាណស្ទើរទាំងស្រុង បទភ្លេងប្រើឈ្មោះ បទភ្លេងពិណពាទ្យ ។

**-ការសំដែងពាក្យសំដី**

ពាក្យសំដីនិយាយ គឺនិយាយដោយគ្មានព្រាងទុកលក្ខណៈមហាជន(ក្នុងក្រាំងគ្មានកត់ត្រាពាក្យនិយាយទេ តែមានពាក្យសរសេរដាក់ថា : (...និយាយ...)... នេះក៏ជាបញ្ហាមួយក្នុងការថែរក្សាទម្រង់នេះដែរ បើគ្មានយាយ២នៅរស់ចេះចាំ... ពាក្យនិយាយ, ពាក្យច្រៀង... ក៏គ្មាន មានកត់ត្រាតែពាក្យពោល និង ដំណើររឿងដល់ត្រង់ចម្រៀងមានដាក់ឈ្មោះបទ... តែគ្មានពាក្យច្រៀង... ។

ពាក្យច្រៀង ទំនុកបទចម្រៀង ច្រៀងក្នុងរឿងមួយនេះហើយ ក៏អាចយកពាក្យដដែលហ្នឹងទៅច្រៀងក្នុងរឿងមួយផ្សេងទៀតដែរឱ្យតែស្ថានភាពបរិយាកាសដូចគ្នា ឧទាហរណ៍ : ដូចជាសិល្បករ ល្ខោនបាសាក់ដូច្នោះដែរ ស្ថានភាពដូចគ្នាច្រៀងបទដដែលហ្នឹងក៏បាន។

**-ការតុបតែងកាយតួអង្គ**

សំពត់អាវ សាវស្បៃ ក្បាំង មកុដ អលង្ការ។ល។ ក៏រឹតតែដូចល្ខោនក្បាច់បុរាណដែរ... (តែក្រុមមួយជាក្រុមល្ខោនព្រះរាជទ្រព្យ : ល្ខោនហ្លួង, មួយល្ខោនរាស្ត្រ...)

តើវាប្រណីត ឬមិនប្រណីតកម្រិតណា?

ល្ខោនពោលស្រី គ្មានសំដែងរឿងរាមកេរ្តិ៍ទេ យាយៗបានឱ្យព័ត៌មានថា តាំងពីគាត់ចេះចាំ ស្គាល់ក្រាំងនេះមក ឃើញមានសំដែងតែ ៧រឿងហ្នឹង... ។

រឿងទាំង ៧ នេះដែលចាស់ៗហៅថា (សាស្ត្រាល្បែង) ប្រហែលកើតមានឡើងក្នុងសម័យលង្វែកដូចជារឿង បញ្ញាសជាតកដែរ គឺក្រោយបែកមហានគរ...។

លក្ខណៈសម្គាល់... រឿងសម្គាល់ជារឿងបញ្ញាសជាតក ៥០ជាតិមុនព្រះពុទ្ធបានត្រាស់... អតីត, វត្តជេតពន, តួអង្គសរជាតិ, តួអង្គស្រីកន្សែសារពេជ្ជ, តួអង្គប្រុសពោធិសត្វ ។ល។

សាស្ត្រាល្បែង... ជារឿងព្រេងនិទានដ៏យូរលង់ណាស់មកហើយ... តួអង្គតែមានទុក្ខបញ្ហាចោទខ្លាំងស្រាយមិនរួចគឺមានអន្តរាគមន៍ទេវ...។ល។ (ព្រះឥន្ទ្រឬទេវតាជួយយកអាសា) គ្មានកាលកំណត់តែលក្ខណៈខ្មែរ... ជួនកាលអាចទាក់ទងប្រវត្តិជាតិ ភូមិសាស្ត្រ ទីតាំងខ្លះ (ប្រវត្តិភ្នំ...)

រឿងទាំង ៧ហ្នឹង ក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅសំដែង ៣ទៅ ៤យប់ ក្នុងមួយរឿងទើបចប់ គឺសំដែងបណ្តែតទៅតាមសាច់រឿងធម្មតា... គឺធម្មតា

<u>**កំណត់ចំណាំ**</u> : ទីកន្លែងដែលល្ខោនពោលស្រីធ្លាប់ទៅសំដែង ព្រែកអញ្ចាញ, តារ៉ុ, ព្រែកពោធិ៍, រកាជល្លីង, អន្លង់ទ្រា, ព្រះម្លូ, ឈើទាល, ក្តីតាកុយ, ពោធិមាស, វត្តដីឥដ្ឋ, តាឡិចជ្រោយជ្រៃ, វត្តស្វាយឧត្តម, វត្តទួលសាលា, វត្តត្នូន, ភ្នំពេញ, ទឹកល្អក់, ទួលទំពូង, អន្លង់រមៀត, ល្វា, ត្របែក, កអណ្តើក។

**-វង់តន្ត្រីប្រគំជាមួយការសំដែងល្ខោន**

វង់ភ្លេងពិណពាទ្យ ជាវង់តន្ត្រីដ៏មានចំណាស់ក្នុងចំណោមមត៌កបន្សល់មកពីអាណាចក្រខ្មែរ ។ បើយោលលើឯកសារប្រវត្តិសាស្ត្រ... រាជធានីខ្មែរដែលតាំងនៅទួលបាសាន្តក្រោយសម័យអង្គរ មានព្រះរាជា៨ព្រះអង្គគង់នៅរាជធានីទួលបាសាន្ត គឺព្រះពញាយ៉ាត, ព្រះស្រីសុគន្ធបទ...។ល។ ។ ល្ខោនពោលស្រីនេះជាមត៌កបន្សល់មកពីភាព រុងរឿងរបស់យុគសម័យអង្គរ។

ភ្លេងដែលជូនល្ខោនពោលស្រី គឺគេប្រើបទទាំងអស់របស់វង់ភ្លេងពិណពាទ្យ ទៅតាមតម្រូវការនៃមនោសញ្ចេតនារបស់តួទៅតាមសាច់រឿង។

អំពីទំនុកច្រៀង និងរបៀបរៀបចំចុងចួន, រៀបចំពាក្យ, រៀបចំពាក្យពេចន៍ នេះជាកិច្ចការឯកទេសរបស់លោកគ្រូចំរៀង... ប៉ុន្តែបើតាមការសង្កេតរបស់យើង ទំនុកចម្រៀងក្នុងល្ខោនពោលស្រី គឺជាទំនុក ដែលមាននិពន្ធជាស្រេចក្នុងបណ្ដារឿង ផ្សេងៗ ឱ្យតែបរិយាកាសឆាកដូចគ្នា គ្រូដឹកនាំរឿងឱ្យសិស្សលើកមកច្រៀងបទ ដដែលហ្នឹងក៏បាន ឧទាហរណ៍ : ដូចជាទំនុក ចម្រៀងល្ខោនបាសាក់អញ្ជើងដែរឱ្យតែ បរិយាកាសឆាកដូចគ្នា សិល្បករអាចលើក ទំនុកបទដដែលក្នុងរឿងណាមួយនោះមក ច្រៀងក៏បាន...

**ចំណាប់អារម្មណ៍**... តែទោះជាយ៉ាងណាក៏ដោយចំពោះទម្រង់ល្ខោនពោល ស្រី យើងចង់ហួងហែងការសំដែងតែក្នុង ៧រឿងដែលមានចារទុកក្នុងក្រាំងសិនកុំ ទាន់បន្ថែម។

**ប្រវត្តិក្រាំងល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ**...

ក្រាំងល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ ថែរក្សាដោយលោក យាយ (កុំ) ប្រពន្ធរបស់លោកតា ជា ដែក អ្នកពោលល្ខោន តពី តាប៉ុន (អ្នកពោលមុនតា ជា ដែក... ៣តំណមនុស្ស) អាយុក្រាំងនេះប្រមាណប្រហែលជាង២០០ឆ្នាំ មកហើយ...។

នេះជាក្រាំងល្ខោនបុរាណ ដែលសេសសល់តែមួយគត់ ក្នុងព្រះរាជាណាចក្រ កម្ពុជារហូតមកដល់ឆ្នាំ២០០១នេះស្ថិតនៅក្នុងឃុំភូមិធំវត្តកៀនស្វាយក្រៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

ក្រាំងនេះខ្ញុំ បាទសូមជម្រាបប្រវត្តិជូនដូចខាងក្រោម :

ក្រាំងនេះ គឺជាមរតកដ៏មានតម្លៃបំផុតក្នុងវិស័យវប្បធម៌ និង សិល្បៈរបស់ ប្រជាជនខេត្តកណ្ដាល (ការស្រាវជ្រាវល្ខោនបែបនេះមានតែក្នុងខេត្តកណ្ដាលមួយ គត់) ក៏ដូចជាប្រជាជនកម្ពុជាទូទាំងប្រទេស ។ ក្រាំងនេះស្ថិតក្នុងការគ្រប់គ្រង ថែរក្សាដោយលោកតា ជា ដែក អ្នកពោលចុងក្រោយមុនក្រុមល្ខោនពោលស្រីវត្ត

កៀនស្វាយក្រៅបាត់បង់ការសំដែង ។ ឆ្លងកាត់របបប្រល័យពូជសាសន៍ ប៉ុល ពត ក្រាំងនេះស្ថិតក្នុងការ តស៊ូស្ថិតស្ថាញបំផុតរបស់លោកតា ជា ដែក (លោកតា ជា ដែក អនិច្ចកម្ម ក្នុងឆ្នាំ ១៩៧៩ ក្រោយសម័យរំដោះ)។

តើក្រាំង និងម្ចាស់លោកតា ជា ដែក ភ័យតក់ស្លុតរន្ធត់យ៉ាងណា? ក្នុងកាលដែលឃើញពួកអាវខ្មៅប្រមូលគម្ពីរដីការ ក្បួនខ្នាត បុរមបុរាណ បំផ្លាញចោល (ដុតបំផ្លាញសាស្ត្រាស្លឹករឹត ជញ្ជូនគ្រវាត់ចោលក្នុងទឹកទន្លេ)... តា ជា ដែក សម្លឹងឃើញក្រាំងរបស់គាត់ភ័យញ័រចំប្រប់ ព្រឺស្រៀវញ័ររញ្ជួយ ស្រក់ទឹកភ្នែកហូរក្លាយជាស្ទឹងឈាម កាត់លង្វែកទ្រូងលោកតា... គាត់ឱបក្រាំងរបស់គាត់ដោយស្លុតវិញ្ញាណយ៉ាងតក្កមា កោលាហល ពួកអាវខ្មៅប្រមូលកម្ទេចគ្រឹះវប្បធម៌របស់ខ្មែរ... ក្នុងយប់ស្ងាត់កណ្តាលអាធ្រាត្រ នៃរាត្រីមួយផ្អែកខាងរនោច គ្មានពន្លឺព្រះច័ន្ទបំភ្លឺឡើយ បសចេកមានស្លឹកទ្រប់ទ្រល់ លោកតា ជា ដែក សម្លឹងទុកពីពេលថ្ងៃហើយស្រេច លុះដល់យាមកំណត់ ក្រោយពីលោកតាបានត្រៀមចបជីក, ថ្លាង និងក្រាំងបុរាណ រុំដោយសំពត់ស ខ្ចប់ដោយផ្ទាំងសំពត់កៅស៊ូយ៉ាងមធ្យ័តបំផុត... ឱលោកតា ដែកហើយ ! ... ជើងទទេគ្មានពាក់ស្បែកជើង... ដើរលបៗ កាត់បន្លាឫស្សី ក្នុងបសចេកដោយថ្នមជើង ខ្លាចឈ្លបអាវខ្មៅឮ ព្រោះលោកតា ដែក នឹងស្លាប់ភ្លាមមួយរំពេចដោយគាត់ប្រឆាំងបញ្ជាអង្គការ... ក្រោមពន្លឺតារារាប់ពាន់លានដួងបំភ្លឺរាត្រីរនោច លោកតាយកចបជីកឆ្កឹះដីសើៗ បានជារណ្តៅល្មមដាក់ថ្លាងមួយចុះ... ញើសហូរជោគខ្លួន ទាំងកណ្តាលរាត្រីត្រជាក់ល្ហឹម... ក្នុងដួងវិញ្ញាណ និងស្មារតីស្លុតរន្ធត់ លោកតាហាក់ដូចជាបញ្ចុះសពកូនប្រុសសំឡាញ់ដែលស្លាប់យ៉ាងអាថ៌កំបាំងយ៉ាងស្ងប់ស្ងាត់បំផុត ក្បែរគុម្ពឫស្សីមានខ្ពង់ទួលបន្តិច... លោកតាលប់ដី លោកតាកប់ថ្នមៗបេតិកភណ្ឌវប្បធម៌ (ក្រាំងល្ខោនពោល) ថ្លៃស្មើជីវិត ។ ... ៦ខែម្តង លោកតាទៅលួចគាស់ ថ្លាងលោកតា ដូរទឹកន្លែងហាលសន្លឹកក្រាំងដែលសើម ដោយអាកាសធាតុដោយរដូវភ្លៀងកណ្តាលបុសចេក... ក្នុងមនសិការ ទុកបង្ហាញកូនចៅជំនាន់ក្រោយរហូតដល់អ្នកស្រាវជ្រាវយើងបានឃើញក្នុងឆ្នាំ ១៩៩៤ នោះ ! ... ឱ ! លោកតា

ជា ដែក អើយ លោកតា ស៊ូប្តូរជីវិតសង្គ្រារដោយសារក្រាំងល្ខោន លោកតា ខ្ញុំអ្នកល្ខោនសូមជូនកម្រងផ្កា វរៈជនវប្បធម៌ចំពោះលោកតា ដែលលោកតាបានយកជីវិតទៅប្តូរជាមួយក្រាំងល្ខោនពោលនេះ... ។

**កំណត់ហេតុការណ៍សិក្សាស្រាវជ្រាវ និងការកកើតឡើងវិញ នូវល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ:**

ក្រោយពីទទួលព័ត៌មានថាមានក្រាំងល្ខោនខោលបុរាណមួយនៅ កៀនស្វាយ (មិនទាន់ច្បាស់លាស់)។

យើងសិល្បករ និង អ្នកទទួលខុសត្រូវ នៅនាយកដ្ឋានសិល្បៈទស្សនីយភាព នាំគ្នាចូលរួមបុណ្យសពលោកតា សៀង ស៊ុំ វរៈសិល្បករផ្នែកល្ខោនខោល ។ ខ្ញុំបាទ ចិន្ត នាគ និងលោក ពេជ្រ ទុំក្រវិល បាននិយាយជជែកគ្នា ស្រាវជ្រាវរកតម្រុយឯកសារល្ខោនខោលបំពេញឯកសារដែលលោក ពេជ្រ ទុំក្រវិល ទទួលព័ត៌មានបានរួចមកហើយ ។ យើងជជែកគ្នាលេងនៅផ្ទះតាប៉ែនដែលនៅទល់មុខផ្ទះតាស៊ុំ ។ ... តាប៉ែនយល់ព្រមជូនយើង ដើររកផ្ទះគេនៅកៀនស្វាយ... ដល់ថ្ងៃ និងដល់ម៉ោងកំណត់ ខ្ញុំ ចិន្ត នាគ ពេជ្រ ទុំក្រវិល អ្នកស្រី ម៉ិញ យុន និងព្រះអង្គម្ចាស់ក្សត្រី នរោត្តម បុប្ផានីហៅស្រីអូន (គ្រួសារលោកក្រវិល)... យើងជិះរថយន្តបើកបរដោយ លោក ឆុង ទៅចាំទទួលតាប៉ែននៅកំពង់ផ កោះប្រាក់ ចាំបាត់១ហួសម៉ោងកំណត់ហើយ មិនឃើញ... មេឃភ្លៀងរដូវវស្សា (ខែ ៨ ឆ្នាំ ១៩៩៤ ) ខ្ញុំចិន្ត នាគ និងលោកក្រវិល សម្រេចចិត្តពីរនាក់ដើរសួរអ្នកភូមិពេញភូមិ ពីវត្ត (មុនីសាគរ) វត្ត (វិចិត្តារាម)... ឡានបើកទៅមុខលែងរួចព្រោះទឹកលិចជង្ហុកជ្រៅពេកយើងឱ្យឡានដឹកស្រី១មកបើកលើថ្នល់កោស៊ូវិញ ជាមួយតាក្រវិលម្នារជើងខោលុយកក់សួរគេហូរហែរតាម ផងផ្លូវរហូតដល់ផ្ទះយាយ កុំ (ព្រោះសួរចំផ្ទះមួយនោះគេធ្វើបុណ្យមានមនុស្សច្រើនកុះករ...) ។ យើងទៅដល់ផ្ទះយាយ កុំ (គាត់ជាស្រីមេម៉ាយពីតា ជាដែក ដែលទទួលមរណភាពតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ)... ម៉ោងជាង១ថ្ងៃត្រង់ ។ ផ្ទះនៅខាងជើងវត្តកៀនស្វាយក្រៅបន្តិច មិនជួបយាយម្ចាស់ផ្ទះទេ ជួបចៅ២ ចៅ

យាយទទួលយើងយ៉ាងរាក់ទាក់ស្វាគមថាជាមួយ ដើររកផ្ទះសំណាក់ (ព្រោះម៉ុនេះគេរកស៊ីជួលគ្រែ ជួលផ្ទះ បន្ទប់សំណាក់ ឱ្យអ្នកដែលទៅកម្សាន្តរមនីយដ្ឋានវត្តកៀនស្វាយក្រៅ) បន្តិចឡានបើកដឹកស្រីៗពីរនាក់មកដល់គេក៏ហៅរាក់ទាក់ដាក់កៅអីអោយអង្គុយលេង... តាក្រវិលឱ្យក្មេងៗធ្វើបាយទឹកដាក់ទឹកក្រូចទឹកកក ស្រាបៀរគ្រឿងក្លែមពេញតុដើម្បីងាយស្រួលទាក់ទាញចិត្ត អោយគេនៅនិយាយរកពួកយើង ព្រោះមានក្មេងស្ទាវៗ ជាគូៗ ដែលនៅឯតូបប្រុបមាត់ទន្លេចេះតែហៅម្ហូប ម្តងយកស្រាម្តងយកទឹក ម្តងលើក... គេមមាញឹកណាស់ យើងដឹងថាផ្ទះហ្នឹងមានក្រាំង យើងសួមក្មួយៗ (ចៅយាយ) មើលតែនាងៗនិយាយថា បើកមិនបានទេខ្វាក់ភ្នែក ។ យាយនាងប្រាប់ថាអញ្ជឹង ។ ... តាក្រវិលឱ្យឡានទៅតាមយកយាយកុំពីវត្តមកថាមានភ្ញៀវមករក (គាត់ទៅជួយកាច់បាយសីយាយៗនៅឯវត្តឯណោះ) ។ ក្នុងចិត្តយើងទាំងពីរនាក់ត្រេកអរ ឥតឧបមាហាក់ដូចជាដើររើសបានកញ្ចប់ពេជ្រទាំងគ្រាប់ ។ ... លោកយាយអញ្ជើញដល់ យើងអញ្ជើញគាត់ សុំពិនិត្យមើលក្រាំងគាត់ប្រាប់ថាលោកក្មួយអើយ តាំងពីតាខ្ញុំស្លាប់ទៅ (តាអនិច្ចកម្មក្រោយឆ្នាំ១៩៧៩) ក្រាំងនេះគ្មានដែលអ្នកណាគេបើកមើលទេ កូនចៅក្នុងផ្ទះក៏មិនប៉ះពាល់ដែរ... ខ្ញុំសួរគាត់ថាមានតំណមយ៉ាងណាឬ ? បានជាក្មេងៗប្រាប់ថាមិនហ៊ានឱ្យបើកមើលទេខ្លាចខ្វាក់ភ្នែក... លោកយាយឆ្លើយថា : ថៃមិនគង់ទេក្មួយអើយ បើមិនថាអញ្ជឹង ។ ...ខ្ញុំឃើញគាត់តម្កល់ក្រាំងលើជើងស្រាពក៏មួយ មានក្រណាត់ក្រាល តាំងនៅលើកូនតុមានកំប៉ុងជើងធូបមុខរូបថត លោកតា ជា ដែក ជាប្តី ។ ពាក្យកំហិតលោកយាយមិនឱ្យក្មេងៗប៉ើងសន្លឹកមើលខ្លាចខ្វាក់ភ្នែកធ្វើអោយយើងទាំងពីរនាក់មើលមុខគ្នាហើយអារម្មណ៍យើងគិតវែងឆ្ងាយ ណាស់... ខ្ញុំជម្រាបលោកយាយថា លោយយាយនេះលោក (ខ្ញុំចង្អុលទៅ លោក ក្រវិល) អគ្គនាយកបច្ចេកទេសក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ... ឯចំណែកខ្ញុំ (ចិន្ត នាគ) ជាអនុប្រធាននាយកដ្ឋានទទួលបន្ទុកសិល្បៈទស្សនីយភាពទូទាំងប្រទេសសុទ្ធសឹងជាអ្នកជំនាញ អ្នកស្រឡាញ់ វប្បធម៌ព្រលឹងខ្មែរ ព្រលឹងជាតិ សុំលោកយាយកុំព្រួយរបស់នេះជាបេតិកភណ្ឌ ជារបស់បុរាណ

មានសេសសល់ដោយកម្រ បំផុតពួកខ្ញុំក៏ស្រឡាញ់ក្រាំងនេះខ្លាំងណាស់... ឃើញវិធីលោកយាយថែរក្សាក្រាំងនេះ វិសេសវិសាល ពួកខ្ញុំត្រេកអរឥតឧបមា ។ សួរនាំលោកយាយពីនេះ ពីនោះរហូត ដល់ម៉ោងជាងពារសៀល ទើបលាគាត់ត្រឡប់មកភ្នំពេញវិញ នាំយកក្រាំងមកធ្វើការសិក្សា... លោកយាយឱ្យព័ត៌មានថានេះជាក្រាំងល្ខោនស្រីៗ ដែលប្ដីគាត់ពោលកាលពីគាត់នៅរស់... មិនមែនជាក្រាំងល្ខោនពោលប្រុសៗសំដែងឯណា? ខ្ញុំ (យាយ) មិនមែនជាអ្នកល្ខោនទេ តែមានពួកល្ខោនគេចាស់ៗនៅសល់ ៥ ទៅ ៦ នាក់ដែរចំណុះជើងវត្តហ្នឹង ។ តាក្រុិលយកក្រាំងនេះមកភ្នំពេញ ថតចម្លងដោយត្រឹមត្រូវយើងក៏អញ្ជើញក្រាំងនេះឱ្យត្រឡប់ទៅផ្ទះកន្លែងដើមវិញ (យកទៅទុកវិញ) ។

**ការកិច្ចអ្នកទទួលបន្ទុកសិល្បៈល្ខោន នៅនាយកដ្ឋានសិល្បៈ ទស្សនីយភាពនៃក្រសួងវប្បធម៌ និង វិចិត្រ សិល្បៈ :**

ការខិតខំប្រឹងប្រែងព្យាយាម ដោយឆន្ទៈមោះមុតក្នុងស្មារតីថែរក្សាជំនាញមនសិការជំនាញ ស្រឡាញ់មរតកព្រលឹងខ្មែររក្សារការពារវប្បធម៌សិល្បៈប្រពៃណីល្ខោនជាពណ៌សម្បុររបស់ជាតិខ្លួន ប្រធានការិយាល័យស្រាវជ្រាវល្ខោន អ្នកទទួលខុសត្រូវល្ខោនយីកេ ល្ខោនបាសាក់ ល្ខោនមហោរី អ្នករបាំបុរាណ អ្នកភ្លេងបុរាណអ្នករបាំប្រពៃណី អ្នកចេះក្បាច់របាំ អ្នកយល់ កសាងក្រឡាវណ្ណកម្មរបាំ អ្នកភ្លេងបុរាណ (លោកតា កែវ សួន) សិល្បករ សិល្បការិនី ក្នុងទូទាំងផ្នែកល្ខោន (ប្រធាននាយកដ្ឋានរងល្ខោនទាំងមូល) មានមុខសញ្ញារៀងៗខ្លួន មានប្រធានបទស្រាវជ្រាវដោយឡែកក្នុងរួមស្រាវជ្រាវរួមក្នុងដោយឡែក នាំគ្នាសិក្សាគ្រប់ជ្រុងជ្រោយរកឱ្យឃើញសោភ័ណក្នុងក្បាច់របាំ រកឱ្យឃើញសោភ័ណក្នុងក្រឡារបាំ ភាពនួន និងភាពគ្រោតគ្រាត ភាពស្វាហាប់ ថាមភាពនៅក្នុងក្បាច់ ចុះបេសកកម្មដោយមានការចាត់តាំងពីនាយកដ្ឋានសិល្បៈ ទស្សនីយភាពជាក្រុម ជាបុគ្គលគ្នាច្រើន គ្នាតិច ដើម្បីស្រង់ព័ត៌មានពីប្រវត្តិ ពីចម្រៀង ពីភ្លេង ពីពាក្យសន្ទនា រកឃើញក្បាច់របាំ រកឱ្យឃើញគម្លាតពីល្ខោនក្បាច់បុរាណ និងល្ខោនពោលស្រី ដែលជាមត៌កវិសេសវិសាលកម្រលែបនេះ។

ពួកយើងបានព័ត៌មានពីលោកយាយ កុំ ប្រពន្ធតា ជា ដែក រៀងរាល់ថ្ងៃពេញបូរមី រៀងរាល់ថ្ងៃខែដាច់ជារៀងរាល់ខែខួបប្រាំងខួបវស្សា (ជាប់ជាប្រចាំ) ទោះបីមានភារៈកិច្ចរវល់លំបាកលំបិន ក្នុងកិច្ចការប្រកបរបររកទទួលទានលៀងជីពជន្ម យ៉ាងណាក៏ដោយ ក៏លោកយាយ ៦រូប លោកតាភ្លេងមួយរូប មករាំបាំថ្វាយទសបារមីព្រះអង្គក្នុងវត្តកៀនស្វាយក្រៅ (ថ្វាយរបាំថ្វាយភ្លេង) ជានិច្ចមិនដែលខាន ទោះបីលោកយាយ លោកតាអាយុពី ៧០ ទៅ ៨០ ឆ្នាំ ហើយក៏ដោយ (អត្ថបទសសេរក្នុងឆ្នាំ ២០០១) ក៏លោកយាយមករាំថ្វាយព្រះមិនដែលខានមួយសីលណាឡើយ... ពិសេសលោកយាយៗឧបាសិកាចំណុះជើងវត្តទាំងអស់បានជួយកាច់បាយសីគ្នា យាយខ្លះយកនេះយកនោះកំប៉ិចកំប៉ុកមកផ្សំគ្នា ខ្លះមានដើមចេក កូនចេក ស្លឹកចេក លាជចំអាបបង្អែម គម្រប់កិច្ចបូជាបារមីព្រះអង្គធំ សុំសេចក្ដីសុខចម្រើនសិរីសួស្ដីជ័យមង្គល រំលឹកគុណគ្រូល្ខោន ។

យើងនាំគ្នាចុះបេសកកម្ម ទៅវត្តកៀនស្វាយក្រៅចំនួនមនុស្សជាង២០នាក់ ក្នុងថ្ងៃពេញបូរមី ឃើញមានក្រុមភ្លេងលោកតានៅជា ឃើញយាយៗកំពុងរាំថ្វាយបារមីក្នុងព្រះវិហារវត្តកៀនស្វាយក្រៅ (ដោយគ្មានជូនពត៏មានជាមុន) ក្នុងឆ្នាំ ១៩៩៥ ឃើញជាក់ស្ដែង ។

យើងពិគ្រោះគ្នា យើងអរឥតឧបមា យើងដាក់ផែនការណ៍ យើងមានគោលការច្បាស់លាស់ ក្នុងការស្ដារទម្រង់ល្ខោនដ៏កម្រនេះ ឱ្យរស់ឡើងវិញ ទោះបីក្រសួងមិនមានប្រាក់កាស (លុយកាក់) ក្នុងការធ្វើផែនការស្រាវជ្រាវយ៉ាងណាក៏ដោយ សមាជិកយើងមានទឹកចិត្តអំណត់ តស៊ូ អត់ធ្មត់ ទាំងភ្លៀង ទាំងក្ដៅរងារ រលីមលុយភក់យ៉ាងណាក៏ដោយ (អ្នកស្រីម៉ិញ យុន ប្រធានការិយាល័យស្រាវជ្រាវល្ខោនបានទៅឃើញជីវភាពផ្ទាល់របស់លោយយាយជា មុត ពេលទឹកលេចភូមិ គាត់យកដីដាក់លើផ្ទះរៀបចង្ក្រាន ចៀននំឱ្យចៅគាត់ទូលលុយទឹកលក់យកប្រាក់ចិញ្ចឹមជីវិត)... ក៏ស្ពាយម៉ាញ៉េ ស្ពាយម៉ាស៊ីនថត ស្ពាយកាមេរ៉ាផ្ទាល់ខ្លួន (លោកជួប សុភាព អ្នកគ្រូ ម៉ិញ យុន អ្នកស្រី កាន់ សុវណ្ណី អ្នកស្រី ម៉េមស៊ីណារ៉េត លោក អាង គីមអ៊ីរ

លោកទាវ័ត្ត មុនិន្ទ (អ្នកថតរូបភាពស្លាប់ក្នុងឆ្នាំ១៩៩៨) ដែលអ្នករៀបរៀងអត្ថបទមិនអាចបំភ្លេចឈ្មោះអស់លោក លោកស្រី បានឡើយ អស់លោក លោកស្រី ជាស្ថាបនិកដំបូងបំផុត ក្នុងការស្រាវជ្រាវឃើញទម្រង់ល្ខោនពោលស្រីនេះ ។ ក្នុងការស្រង់ព័ត៌មានជាក់ស្តែង សេនាធិការល្ខោន នាយកដ្ឋានរង ទទួលបន្ទុកល្ខោន នាយកដ្ឋានសិល្បៈទស្សនីយភាព ប្រមូលឯកសារយក ជាការបានគ្រប់គ្រាន់ ឯកភាពជូនព័ត៌មានលោកប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព ស្នើសុំលោកយាយ ជា មុត តួនាយរោងឯកក្នុងក្រុមអាយុជាង៧០ឆ្នាំ សូមក្រសួងស្នើរាជរដ្ឋាភិបាលបំពាក់ជូនកិត្តិយសជា (វរៈសិល្បការិនី) មត៌ករស់សម្បត្តិវប្បធម៌មនុស្សជាតិ ដែលជាតិ ដែលមនុស្សជំនាន់ក្រោយត្រូវតែដឹងគុណបំភ្លេចមិនបានឆ្នាំ ១៩៩៦ ។

ពេលវេលាចេះតែកន្លងទៅមុខជានិច្ច ខ្ញុំបាទ ចិន្ត នាគ អាំង គឹមអីរ អ្នកគ្រូម៉ិញ យុន អ្នកស្រី កាន់ សុវណ្ណី អ្នកស្រី ប៉ែន សុខជា ប្រធានការិយាល័យរបាំបុរាណក្នុងស្មារតីព្យាយាម តស៊ូអត់ធ្មត់បំផុត ទោះមានរថយន្ត ឬម៉ូតូ ឬមួយជិះរថយន្តក្រុងគគីរកៀនស្វាយក្រៅក៏ដោយ ក៏យើងខ្ញុំទាំងអស់គ្នាមិនបោះបង់ ការងារនេះ ស្ទើររាល់ថ្ងៃរាល់អាទិត្យ រាល់ខែ រៀងរាល់ឆ្នាំ ពិភាក្សារិះរកវិធីការងារយ៉ាងដូចម្តេច ធ្វើឱ្យកើតដោយយើងគ្មានប្រាក់កាសចេញមុខជាអ្នកឧបត្ថម្ភក្រុមសិល្បៈបាន ។

យើងថ្វាយបង្គំព្រះសង្ឃ ព្រះចៅអធិការវត្ត ព្រះអង្គព្រះនាម សុខ រស់ (កាលណោះ ព្រះអង្គជរាអាពាធជាទម្ងន់ សុគត)... តែព្រះអង្គ ព្រះចៅអធិការលោកបានប្រគល់ភារកិច្ចនេះប្រគេន ព្រះភិក្ខុ យង់ ចំរើនភក្តី និងគណៈកម្មការអាចារ្យវត្ត ឱ្យទទួលរ៉ាប់រង់ភារកិច្ចនេះសម្រេចចាត់ការជំនួសព្រះសង្ឃព្រោះព្រះអង្គអាពាធ ក្រោយមកលោកក៏សុគត... យើងអញ្ជើញមេឃុំភូមិធំ យើងអញ្ជើញលោក ប៉ែន ញ៉ិល អនុប្រធានការិយាល័យវប្បធម៌ ស្រុកកៀនស្វាយ យើងសុំពិភាក្សាជាមួយលោក អ៊ុង ឆាន អនុប្រធានគណៈកម្មការស្រុកកៀនស្វាយ ទទួលបន្ទុកវិស័យវប្បធម៌ យើងជួបគណៈកម្មការអារចារ្យវត្ត (ដូចក្នុងរូប). ។

យើងសុំជួបលោកយាយលោកតាទាំង៧រូប (លោកតា នៅ ជា លោកយាយ ជា មុត លោកយាយ គិន យិន លោកយាយ មាស ហូ លោកយាយ សាន់ យីន លោកយាយ ញ៉ែម យីន និង លោកយាយ អ៊ូ ណម) មកជួបជុំគ្នា សម្រេចបង្កើតជាក្រុមល្ខោនសហគមន៍ ដោយយកទីតាំងឆាកល្ខោនចាស់ ដែលមានស្រាប់តាំងពីបុរមបុរាណមក (ជាប់សាលាឆាន់វត្តកៀនស្វាយក្រៅ) ជាទីកន្លែងហាត់រៀន ។

ព្រះភិក្ខុ យង់ ចំរើនភក្តី ព្រះអង្គឯកភាពជាមួយគណៈកម្មការអាចារ្យវត្ត ជួយឧបត្ថម្ភយាយៗគ្រូទីទ័លក្រខ្លាំងពេកជាអង្ករជាប្រាក់កាស ជួយចិញ្ចឹមយាយៗ (បណ្តោះអាសន្ន) អស់ប្រាក់ប្រហែល ៦០ ទៅ ៧០ ម៉ឺនរៀល គឺព្រះអង្គរំលែកពីប្រាក់កាសដែលតាអាចារ្យវត្តវែរអង្គាសបានជួយយាយៗឱ្យរឹងដើរឹងជើង ។

យើងប្រកាសរើសសិស្ស មានកុមារី នារីវ័យជំទង់មកពី ៦ភូមិ ក្នុង ឃុំភូមិធំ ចំនួន ១៦៥នាក់ កូនចៅអ្នកស្រុកចូលមកហាត់រៀន ។ នាយកដ្ឋានសិល្បៈទស្សនីយភាពបានបញ្ជូនអ្នកឯកទេសរបាំបុរាណមួយក្រុមចូលជួយយាយៗ ជួយជម្រើសនាងនេះត្រូវហាត់ជាតួនាយរោង នាងនេះត្រូវហាត់ជាតួនាង នាងនេះត្រូវហាត់ជាតួយក្ស នាងនេះត្រូវហាត់ជាតួស្វា នាងណារៀនសាលាចំណេះវិជ្ជាទូទៅព្រឹកមកហាត់ល្ងាចនាងណារៀនល្ងាចមកហាត់ពេលព្រឹក ។

រយៈពេលវេលាកន្លងទៅអស់ ៤ឆ្នាំ ក្នុងការធ្វើការសិក្សាស្រាវជ្រាវ និង រៀបចំគម្រោងការ ផែនការក្នុងការហាត់រៀនបន្តវេនពីជំនាន់មនុស្សចាស់ផ្ទេរមកឱ្យក្មេងៗជំនាន់ក្រោយ... ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៨ ជាថ្ងៃប្រារព្ធពិធីបើកវគ្គបង្រៀនល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ (ជាថ្ងៃធ្វើពិធីថ្វាយខ្លួនចំពោះគ្រូល្ខោន) ហើយប្រាក់កាសចំណាយក្នុងអង្គពិធីនេះ គឺព្រះសង្ឃសុខចិត្តរ៉ាប់រងចំណាយជាមួយគណៈកម្មការអាចារ្យវត្តមានម្ហូប បាយ ទឹក នំចំណី ទទួលទានប្រហែលចំនួនមនុស្សជិត ៣០០នាក់ មួយថ្ងៃវាល់ល្ងាចដោយមានលោកយាយៗយកអស់កម្លាំងកាយចិត្តក្នុងការសម្រេចផែនការធ្វើការជម្រើសសិស្សឱ្យចូលហាត់រៀនល្ខោននេះ ។




១៣-៥-១៩៩៨ ជាថ្ងៃកំណើត ២៣-៣-១៩៩៩ សិល្បៈល្ខោនពោលស្រី វត្តកៀនស្វាយក្រៅបានលេចចេញបង្កើតបានជាផ្ទាំងទស្សនីយភាពមួយមានរយៈពេល សំដែង២ម៉ោងនឹង៣០នាទី មានទាំងរបាំ មានទាំងសាច់រឿងជ័យសែន ១វគ្គ អាចទាក់ទាញអារម្មណ៍ទស្សនិកជនបាន





ព្រះភិក្ខុ យង់ ចំរើនភក្តី
ថ្លែងពុទ្ធដីកាស្វាគមន៍ភ្ញៀវដែលអញ្ជើញជាកិត្តិយសក្នុងឱកាសនេះ



ការប្រុងប្រៀបត្រៀមលក្ខណៈក្នុងការសំដែង (ឈុតឆាករបស់ទម្រង់ល្ខោនពោលស្រីប្រព្រឹត្តិឡើងនៅកណ្តាលវាលគឺភ្ញៀវអាចទស្សនាគ្រប់សព្វសកម្មភាពទាំងអស់ តើត្រង់ណាជារឿងល្ខោន? ត្រង់ណាជាវិន័យក្រុម? ត្រង់ណាជាចរិតរបស់តួទាំងឡាយរបស់ក្រុមល្ខោនពោលស្រី?



តើក្មួយណាអង្គុយទស្សនា? ក្មួយណាមួយជាអ្នកជួយច្រៀងបន្ទរ? អ្នកណាជាអ្នកសំដែងក្នុងរឿងខ្លះពេលនេះ គឺត្រូវតែស្ទឹងស្មាធតាមសាច់រឿងល្ខោនទាំងអស់

ក្នុងឱកាសនោះក៏មានអ្នកគ្រូៗខាងនាយកដ្ឋានសិល្បៈទស្សនីយភាពចុះជួយតាមដានសកម្មភាពក្នុងការសំដែងផងដែរ






(១)លោកហ្វ្រេតហ្វ្រាំបែរ បច្ចុប្បន្នប្រធានអង្គការក្រុមសិល្បៈអម្រឹតា ដែលបានខិតខំជួយផ្ដួចផ្ដើមឱ្យមានជាកម្មវិធីទស្សនីយភាពនេះឡើង

ការប្រព្រឹត្តិទៅរបស់សាច់រឿងជ័យសែនពេលដែលមិនទាន់មានការឧបត្ថម្ភ
(សិស្សប្រើសម្លៀកបំពាក់ផ្ទាល់ខ្លួន)






(១)លោកប្រៀតហ្រ៊ុំបែរ ដែលខ្ញុំបាទ ចិន្ត នាគ អ្នកនិពន្ធសៀវភៅល្ខោនពោលស្រី ដឹងគុណលោក និងអង្គការរបស់លោកជានិច្ច ព្រោះលោកនេះហើយបានជួយឧបត្ថម្ភការបោះពុម្ពសៀវភៅល្ខោនពោលស្រីនេះទុកជាមរតកសម្រាប់មនុស្សជាតិ សម្រាប់អ្នកស្រាវជ្រាវទៅថ្ងៃអនាគត





-ឯកឧត្តម នុត ណារ៉ាង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ឯកឧត្តម ប៉ែន យ៉េត រដ្ឋលេខាធិការ ចុះសាកសួរសុខទុក្ខ និង សំណេះសំណាល (ក្រោយពីបានហាត់រឿងជ័យសែនចប់បានមួយកម្មវិធី)

(១)លោកស្រី ម៉ិញ យុន ប្រធានការិយាល័យស្រាវជ្រាវល្ខោនអង្គភាព នាយកដ្ឋានសិល្បៈទស្សនីយភាព





ក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅដោយមានលោកប្រធានឃុំភូមិធំ,លោកប្រធានភូមិត្នោត ចូលរួមសំដែងនូវបដិសណ្ឋារកិច្ចចំពោះឯកឧត្តមថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានអញ្ជើញទៅឆ្លងរឿងជ័យសែន និងរបាំទាំងឡាយមុននឹងដាក់ផ្ទាំងទស្សនីយភាពនេះសំដែងជូនជាផ្លូវការចំពោះទស្សនិកជនជាសាធារណៈ ។ អ្នកភូមិចំណុះជើងវត្តកៀនស្វាយក្រៅរីករាយក្នុងចិត្តឥតឧបមា ដោយនៅក្នុងភូមិយើងឃុំយើងពេលនេះចាប់មានសិល្បៈល្ខោនពោលស្រីកេរដំណែលដូនតាយើងបានរស់រានមានជីវិតវិញហើយ





ភិក្ខុ យង់ ចំរើនភក្តី ថ្លែងសន្ទរកថា ស្វាគមន៍ ថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

(១)លោកយាយ គិន យិន ជាអ្នកចាត់ចែងដំណើរការ ឆាកឈុតល្ខោន ដែលសាច់រឿងកំពុងប្រព្រឹត្តិទៅ





ការទស្សនា និងតាមដានសាច់រឿងដោយព្រះទ័យទុកដាក់ជាទីបំផុត




នាដកម្មរបស់តួជ័យសែន
កំពុងតែស្តែងឡើងទៅតាម
ព្រលឹង នៃស្រមោលតួ
បញ្ចេញជាសកម្មភាព
នៅលើឆាកល្ខោន



ក្រោយពីបានទស្សនាចប់សព្វគ្រប់ឯកឧត្តមរដ្ឋមន្ត្រីបានធ្វើការសំណេះសំណាលថ្លែង
វាចាផ្តាំផ្ញើទៅតាមពួក តាមក្រុមរបស់ល្ខោនពោលស្រី

ការផ្តាំផ្ញើចំពោះយាយៗ គ្រូចាស់ៗ





សំណេះសំណាលចំពោះក្មួយតូចៗ ដែលមិនទាន់ចេះសំដែង

សំណេះសំណាលចំពោះនាងៗក្មួយធំៗដែលជាអ្នកសំដែង
រឿងជ័យសែនជូន ឯកឧត្តមរដ្ឋមន្ត្រីទស្សនា





ការសំណេះសំណាលផ្តាំផ្ញើ
ជារួម សូមលោកយាយ
លោកតា ក្មួយៗទាំងអស់ថែ
រក្សាក្រុមល្ខោននេះឱ្យបាន
គង់វង្សជារៀងរហូតទៅ





ឯកភាពទស្សនៈឯកភាពសកម្មភាព លោកយាយៗប្រឹងបង្ហាត់ក្បាច់បាត សិស្សណាចេះចាប់ក្បាច់បានរហ័សបង្ហាត់ក្បាច់បាតបណ្ដើរ បង្ហាត់រឿងបណ្ដើរ... លោកយាយរើសពួកនាងធំៗដោយឡែកបង្ហាត់ឈុតលំដាប់លំដោយក្នុងរឿង (ជ័យសែន) បណ្ដើរ (លោកយាយ ជា មុត លោកយាយបានមានប្រសាសន៍ ល្ខោនស្រី លោកយាយ តែកូនសិស្សចេះក្បាច់បាតហើយ រឿងដែលបង្ហាត់ឱ្យហាត់រៀនរឿងមុនគេ គឺរឿងជ័យសែនហ្នឹងឯង បើចេះរឿងជ័យសែនងាយស្រួលសម្រាប់ហាត់រឿងក្រោយៗទៀត)... ដែលជារឿងមាននៅក្នុងក្រាំងបុរាណជូនតារបស់លោកយាយ (លក្ខណៈពិសេស លោកយាយ លោកតា ទាំងអស់សុទ្ធតែនាំគ្នាថ្វាយបង្គំក្រាំងលោកយាយ ហាត់ដូចជាថ្វាយបង្គំលោកយាយ គ្រូលោកយាយនៅចំពោះមុខ) លោកយាយៗមិនចេះអក្សរខ្មែរទេ តែលោកយាយចាំពាក្យពេចន៍ក្នុងក្រាំងមិនសូវចន្លោះឃ្លាទេ ពិសេសគឺលោក យាយ គិន យិន តួយក្ស តួស្វា ។

ព្រះភិក្ខុ យង់ ចំរើនភក្តី លោកប្រឹងប្រែងជួយល្ខោនរហូតមកដល់ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៨ ឯកឧត្តម នុត ណារាំង ឯកឧត្តម ប៉ែន យ៉េត រដ្ឋលេខាធិការថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញចូលរួមទស្សនាលើកទឹកចិត្តអ្នកខិតខំតស៊ូលើកស្ទួយរក្សាវប្បធម៌ប្រពៃណីជាតិដោយមានអញ្ជើញចូលរួមដោយប្រធានមន្ទីរវប្បធម៌ខេត្តកណ្ដាល លោក សុខ អឿន លោក អ៊ុង ឆាន អនុគណៈកម្មការស្រុកកៀនស្វាយផងដែរ ។

ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៩ ដោយមានតំណាងគណៈប្រតិភូសិល្បៈ **U.N.E.S.C.O** អញ្ជើញទៅទស្សនាដើម្បីជួយស្វែងរកជំនួយឧបត្ថម្ភក្នុងការសំដែង កាសែតរស្មីកម្ពុជា ទូរទស្សន៍ជាតិ **Rendez vous** វិទ្យុអាស៊ីសេរី ជួបធ្វើកិច្ចសម្ភាសន៍ផ្សព្វផ្សាយក្នុងជាតិ និងក្នុងអន្តរជាតិរហូតមកដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩ អង្គការក្រៅរដ្ឋាភិបាលអូស្ត្រាលីសង្គ្រោះកុមារកម្ពុជា **SAVE THE CHILDREN** នៅក្នុងការងារ បូកសរុបលទ្ធផលប្រចាំឆ្នាំ ១៩៩៨-១៩៩៩ របស់ខ្លួនបានឧបត្ថម្ភក្នុងការសំដែង ២លើក ចំនួនទឹកប្រាក់ ២.៥០០ ដុល្លារ ។ គឺសំដែងជូនក្នុងពេលប្រារព្ធ

ពិធីមួយលើក និងមួយលើកទៀតនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៩ នៅសាលសន្និសីទចតុម្មុខ ជូនសាធារណជនទស្សនាដោយនាយកដ្ឋានសិល្បៈទស្សនីយភាពធ្វើលិខិតអញ្ជើញ ។ ដោយសារការខិតខំព្យាយាមដោយមិនចេះនឿយណាយល្ខោនពោលស្រីវត្តកៀនស្វាយក្រៅបាន ចូលរួមក្នុងបុណ្យចម្រើនព្រះជន្មវស្សា សម្តេចព្រះនរោត្តមសីហនុ ក្នុងឆ្នាំ ១៩៩៩ នៅសាលាគរុកោសល្យខេត្តកណ្តាល ចូលរួមដោយឯកឧត្តមទេព ននរី អភិបាលខេត្តកណ្តាល និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិប៉ាណារ៉ាស៊ិរីវុឌ្ឍ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាពិសេសបានចូលរួមសំដែងជាផ្លូវការតំណាងជួសមុខក្រុម សិល្បៈខេត្តកណ្តាល ដែលកាលណោះក្រសួងវប្បធម៌អញ្ជើញចូលរួមការសំដែងតំណាងទូទាំងប្រទេសមាន ៥ ខេត្តគឺ ៖

១ - ខេត្តកណ្តាល

២ - ខេត្តស្វាយរៀង

៣ - ខេត្តកំពង់ស្ពឺ

៤ - ខេត្តពោធិសាត់

៥ - ខេត្តសៀមរាប

ក្នុងបុណ្យឆ្លងសហស្សវត្សរ៍លើវេទិកា (ឆាក) មុខប្រាសាទអង្គរវត្ត នៅថ្ងៃទី ៣០-៣១ ខែធ្នូ ឆ្នាំ ១៩៩៩ និង ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០០ ។

ជាមួយនេះផងដែរ យើងខ្ញុំអ្នកស្រាវជ្រាវរៀបរៀងអត្ថបទ និងជាស្ថាបនិកក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ លើកទី២ នេះមិនអាចបំភ្លេចនាមឯកឧត្តមរក្ខ មុន្នី អភិបាលខេត្តរងទទួលបន្ទុកវិស័យវប្បធម៌ដែលបានជួយជ្រោមជ្រែងអស់ទាំងកម្លាំងកាយចិត្តរហូតដល់ក្រុមសិល្បៈ បានអញ្ជើញទៅសំដែងដល់ខេត្តសៀមរាបហើយ និង ត្រឡប់វិញដោយសុវត្ថិភាពគួជាទីមោទកភាពយ៉ាងក្រៃលែង ។

ជាអកុសល ក្រោយពីការវិលត្រឡប់មកពីសំដែងនៅអង្គរវិញ វិបត្តិផ្ទៃក្នុងការបែកបាក់បក្សពួកឧបាសក ឧបាសិកាចំណុះជើងវត្តដេញព្រះភិក្ខុ យង់ ចំរើនភក្តីចេញពីវត្តកៀនស្វាយក្រៅទំនាស់មិនត្រូវបានដោះស្រាយទាល់តែសោះ ខ្ញុំសូមអធ្យាស្រ័យ

សុំចុះក្នុងកំណត់ហេតុ ពេលសិល្បៈរៀបសំដែងនៅចំពោះមុខអជ្ញាធរដែនដីឃុំស្រុក (លោក អ៊ុង ឆាន) ខេត្ត (លោក រក្ខ មុន្នី) ភាពចលាចលកើតឡើងដោយមានមនុស្សមួយក្រុមដកជណ្តើរកុដិលោក យង់ ចំរើនភក្តី ចេញមិនអោយលោកមានជណ្តើរឡើងចុះ... យើងក្រុមសិល្បៈចែកផ្លូវគ្នាតាំងពីពេលនោះមក... ទោះបីខ្ញុំបាទ ចិន្ត នាគ ធ្វើអន្តរាគមន៍ដល់មន្ទីរពាក់ពន្ធ័ដល់ក្រសួងពាក់ពន្ធ័មានក្រសួងធម្មការ និងសាសនាបញ្ជាផ្ទាល់ពីឯកឧត្តម ជា សារឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា យ៉ាងណាក៏ដោយ មន្ទីរធម្មការខេត្ត ការិយាល័យធម្មការស្រុក ព្រះគ្រូ យឿង យ៉ាត គណៈសង្ឃស្រុកកៀនស្វាយ... ដំណោះស្រាយគឺគ្មាន បានសេចក្តីថាក្រុមល្ខោនពោលស្រីវត្តកៀនស្វាយស្លាប់ខ្វះឆាកទីតាំងសម្រាប់ក្មេង១ហាត់... គណៈកម្មការអាចារ្យវត្តថ្មី (ដែលតែងតាំងដោយឯកឧត្តម ស្រី វណ្ណផ្ទង់ ឯកឧត្តមបានទទួលមរណភាពនៅសហរដ្ឋអាមេរិច...) មិនឱ្យកន្លែងឆាកចាស់ក្នុងវត្តមកក្រុមសិល្បៈហាត់វិញទេ ដោយមានដាក់ល័ក្ខខ័ណ្ឌច្រើនពេកជាមួយលោកយាយគ្រូចាស់ៗ ។ យើងគិតគូរបង្កើតក្រុមល្ខោនពោលស្រីនេះឱ្យរស់មានសកម្មភាពលេចចេញជាទម្រង់ល្ខោនបុរាណមួយដ៏ល្អនេះបានអស់រយៈពេល៤ឆ្នាំ... មកត្រូវស្លាប់វិញមួយប៉ប្រិចភ្នែកយើងខ្ញុំមានការសោកស្តាយជាអតិបរមា... សារព័ត៌មានរស្មីកម្ពុជាក៏បានជូនដំណឹងជាហូរហែរដែរចំពោះការបរាជ័យដោយមិនសមហេតុផលនេះ...។ល។ បញ្ហាទំនាស់មនុស្សបក្សពួកក្នុងវត្តតែសិល្បៈវប្បធម៌ប្រពៃណីរបស់ជាតិខ្លួន... ដោយសារចាស់ៗបែកបាក់គ្នាមិនអាណិតក្មេងៗខ្លះខ្ជប់បាយកញ្ចប់ដើរ ៦គីឡូម៉ែត្រ មកហាត់ល្ខោននៅក្នុងមជ្ឈដ្ឋានមួយដែលសម្បូរណ៍ទៅដោយរបរកសុី ទាក់ម៉ូយជួលបន្ទប់ជួលផ្ទះទឹកយ៉ាងនេះ ។ ខ្ញុំបាទអ្នករៀបរៀងសូមបញ្ចប់អត្ថបទការកើត និងការស្លាប់ទៅវិញរបស់ក្រុមល្ខោនពោលស្រីក្រោមក្រសែភ្នែកដ៏សោកស្តាយស្រណោះរបស់ខ្ញុំបាទ ចិន្ត នាគ ស្លាបនិកមួយរូបដោយក្តីអាឡោះអាល័យជាទីបំផុត ។ ដំណឹងចុងក្រោយ (ខែមិនា ឆ្នាំ២០០១) នេះបានព័ត៌មានថាបាត់ក្រាំង (ពណ៌ខ្មៅ) បុរាណមួយនៅសល់តែមួយដែលកាលនៅផ្ទះលោកយាយកុំ ដំបូងមាន២ ឥឡូវបាត់មួយហើយ...។ល។ តើយ៉ាងណា? អ្នកបន្លំដើម្បីអ្វី?...

## កំណត់ហេតុ

ការប្រមូលផ្តុំបង្កើតឡើងវិញជាក្រុមសិល្បៈសហគមន៍ "ល្ខោនពោលស្រីវត្តកៀនស្វាយក្រៅលើកទីពីរក្រោយឆ្នាំ ២០០០ ។

យើងខ្ញុំជាអ្នកនិពន្ធសៀវភៅបច្ចេកទេសសិល្បៈសំដែងល្ខោនពោលស្រីពេលនេះទូលព្រះបង្គំខ្ញុំព្រះករុណា ខ្ញុំបាទសូមធ្វើការកត់ត្រានូវកំណត់ហេតុបន្ថែមលើប្រវត្តិល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ ដើម្បីជាព័ត៌មានជូនអ្នកជំនាន់ក្រោយសម្រាប់ធ្វើការរិះគិត និងពិចារណា។

នៅថ្ងៃទី ០៧ ខែ ១២ ឆ្នាំ ២០០៤ ដោយនៅមានអ្នកស្រឡាញ់ទម្រង់ល្ខោនពោលស្រីនេះប្រៀបបានទៅនឹងគល់ឈើមួយមានឫសគល់ យើងពូនជ្រុំស្រោចទឹកលូតលាស់ទៅជាដើមឈើធំមានមែកសាខាត្រសុំត្រសាយបាន ។ យើងខិតខំរើសបំណែកដែលបែកបាក់រៀបចំជាថ្មីមួយសារទៀត បង្កើតជាក្រុមសិល្បៈ សហគមន៍ទាល់តែបាន ។ យើងឯកភាពជាមួយព្រះចៅអធិការវត្តកៀនស្វាយក្រៅ ព្រះនាម ពៅ រតនា គណៈកម្មការអាចារ្យវត្តរៀបជាពិធីបើកវគ្គបង្រៀនសិល្បៈ ចំពោះកូនចៅអ្នកភូមិក្មេងៗលើកទីពីរព្រោះពួកនាងៗកាលពីហាត់រៀនលើកទី១នោះ គេចេញទៅប្រកបវិជ្ជាជីវៈរកទទួលទានធ្វើការងារតាមលទ្ធភាពផ្សេងៗរៀងៗខ្លួន តែពួកក្រុមនាងបងៗកាលពីឆ្នាំ២០០០នោះក៏នៅតែមកជួយបង្ហាត់ប្អូនៗខ្លះៗរៀងរាល់ ថ្ងៃអាទិត្យដែរពេលសម្រាកពីការងារ (ដោយមានយាយៗឈរជំហរបង្ហាត់ដូរវេន គ្នាព្រឹកល្ងាចទាំងខ្វះខាតជីវភាព) រហូតដល់យើងបានធ្វើសេចក្តីអំពាវនាវមួយមានខ្លឹម សារទាំងស្រុងដូចខាងក្រោម ។



កិច្ចពិភាក្សា រើរៀបក្រុមល្ខោន និងបង្រៀនសិស្សថ្មី
បន្តជាមួយចៅអធិការវត្ត គណៈកម្មការអាចារ្យ និងគណៈឃុំ និងគណៈនារីឃុំ

ព្រះតេជគុណ ពៅ រតនា
ចៅអធិការវត្តកៀនស្វាយក្រៅ



លោក ចិន្ត នាគ លើកហេតុផល
ពិភាក្សាស្ដាបនិកល្ខោនពោលស្រីជាបន្ត



ព្រះចៅអធិការ និង
គណៈកម្មការអាចារ្យ
វត្តទទួលភោជនាហារ
ចំនួនមនុស្សជាង
១០០នាក់ ក្នុងថ្ងៃ
ប្រារព្ធពិធី





សិស្សថ្មី កូនចៅ
អ្នកភូមិធំ មកហាត់
រៀនក្បាច់ល្ខោន
ពោលស្រីបន្តវេន



# សេចក្ដីអំពាវនាវ

ក្រុមសិល្បៈសហគមន៍ ល្ខោនពោលស្រី វត្តកៀនស្វាយក្រៅ សូមអំពាវនាវដល់ប្រជាជនខ្មែរ និងបរទេសទាំងអស់ ដែលមានចិត្តសទ្ធាសប្បុរសសូមជួយដល់ក្រុមសិល្បៈដើម្បីរក្សាប្រពៃណីយ៍សិល្បៈវប្បធម៌ខ្មែរ ។

ទម្រង់ល្ខោនពោលស្រី សេសសល់នៅតែវត្តកៀនស្វាយក្រៅមួយក្រុមគត់ ទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុង ២៤ ខេត្តក្រុង ស្ថាបនិកក្រុមបានបង្ហាត់កុមារី ៦ ភូមិចំនួន ១៥០នាក់ ក្នុងនោះមានក្មេងកំព្រាផងដែរ ។

ក្រុមសិល្បៈល្ខោនកើតឡើងនេះមានការខ្វះខាតយ៉ាងខ្លាំងទាំងឧបករណសម្ភារៈនិងថវិកាដើម្បីផ្គត់ផ្គង់អោយមានដំណើរការ ។ យើងខ្ញុំស្ថាបនិកក្រុមទាំងអស់គ្នាមានសង្ឃឹមលើទឹកចិត្តសប្បុរសធម៌ របស់អស់លោកអ្នក ទាំងខ្មែរទាំងបរទេស ក្នុងការស្ដារសិល្បៈវប្បធម៌ទម្រង់ល្ខោនខ្មែរនេះព្រោះជាទម្រង់ល្ខោនដ៏មានចំណាស់តាំងពីសម័យអង្គរមកម្ល៉េះ ( តាមការសិក្សាស្រាវជ្រាវ ) ។

សូមផ្ញើសេចក្ដីសង្ឃឹមទុកជាមុន សូមថ្លែងអំណរគុណចំពោះអស់លោកសប្បុរសជន ដែលមានទឹកចិត្តសទ្ធាជាកុសល ឆ្លើយតបនិងសេចក្ដីអំពាវនាវនេះ សូមជូនពរនិងភាពញញឹមប្រឹមប្រិយ៍ក្នុងជីវិត ។

**ស្ថាបនិក**

| | | |
|---|---|---|
| លោកយាយ | ជា មុត | |
| លោកយាយ | តិន យិន | |
| លោកយាយ | អ៊ុំ ណម | |
| លោកយាយ | មាស ហូ | |
| លោកតា | នៅ ជា | |
| លោក | ចិន្ត នាគ | ០១២ ៨៤៣ ៦២៤ |
| អ្នកគ្រូ | ទន់ សាវ៉ង | ០១២ ៩២០ ៧០៦ |
| អ្នកគ្រូ | ឱម យុវណ្ណី | ០១២ ៣៤៤ ២០១ |
| លោក | ជា ឈន | ០១២ ៤១៤ ២០៣ |
| អ្នកស្រី | ទុយ ស៊ីណាត | ០១២ ៤៧១ ៤២៤ |

ថ្ងៃទី២៧ ខែ០៥ ឆ្នាំ២០០៥

ចៅអធិការវត្តកៀនស្វាយក្រៅ

ពៅ_រតនា

បានឃើញ និង ឯកភាព

..........................................

ថ្ងៃទី27 ខែ05 ឆ្នាំ2005

មេឃុំ

មៀច_ឆៃ



ការអញ្ជើញដល់រោងល្ខោនពោលស្រីរបស់អ្នកម្នាង **ស៊ីសុវត្ថិ កន្នីរ៉េត**, ថ្វាយបង្គំព្រះចៅអធិការវត្តកៀនស្វាយក្រៅព្រះនាម (**ពៅ រតនា**)

ហើយបន្ទាប់មកអ្នកម្នាងស៊ីសុវត្ថិកន្នីរ៉េតក៏បានអញ្ជើញចែកអំណោយក្នុងនាមប្រធានមូលនិធិក្តីសង្ឃឹមនៃ ក/ជ (២៧-០៥-០៥) ដូចមានរូបថតជាភស្តុតាងខាងក្រោមនេះ ។






នាងក្មួយៗ សិស្សចាស់ចូលរួមរាំជូនពរអ្នកម្នាងប្រធានមូលនិធិ




(១)លោកជំទាវ ហ៊ឹម ណាឡា បានអញ្ជើញចូលរួមក្នុង ពិធីចែកអំណោយដល់ កុមារី ចំនួន ១៥០នាក់ សិស្សថ្មីរបស់ក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅនេះផងដែរ (២)អ្នកគ្រូទន់សារ៉ាំងស្ថាបនិកក្រុម




ពិធីចែកអំណោយរបស់មូលនិធិក្តីសង្ឃឹមនៃកម្ពុជាដល់ក្រុមល្ខោន ។

(១)អ្នកគ្រូ ឱម យុវណ្ណី ស្ថាបនិកក្រុម

សូមជូនទម្រង់ល្ខោនពោលស្រី
រឿង "ជ័យ សែន"

## ឆាកទី ១

ភ្លេងស្មើ (ស្មី) *(ជ័យសែនចេញ)*

ជ័យសែន : ... (និយាយ-មុននិយាយសំពះគោរពទស្សនិកជន) ខ្ញុំទ្រង់ព្រះនាមហៅថា ជ័យ សែន ថ្ងៃនេះខ្ញុំកាន់តែធំពេញវ័យហើយគិតចង់លាព្រះមាតា ព្រះបិតា ទៅរៀនសិល្បវិជ្ជាការដើម្បីការពារព្រះបូរី (ភ្លេង ព្រះមាតា ព្រះបិតាចេញ)

ជ័យសែន : ... ច្រៀងបទព្រះសំង៉ា ដល់ហើយឱនកាយថ្វាយបង្គំ (ច្រៀងខ្លួនឯងព្រមទាំងដាក់ក្បាច់ទៅតាមពាក្យពេចន៍ទៀតផង) បិតាជាធំលើសិរសាថាកូនសូមលាទៅរៀនសិល្បវិជ្ជាការ សូមព្រះបិតាមេត្តាកូន ។

*(សាច់ភ្លេង)*

ជ័យសែន : ... (និយាយ) បុត្រសូមក្រាបថ្វាយបង្គំ ព្រះមាតា ព្រះបិតា...

បិតា : ... អើល្អហើយបុត្រ ថ្ងៃនេះតើបុត្រមានកិច្ចការយ៉ាងណាដែរ ដូចជាមានព្រះទ័យសប្បាយរីករាយម្ល៉េះបុត្រ...

ជ័យសែន : ... បពិត្រព្រះបិតា ព្រះមាតា បុត្រសូមឱនកាយថ្វាយបង្គំលាព្រះបិតាព្រះមាតាទៅរៀនសិល្បវិទ្ធិរុង ដើម្បីឆោមយង់ការពារបូរី ។

ព្រះមាតា : ... នែ៎ ! បុត្រមាតាៗមិនអោយបុត្រទៅទេ ពីព្រោះបុត្រនៅក្មេងណាស់

ជ័យសែន : ... ក្រាបទូលព្រះមាតា បើមិនអោយទូលបង្គំទៅទេ... តើថ្ងៃក្រោយបាននរណាការពារព្រះនគរ ក្រាបទូល...

បិតាជ័យសែន : អើ...! បុត្រ បើបិតាមាតាឃាត់បុត្រមិនព្រមទេទៅក៏ទៅចុះណាំបុត្រ ។

ជ័យសែន : បើអញ្ចឹងបុត្រសូមក្រាបថ្វាយបង្គំលាសិនហើយ... ព្រះបិតា ព្រះមាតា

បិតា+មាតា : អើ ទៅចុះអោយបានសុខ... ពោល (តួធ្វើកាយវិការគ្រប់តាមពាក្យពោល)

ពីរក្សត្រកាត់ព្រះទ័យប្រតិពង្ស ទៅចុះឆោមយង់អោយសិទ្ធី...

*ភ្លេងឱត(អូត) (យំសោកបែកគ្នា)*

ពោល : ... កាលអើយកាលណោះ អង្គព្រះជ័យសែនអរឥតពីរបង្គំបិតុរង្គ អង្គជនី ឡើងជិះពាជីចរឈ្លាឈ្លែ...

*(ភ្លេងជើត) (ពាជីចេញ) (មាតាបិតាចូល ជ័យសែនសំដែងបន្ត)*

ជ័យសែន : ឱ ! ខ្លួនខ្ញុំអើយ ខ្ញុំបានលាព្រះមាតាព្រះបិតា មកដល់ពាក់កណ្ដាលព្រៃហើយមិនបានជួបនឹងលោកតាមុនីឥសីសោះ បើអញ្ជឹងខ្ញុំគិតរាប់ព្រៃកម្សាន្តកាយាសិន... ។ ច្រៀង... (បទរាយ) ឱ ! ដើមស្រឡៅខ្ពស់ស្រលួត ដើមទ្រាដុះត្រួតលើខ្លុងត្បែង ណាគ្រីគគីរដុះម្នាក់ឯងតែខ្ញុំខំស្វែងរកឥសី... ។

ជ័យសែន : (និយាយ) ព្រះសុរិយាក្ដៅខ្លាំងណាស់ហើយ ខ្ញុំក្រឡេកទៅឃើញដើមជ្រៃមួយធំសាខាល្អណាស់ បើអញ្ជឹងខ្ញុំចូលទៅសម្រាកកាយសិន... យី ! ខ្ញុំឃើញសត្វព្រៃច្រើនណាស់ បើអញ្ជឹងខ្ញុំគិតចាប់សត្វព្រៃមកឆ្អើរចម្អែតផ្ទៃសិន... ។ (ជ័យសែនចូល)

*(ភ្លេងរូ)*

*(ចុងភ្លេងរូ យក្ស, មហេសី និងបុត្រីចេញ) (ភីលៀង ៨នាក់)*

នព្វវង្ស : (និយាយ) ទ្រង់ព្រះនាមនព្វវង្សពង្សធិបតី មហេសីនាមឈ្មោះសូផាណា បុត្រី នាមឈ្មោះសាឡីបុប្ផា សោយរាជ្យនៅនគររតនាខ្ចី... ថ្ងៃនេះអផ្សុកក្នុងព្រះទ័យខ្លាំងណាស់សូផាណាអូន បងសុំលាអូនទៅកម្សាន្តនៅក្នុងព្រៃបានមួយថ្ងៃអូន... សូផាណា... ព្រះពរព្រះស្វាមីសូមស្ដេចយាងក្រាបទូល... !

នព្វវង្ស : បងលាអូនសិនហើយ បិតាលាបុត្រីសិនហើយ សាឡីបុប្ផាបុត្រីបិតា

សូផាណា+សាឡីបុប្ផា : ព្រះពរ... ស្ដេចយាងក្រាបទូល...

*(ភ្លេងកេវណៃ, ជើត... សូផាណា សាឡីបុប្ផា ចូល...)*

*(នព្វវង្សមកមុខឆាក ជ័យសែន ចេញមកដេកលើគ្រែ)*

នព្វវង្ស : (ពោល)... ដល់ព្រៃដើរព្រាង ប្របជើងភ្នំ ត្រូវថ្ងៃចូលផ្ទុំក្រោមព្រឹក្សា ព្រះពាយរំភើយក្លិនមំសារដែលរាជកុមារឆ្អើនោះណី... ។

នព្វវង្ស : (និយាយ) យ៉ះ ! ធំក្លិនអ្វីក៏ឈ្ងុយម្លេះ... ! (ពោល) ស្រក់ទឹកមាត់ច្រោក ក្រោកឡើងមើល ឃើញក្រោមម្លប់ឈើឆ្អើសត្វព្រៃ យល់ទាំងកុមាររូបល្អមល្ហៃ ថាមានលាភជ័យថ្ងៃនេះណា៎... ស៊ីសាច់ស៊ីទាំងក្មេងនេះឯង... យី ! មិនកើតទេ អាត្មាអញសេពមន្តវិជ្ជាការសណ្ដំកុមារនេះអោយលង់លក់ទើបបាន... ។

*(ភ្លេងរូ+ជើត) (នព្វវង្សចូលស៊ីសាច់) (កាយវិការក្បាច់)*

នព្វវង្ស : យី ! សាច់ឆ្អើរនេះឆ្ងាញ់ណាស់ អាត្មាអញយកសាច់ពីរដុំនេះផ្ញើសូផាណា និងសាឡីបុប្ផាអោយបានឆ្ងាញ់មាត់ផង... ។

*(នព្វវង្សចូល) (ជ័យសែនដឹងខ្លួន ច្រៀងជាក្រុមជូនកាយវិការ)*

ចម្រៀងជាក្រុម : (បទប្រែប្រាណ) ស្ដែងស្ដេចប្រែប្រាណព្រះកាយា តើនចាកកាលណា បាត់ពុំឃើញ (សាច់ភ្លេង ជ័យសែនរត់រកមើលសាច់របស់ខ្លួន) (ភ្លេងឱត)

ជ័យសែន : យី ! នរណាចិត្តហានក្លា លួចយកមំសាអាត្មាអញដូច្នេះ នេះមកពីអាត្មាអញគ្មានរីទ្ធីចេស្ដា (ជ័យសែន បួងសួង) ឱ ! ព្រះឥន្ទ្រព្រះព្រហ្មអើយ សូមលោកចុះមកជួយខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់ភ័យខ្លាំងណាស់ (ជ័យសែនមកដាក់ក្បាច់ឱតខាងមុខឆាក " ភ្លេង រូ " ព្រះឥន្ទ្រចេញ...)

*(បទជិនប៉ាងឡាង)*

ចម្រៀងជាក្រុម : (ពោល)... តេជៈបុណ្យព្រះវិសេសសល់ក្ដៅដល់ព្រះឥន្ទ្របើកទិព្វចក្ខា ។

*(សាច់ភ្លេង) (និយាយ)*

ព្រះឥន្ទ្រ : ខ្លួនខ្ញុំជាព្រះឥន្ទ្រ ថ្ងៃនេះក្ដៅអាសនៈខ្លាំងណាស់ បើអញ្ចឹងខ្ញុំបើកទិព្វចក្ខុមើលទៅដ្ឋានកណ្ដាលមើល តើមានរឿងអ្វីកើតឡើង ។

*(ភ្លេង រូ) (សំពះបង្វិលខ្លួន)*

ឥឡូវឃើញថា ព្រះរាជកុមារ ជ័យសែន កំពុងតែមានទុក្ខ ដូច្នេះខ្ញុំប្រញាប់ចុះទៅជួយសិន ។ ក៏ប៉ុន្តែខ្ញុំទៅជាព្រះឥន្ទ្រអញ្ចឹងមិនកើតទេ ខ្ញុំត្រូវប្រែក្រឡាជាតាបសដើម្បីយកបង្កាត់ពេជ្រ ខ្សែចងដំបងវាយទៅអោយជ័យសែនសិន ។

*(ភ្លេង រូ+ជើត)*

ព្រះឥន្ទ្រ : ... នែ៎ ! ចៅៗស្គាល់តាទេចៅ តានឹងហើយជាព្រះឥន្ទ្រណាចៅ... ។

ជ័យសែន : ... ចៅសូមថ្វាយបង្គំលោកតា

តាបស : ... អើ ! ល្អហើយចៅ (ពោល)...ដល់ភ្លាមទ្រង់ហុចបង្កាត់ពេជ្រ ទោះយក្សធ្វើម្តេចចៅកុំភ័យ បើយក្សអួតខ្លាំងតាំងជាញជ័យ មាសមៃក្រលុកវាអោយទ្រមអោយបានការ ។ (ធ្វើកាយវិការតាមពាក្យពោល)

តាបស : ... បើអញ្ចឹងតាលាសិនហើយណាចៅ... ។

ជ័យសែន : ... ករុណាលោកតា និមន្តលោកតា...

*(ភ្លេងជើត)*

*(លោកតាចូល ជ័យសែនទៅម្ខាងឆាក កន្ទុយភ្លេងនព្វវង្សចេញ)*

ពោល... (បន្ថយភ្លេង) អាសូរីពុំស្កប់ព្រះចិន្តាចូលដល់នគរហើយកាលណា រូតរះវិលចូលក្នុងពីក្សព្រៃ

*(ភ្លេងជើត)*

នព្វវង្ស : យី ! ម៉េចក៏បាត់កុមារនេះទៅណាអញ្ចេះ អាត្មាអញត្រឡប់មកវិញថានឹងចាប់កុមារនេះស៊ីទាំងស្រស់អោយឆ្ងាញ់មាត់ម្តង ។

ជ័យសែន : យើងនៅខាងណេះណាក្រុងមារ នែ៎ ! ក្រុងមារឯងចិត្តសាមាន្យណាស់លួចមំសាយើងហើយឥឡូវតាមមករកស៊ីយើងទៀត ឬក្រុងមារ?

*(ជ័យសែន និង នព្វវង្ស ច្រៀងតគ្នា)*

*(ក្រុមច្រៀងជូនតួដាក់ក្បាច់)*

វ៉ើយៗ ! ក្រុងមារចោរចិត្តសាមាន្យលួចប្លន់បំពានមិនគិតខ្លួនក្ស័យ...។
...នែ៎ ! វ៉ើយកុមារ អ្នកឯងអាងអី ថាយើងក្សិណក្ស័យដោយសារដៃឯង

*(សាច់ភ្លេង)*

ជ័យសែន : (និយាយ) បើអញ្ជឹងឯងចូលមកចុះណាំ ក្រុងមារ

*(ដើត+រូ) (ចូលច្បាំងគ្នា ជ័យសែនផ្សង)*

(ពោល) ចង់អួតអានុភាពនិងកុមារ ស្ទុះឆ្វាចូលទៅដូចគេរីត បង្កាត់ពេជ្រ គេចរួបជិត យក្សមិត គេចដោះអស់ប្រាជ្ញា

*(ជ័យសែន ប្រើសិល្ប៍បង្កាត់ពេជ្រ ចងនព្វវង្ស) (ភ្លេងឱត)*

ជ័យសែន : ... ម៉េចទៅក្រុងមារ ឯងសុខចិត្តចុះចាញ់យើងហើយឬនៅក្រុងមារ។
នព្វវង្ស : នែ៎ ! ម្នាលកុមារ ឱសូមចុះចាញ់តេជដៃកុមារឯងហើយណាំ... ។
ពោល : គិតហើយត្រាស់ថា ឱ ចាញ់ជាក់ សូមស្អគ្រ ទុកអ្នកជាកូនស្មោះ ។
ជ័យសែន : បើក្រុងមារព្រមចុះចាញ់យើងហើយមិនអីទេ យើងទុកជីវិតអោយរស់តទៅទៀតណាំ... ។
ជ័យសែន : (បួងសួង) សូមបួងសួងដល់ព្រះឥន្ទ្រាធិរាជ្យ ដែលលោកបានប្រទានបង្កាត់ពេជ្រ នឹងខ្សែចងដំបងវាយអោយខ្ញុំ ខ្ញុំសូមសេពមន្តវិជ្ជាការទៅកាលណា ស្រាយយក្សានេះដូចសេចក្តីប្រាថ្នា

(ភ្លេង រូ) (នព្វវង្សរួចពីចំណងសិល្ប៍)

(ពោល)... (នព្វវង្សចូលថ្នមជ័យសែន) ព្រះព្រមចូលថ្នមហើយស្រាយដោះ យក្សាពរផ្ដោះហោះទៅរាជក្រុងក្រៃ... ។

*(ភ្លេង ដើត)*

**ចប់ឆាកទី ១**

~~~~~~~~~~~

**ឆាកទី ២**

ពោល : ថ្លែងអង្គជ័យសែនមានរិទ្ធី ចរលីយាងតាមក្រុងអាសូរ៉ា បានរៀបអភិសេក
~~~~~~~~~~~

ជាមួយសាឡីបុប្ផា បុត្រីយក្សាកាលណោះហោង ។

*(ដើត ស៊ីន្ទូន)....(ជូរត្ដជ័យសែនធំ)*

សាឡីបុប្ផា : ក្រាបទូលព្រះអង្គ សូមព្រះអង្គយាងទៅប្រពាតសួនជាមួយខ្ញុំម្ចាស់ណ៎ា ព្រះអង្គ។

*(សកម្មភាពជ័យសែន និងសាឡីបុប្ផា)*

ច្រៀង : (រាប់ផ្កា) ឱ ផ្ការំចេក ផ្ការំដួល ដើមស្លា ដើមស្រស់ ដើមចំប៉ី ចំប៉ា ចំពើប ទើបយល់ថ្មី ម្លិះរួតនួនស្រីផ្កាសេមាន់ ។

*(ភ្លេងរ៉ូ)*

សាឡីបុប្ផា : ព្រះស្វាមីសប្បាយព្រះទ័យទេក្រាបទូល ។

ជ័យសែន : ឱអូនហើយ បងសប្បាយព្រះទ័យខ្លាំងណាស់ណ៎ាអូន ។

សាឡីបុប្ផា : បើអញ្ចឹងយើងនាំគ្នាចូលទៅថ្វាយបង្គំ ព្រះមាតា ព្រះបិតា យើងណ៎ា ក្រាបទូល។

ជ័យសែន : ពិតមែនហើយមហេសីអូន ។

*(ភ្លេងកន្ទុយដើត) (មាតាបិតា)*

ជ័យសែន+បុប្ផា : បុត្រសូមក្រាបថ្វាយបង្គំព្រះមាតា ព្រះបិតា ។

បិតា :អើ ! ល្អហើយបុត្រទាំងពីរ ។ បុត្រទៅប្រពាតសួន តើបុត្រមានទឹកព្រះទ័យយ៉ាងម៉េចដែរបុត្រ ។

ជ័យសែន : អូ ! ក្រាបទូលសប្បាយណាស់ក្រាបទូល ។

នព្វវង្ស : នែ៎ ! មហេសីអូនថ្ងៃនេះ បងដូចជារសាប់រសល់ក្នុងព្រះកាយខ្លាំងណាស់ ប្រហែលជាមានរឿងអ្វីហើយមើលទៅ ។

*(ភ្លេងដើត) (ត្លុកចេញ)*

ត្រីដាសេនារបស់វណ្ណរាជ្យ អាសូរី ខ្ញុំបាទឈ្មោះហៅថា ត្រីដា រាជទូតនាំសាររបស់នគរវណ្ណរាជ្យអាសូរី ចងស្ពានមេត្រីជាមួយបុត្រីនព្វវង្ស ឥឡូវខ្ញុំធ្វើដំណើរកាន់តែឆ្ងាយណាស់មកហើយ រកផ្លូវមិនឃើញសោះសង្ស័យ

តាមផ្លូវត្រឡោកបែកទេមិនដឹង ។

នព្វវង្ស : នែ៎ ! ត្រីដាឯងមានការអ្វី ចូរឯងស្រដីប្រាប់យើងមកមើលណាត្រីដា។

ត្រីដា : កូណាថ្លៃវិសេសក្រាបទូល ទូលបង្គំនាំព្រះរាជសារពីម្ចាស់វណ្ណរាជ្យ មកថ្វាយព្រះអង្គក្រាបទូល ។

ពោល : (សូត្រពាក៧) សារព្រះវណ្ណរាជ្យរិទ្ធិរុង ផ្ញើមកនព្វវង្សចោមអាសូរី ខ្ញុំមានបុត្រាអ្នកមានបុត្រី សូមស្ពានមេត្រីតពង្សា ។

នព្វវង្ស : នែ៎ ! ត្រីដាចូរឯងទៅប្រាប់ម្ចាស់ឯងវិញចុះណ៎ា ថាយើងបានលើក បុត្រី ឱ្យមានស្វាមីហួសទៅហើយណាត្រីដា ។

ត្រីដា : កូណាថ្លៃវិសេសក្រាបទូល ប៉ុន្តែបើតាមទូលបង្គំដឹងរឿងនេះបែបមិន ស្រួលទេ ប្រហែលជាម្ចាស់ទូលបង្គំលើកគ្រឿងបណ្ដាការមកដល់ពាក់ កណ្ដាលផ្លូវហើយមើលទៅក្រាបទូល ។

នព្វវង្ស : បើអញ្ចឹងឯងប្រញាប់ទៅណ៎ា ។

ត្រីដា : កូណាថ្លៃវិសេស... បើអញ្ចឹងទូលបង្គំសូមក្រាបថ្វាយបង្គំលាសិន ហើយក្រាបទូល ។

នព្វវង្ស : អើ ! ទៅចុះ

*(ភ្លេងជើត) (ទ័ពវណ្ណរាជ្យមកដល់)*

ត្រីដា : សូមថ្វាយបង្គំម្ចាស់ ។

វណ្ណរាជ្យ : អើ ! ល្អហើយ នែ៎ ! សេនាយើងឱ្យឯងយករាជសារទៅថ្វាយ នព្វវង្ស តើបានការយ៉ាងណាដែរសេនា ។

ត្រីដា : ក្រាបទូលម្ចាស់ អន្សមម្ចាស់ផ្អូមហើយក្រាបទូល ។

វណ្ណរាជ្យ : នែ៎ ! សេនាឯងនិយាយថាម៉េច យើងដូចជាស្ដាប់មិនបានសោះណ៎ា សេនា ។

ត្រីដា : ក្រាបទូលម្ចាស់ ស្ដេចនព្វវង្សបានលើកបុត្រីឱ្យមានស្វាមីហើយក្រាបទូល។

វណ្ណរាជ្យ : យើស ! នព្វវង្សឯងហ៊ានក្បត់នឹងយើងផង... នែ៎ សេនាឯងនាំគ្នា

ស្រែកហោ ៣ដង ព័ទ្ធរាំងវាក្លាមទៅណាំសេនា ។

ត្រីដា : កូណាថ្លៃវិសេស យក្សអ! ... យក្សអ! ... យក្សមិនសូវអរ ...។

នព្វវង្ស : នែ! សម្លាញ់ឯងមានរឿងអ្វីបានជាឯងមកព័ទ្ធរាំងយើងដូច្នេះណាសម្លាញ់។

វណ្ណរាជ្យ : នែ៎! នព្វវង្សឯងក្បត់ពាក្យសន្យាហើយ ឯងថាលើកបុត្រីឯងឱ្យមកបុត្រា យើង ហេតុអ្វីបានជាឯងលើកទៅឱ្យមនុស្សាដូច្នេះ ។

នព្វវង្ស : អើ! សម្លាញ់ឯងកុំខឹងនឹងយើងអី នេះមកពីយើងប្រយុទ្ធចាញ់ជ័យ សែន ណាំសម្លាញ់ ។

វណ្ណរាជ្យ : នែ៎! នព្វវង្សយើងមិនអត់ឱនឱ្យឯងបានទេ យើងត្រូវតែប្រយុទ្ធជាមួយ នឹងឯងហើយ ។

ជ័យសែន : ក្រាបទូលព្រះបិតា សូមព្រះបិតាទ្រង់គង់មួយកន្លែងសិនចុះទុកអោយ ទូលបង្គំប្រយុទ្ធតទល់ នឹងក្រុងមារវិញក្រាបទូល ។

នព្វវង្ស : អើ! ជ័យសែនបុត្របិតា បិតាតាមព្រះទ័យបុត្រចុះណាំបុត្រ ។

ជ័យសែន : នែ៎! ក្រុងមារសូមឯងប្រឡប់ទៅនគរឯងវិញទៅណាក្រុងមារ ។

វណ្ណរាជ្យ : នែ៎! អាមនុស្សាយើងមកដល់ទីនេះហើយយើងមិនត្រឡប់ទៅវិញទេ លុះត្រាតែសិរសាយើងធ្លាក់ដល់ដីណាំ ។

ជ័យសែន : បើអញ្ចឹងចាំទទួលសិល្ប៍ពីយើងទៅណាំក្រុងមារ ។ (ចូលប្រយុទ្ធ)

*(ជ័យសែនបួងសួង) (ភ្លេងជេិត+រូ+ឱត)*

វណ្ណរាជ្យ : នែ៎! ម្នាលកុមារយើងសូមចុះចាញ់ឯងហើយ ។ ឱសម្លាញ់ឯងប្រាប់ ទៅបុត្ររបស់ឯងឱ្យដោះលែងយើងទៅណាំ ។

នព្វវង្ស : នែ៎! ជ័យសែនបុត្របិតា សូមបុត្រដោះលែងសម្លាញ់បិតាទៅគេព្រម ចុះចាញ់យើងហើយ ។

ជ័យសែន : មិនអីទេព្រះបិតា សូមព្រះបិតាកុំព្រួយចាំបុត្រដោះលែងគេក្រាបទូល។

ជ័យសែន : (បួងសួង) (សូមបួងសួងដល់ព្រះឥន្ទ្រាធិរាជ្យដែលបានប្រទានបង្កាត់ ពេជ្រ និងខ្សែចងដីបងវាយដល់ខ្ញុំ សូមឱ្យខ្ញុំស្រាយចំណងនេះបានដូច

សេចក្តីប្រាថ្នា ។

*(ភ្លេងរូ)*

វណ្ណរាជ្យ : នែ៎! ជ័យសែនបុត្រ បិតាសូមទុកបុត្រដូចជាបុត្របង្កើត ហើយបើថ្ងៃក្រោយបុត្រមានរឿងអី បុត្រនឹកមកដល់បិតា បិតានឹងមកជួយបុត្រភ្លាមណាំបុត្រ ។ បើអញ្ចឹងបិតាលាបុត្រត្រឡប់ទៅនគរវិញហើយណាំបុត្រ។

ជ័យសែន : ស្តេចយាងក្រាបទូល

វណ្ណរាជ្យ : នែ៎! សម្លាញ់យើងទៅហើយណាំសម្លាញ់ ។

នព្វវង្ស : អើ! ទៅចុះសម្លាញ់ឱ្យបានសុខ ។

*(ភ្លេងជើត)*

**ចប់ឆាកទី ២**

~~~~~~~~~~~~~

**ឆាកទី ៣**

ជ័យសែន+បុប្ផា : បុត្រសូមក្រាបថ្វាយបង្គំព្រះមាតាព្រះបិតា ។

នព្វវង្ស : អើ! ល្អហើយបុត្រ បុត្រមានរឿងអ្វីបានជាមានព្រះភ័ក្ត្រស្រពាប់ស្រពោនម្ល៉េះបុត្រ ។

ជ័យសែន : ក្រាបទូលព្រះមាតាព្រះបិតា បុត្រចង់លាព្រះមាតាព្រះបិតាបន្តដំណើរទៅរៀនសីល្បវិជ្ជាការពីតាឥសីក្រាបទូល ។

នព្វវង្ស : អើ! មិនអីទេបុត្រ រួចចុះមហេសីបុត្រ តើបុត្រយកទៅជាមួយទេបុត្រ ។

ជ័យសែន : ក្រាបទូលព្រះបិតា បុត្រសូមផ្ញើមហេសីបុត្រ និងព្រះមាតាព្រះបិតាហើយក្រាបទូល ។

សុជាណា(ប្រពន្ធនព្វវង្ស) : ជ័យសែនបុត្រមាតាកុំទៅចោលប្អូនអីណាំបុត្រ ។

ជ័យសែន : ក្រាបទូលព្រះមាតា បុត្រទៅមិនយូរទេ បុត្ររៀនចេះចប់កាលណាបុត្រនឹងវិលត្រឡប់មករកមហេសីបុត្រវិញហើយណាំមាតា ។
~~~~~~~~~~~~~

សាឡីបុប្ផា : ឱព្រះស្វាមី១ កុំទៅយូរពេកណាំក្រាបទូល។

ជ័យសែន : អើ! មហេសីអូន បងទៅមិនយូរទេណាំអូន ។ បើអញ្ចឹង បងសូមលាអូនសិនហើយណាំអូន ។ ព្រះមាតាព្រះបិតាបុត្រសូមថ្វាយបង្គំលាសិនហើយ។

មាតា+បិតា : អើ! ទៅចុះឱ្យបានសុខណាំបុត្រ ។ (ភ្លេងជ័យសែនចូល)

*(ភ្លេងជើត)* (មាតាបិតាចូលម្ខាង+ស្វាចេញម្ខាង)

ពុងនភា : នែ៎! បងពានរុង ។

ពានរុង : យ៉ាងម៉េចបងពុងនភា ។

ពុងនភា : នែ៎! បងពានរុងយើងទាំងពីរកុំតែបានលោកតាប្រោសឱ្យយើងរស់រានមានជីវិត ម្ល៉េះយើងស្លាប់បាត់ទៅហើយណាំបង ។

ពានរុង : ពិតមែនហើយណាបងពុងនភា ។

ពុងនភា : នែ៎! បងពានរុង បងមើលទៅខាងមុខអាស្រមយើងទៅមើលដូចជាឃើញមានមនុស្សាកំពុងដើរចូលមកណាបង ។

ពានរុង : អើ! ពិតមែនហើយបងពុងនភា យើងស្រែកសួរគេមើល ។

ពុងនភា : នែ៎! ម្នាលកុមារ ឯងធ្វើដំណើរទៅណាមកណាបានជាយាត្រាមកដល់ទីនេះ ។

ជ័យសែន : ឱបងពានរអើយ ខ្ញុំធ្វើដំណើរមកនេះដើម្បីមករករៀនសីល្ប៍វិជ្ជាការពីតាឥសី សូមបងប្រណីអោយខ្ញុំចូលផងណាបង ។

ពាន្តទាំងពីរ : នែ៎! ម្នាលកុមារ យើងមិនឱ្យឯងចូលទេ លោកតាយើងកំពុងសង្រ្គមភាវនាធម៌បើចង់ចូលទាល់តែឯងប្រឡងអនុភាពជាមួយនឹងយើងសិនណាំកុមារ ។

ជ័យសែន : បើអញ្ចឹង បងចាំទទួលសីល្ប៍ពីខ្ញុំទៅណាំបង...! ។

ជ័យសែន : សូមនឹកគុនដល់ព្រះឥន្ទ្រាធិរាជ្យ ខ្ញុំសូត្រមន្តវិជ្ជាការទៅកាលណាចងស្វាទាំងពីរនេះដូចសេចក្តីប្រាថ្នា ។

*(ភ្លេងរូ+ឱក)*

ពានរទាំងពីរ : អូយ! ក្ដៅណាស់លោកតា ជួយខ្ញុំកូណាផងលោកតា ។

ឥសី : អើ! ហ្អេចៅតាយ៉ាងម៉េចបានជាជាប់ចំណងទាំងពីរនាក់ដូច្នេះណ៎ាចៅ។

ពានរទាំងពីរ : កូណាលោកតា ចៅបានប្រយុទ្ធចាញ់ដៃមនុស្សាណ៎ាលោកតា ។

ឥសី : យី! អើបើអញ្ចឹងឱ្យតាមើលបន្តិចមើលចៅ អូ! ចំណងនេះគឺចំណងជ័យសែនម្ចាស់ឯងទេតើ តាមិនហ៊ានស្រាយទេ ចាំឱ្យម្ចាស់ឯងមកស្រាយឱ្យទៅណ៎ាចៅ ។

ជ័យសែន : ចៅសូមក្រាបថ្វាយបង្គំលោកតា ។

ឥសី : អើ! ល្អហើយចៅ នែ៎! ពានរុង ពុងនរា ចៅថ្វាយបង្គំសុំទោសម្ចាស់ឯងដោះលែងទៅណ៎ា ។

ពានរទាំងពីរ : ទូលបង្គំសូមក្រាបថ្វាយបង្គំម្ចាស់ ទូលបង្គំសុំទោស សូមម្ចាស់ដោះលែងទូលបង្គំទៅ ។

ជ័យសែន : អើ! មិនអីទេបងទាំងពីរចាំខ្ញុំស្រាយឱ្យបងណ៎ា ។

*(ជ័យសែនបួងសួង ភ្លេងរូ)*

ជ័យសែន : ខ្ញុំកូណាសូមថ្វាយបង្គំលោកតា ។

ឥសី : អើ! ល្អហើយចៅ តើចៅមានបំណងយ៉ាងណាទើបយាត្រាមកដល់ទីនេះចៅ។

ជ័យសែន : កូណាលោកតា ខ្ញុំកូណាមានបំណងចង់មករៀនសីលវិជ្ជាការពីលោកតាដើម្បីការពារបូរីណ៎ាលោកតា ។

ឥសី : អើ! មិនអីទេ ចាំតាបង្ហាត់បង្រៀនណ៎ាចៅ។ អើ! ពានរុង ពុងនរា។

ពានរទាំងពីរ : កូណាលោកតា។

ឥសី : ចៅទាំងពីរ នៅចាំអាស្រមតាឱ្យបានល្អ តានាំម្ចាស់ឯងទៅរៀនសីលវិជ្ជា នៅខាងក្រោយអាស្រមនេះណ៎ាចៅ ។

ពានរទាំងពីរ : កូណាលោកតា និមន្តលោកតា ។

*(ភ្លេងជើត)*

ពុងនរា : នែ៎! បងពានរុង ។

ពានរុង : យ៉ាងម៉េចបងពុងនរា ។

ពុងនរា : ឥឡូវលោកតា និងម្ចាស់យើងទៅបាត់ហើយបើអញ្ចឹងយើងគិតទៅបេះផ្លែផ្លូមកថ្វាយម្ចាស់ និងប្រគេនលោកតាយើងផងណា៎បង ។

ពានរុង : ពិតមែនហើយបង អញ្ចឹងយើងនាំគ្នាទៅណា៎បង ។

*(ភ្លេងស្វា ជើត) (ភ្លេងបាធំ)*

ពោល : ថ្លែងពីអង្គជ័យសែនមានបារមី រៀនចប់គម្ពីរសាស្ត្រាបាលី អស់ជប់ប្រាំថ្ងៃចេះសព្វវិជ្ជា ។

*(ជើត)*

ពានរទាំងពីរ : លោកតា២ ច្រើនណាស់លោកតា ។

ឥសី : អើ! អូពានរឯងបានអីក៏សន្ធឹកសន្ធាប់ម្ល៉េះចៅ ។

ពានរុង : កូណាលោកតា កូណាបានបេះផ្លែផ្លូមកប្រគេនលោកតា ហើយខាងណោះថ្វាយម្ចាស់ណា៎លោកតា ។

ជ័យសែន : ចៅសូមថ្វាយបង្គំលោកតា ។

ឥសី : អើ! អើល្អហើយចៅ២ ចូលមកជួបតា តើមានកិច្ចការអ្វីដែរចៅ ។

ជ័យសែន : កូណាលោកតា ឥឡូវនេះចៅបានរៀនចេះចប់សព្វគ្រប់មុខវិជ្ជាសិលអស់ហើយ ។ ចៅចង់លាលោកតាត្រឡប់ទៅនគរវិញណា៎លោកតា ។

ឥសី : អើ! បើចៅទៅក៏ទៅចុះ ក៏ប៉ុន្តែមុននឹងទៅចាំតាជប់ធ្នូជ័យ និងមនោម័យមួយដល់ចៅគ្រាន់នឹងការពារខ្លួនទៅតាមផ្លូវណា៎ចៅ ។

*(ភ្លេងរូ ជើត)*

**ចប់ឆាកទី ៣**

~~~~~~~~~~~~
~~~~~~~~~~~~

## ឆាកទី ៤

ច្រៀង..........

ពោល : ថ្លែងពីអង្គជ័យសែនមានរិទ្ធី ត្រាច់កាត់គីរីព្រៃព្រឹក្សា ឃើញម្លប់ឈើធំ ចូលផ្ទំកាយា កាលហុកយក្សាលួចយកសេះបាត់ ។

*(ភ្លេងជើត)*

យក្សទសរថ : នែ៎! ប៊ូសគុស្សរ៉ាអូន ។

ប៊ូសគុស្សរ៉ា : ព្រះពរព្រះស្វាមី ។

ទសរថ : ថ្ងៃនេះបងដូចជារសាប់រសល់ក្នុងព្រះកាយខ្លាំងណាស់ ប្រហែលជាមានការអីហើយមើលទៅណ៎ាមហេសីអូន។

ប៊ូសគុស្សរ៉ា : ព្រះពរព្រះស្វាមី...

*(ចុងជើត)*

យក្សកាលហុក: ខ្ញុំព្រះនាមកាលហុកអាសូរី ខ្ញុំបានលួចសេះរបស់ព្រះរាជកុមារជ័យសែនហើយ ឥឡូវនេះខ្ញុំមកពឹងទសរថសម្លាញ់របស់ខ្ញុំដើម្បីទៅចាប់រាជកុមារនេះទៀត កុំឱ្យពូជពង្សមនុស្សមានរិទ្ធិអានុភាពលើយើង ។

*(ពោលធ្វើកាយវិការតាម)*

ពោល : នែ៎! វើយកាលហុកមិត្តសម្លាញ់ ឯងមករកអញមានការអ្វី រឿងតូច ឬធំឯងកុំភ័យ សូមឯងស្រដី ប្រាប់យើងមកចុះណ៎ាសម្លាញ់ ។

កាលហុក : អើសំឡាញ់! យើងមកពឹងឯងឱ្យទៅចាប់មនុស្សណាសម្លាញ់ ។

ទសរថ : អើ! មិនអីទេសម្លាញ់ តើមនុស្សនោះនៅឯណ៎ាសម្លាញ់ ។

កាលហុក : នៅឯក្នុងព្រៃឯណោះណ៎ាសម្លាញ់ ។

ទសរថ : បើអញ្ចឹង ប៊ូសគុស្សរ៉ាអូន អូននៅចាំនគរ បងជូនសម្លាញ់បងទៅចាប់មនុស្សណ៎ាអូន ។

ប៊ូសគុស្សរ៉ា : ព្រះពរព្រះស្វាមី ស្តេចយាងក្រាបទូល ។

ទសរថ : នែ៎! សម្លាញ់យើងទៅតែពីរនាក់ ដូច្នេះមិនបានទេយើងត្រូវបបួលសួង

នឹកដល់សម្លាញ់យើងម្នាក់ទៀត គេឈ្មោះរុលម៉ាតឱ្យជួយយើងផងណាំសម្លាញ់ ។

កាលហុក : អើ! ពិតមែនហើយសម្លាញ់ ។

ទសរថ : សូមបួងសួងនឹកដល់សម្លាញ់រុលម៉ាត សូមឯងមកជួយយើងជាបន្ទាន់ណាំសម្លាញ់ ។

*(ភ្លេងរូ ជើត)*

រុលម៉ាត : នែ៎! សម្លាញ់ឯងមានរឿងអី បានជាឯងនឹករលឹកដល់យើងដូច្នេះណាំសម្លាញ់ ។

ទសរថ+ហុក : អើ! សម្លាញ់យើងចង់នាំឯងម្នាក់ទៀតឱ្យបានបីនាក់ ដើម្បីទៅចាប់មនុស្សាណាំសម្លាញ់ ។

រុលម៉ាត : អូ! អញ្ចឹងសម្លាញ់ អញ្ចឹងយើងនាំគ្នាទៅ ។

*(ភ្លេងជើត)*

ទសរថ+ហុក : នែ៎! សម្លាញ់យើងមកដល់ពាក់កណ្ដាលព្រៃហើយដូចជាមិនឃើញមនុស្សានោះសោះណាសម្លាញ់ ។

កាលហុក : នោះន៎! គឺមនុស្សា នឹងហើយណាំសម្លាញ់ដែលយើង ពឹងឯងមកជួយចាប់យើងនោះណាំសម្លាញ់ ។

ទសរថ : បើអញ្ចឹងយើងសូត្រមន្តវិជ្ជាការសណ្ដំកុមារនេះឱ្យលង់លក់ ដើម្បីចាប់កុមារនេះយកទៅចងឆ្កាងនៅកណ្ដាលព្រៃណាំសម្លាញ់ ។

*(ភ្លេងរូ ជើត)*

ទសរថ : នែប៊ូសកុស្សរ៉ាអូន អូនប្រាប់ឱ្យសេនា ភិលៀងយកព្រះស្ងោយ និងភេសជ្ជៈមកឱ្យមិត្តសម្លាញ់យើងសោយឱ្យបានឆ្ងាញ់ម្ដង ។

ប៊ូសកុស្សរ៉ា : អើ! សេនា ភិលៀង ឯងយកព្រះស្ងោយផ្លែផល្លា និងគ្រឿងភេសជ្ជៈ ជប់លៀងសម្លាញ់ព្រះស្វាមីយើងឱ្យសប្បាយម្ដងណាំ ។

ភិលៀង : ព្រះមែម្ចាស់ នេះព្រះស្ងោយ, ផ្លែផល្លា និងគ្រឿងភេសជ្ជៈក្រាបទូល។

ប៊ូសគុស្សរ៉ា : អើ! ល្អហើយ ទុកត្រង់នេះចុះណ៎ា ។

ទសរថ : អើ! នែវើយសេនា ។

សេនា : កូណាថ្លៃវិសេសក្រាបទូល ។

ទសរថ : នែ៎! សេនាឯងយកមួយគុទៅសប្បាយជាមួយនឹងភិលៀងទៅណា ។

សេនា : កូណាថ្លៃវិសេសក្រាបទូល ។

*(ភ្លេងសែនឡាវ)*

ភិលៀង : នែ៎! បងសេនាម្ចាស់យើងថ្ងៃនេះមានរវល់ការអីបានជារៀបចំពិធីអឹកធឹកម្ល៉េះបង?

សេនា : យី! បងភិលៀងឯងអត់ដឹងរឿងអីមែនឬ?

ភិលៀង : ពិតមែនហើយបង ខ្ញុំអត់ដឹងរឿងអីទេណ៎ាបង ។

សេនា : ម្ចាស់យើងចាប់បានមនុស្សម្នាក់ ចងឆ្កាងនៅកណ្តាលព្រៃឯណោះស្អាតអើយស្អាតណ៎ាបង ។

ទសរថ : នែ៎! សេនាល្មមពេលសម្រាកហើយណ៎ាសេនា ។

សេនា : កូណាថ្លៃវិសេសក្រាបទូល ទូលបង្គំទៅហើយ ។

ទសរថ : នែ៎! សម្លាញ់យើងក៏ល្មមពេលសម្រាកដែរហើយណ៎ាសម្លាញ់ ។

កាលហុក : អើ! ទៅក៏ទៅចុះណ៎ាសម្លាញ់ ។

*(សំពះទស្សនិកជន) ភ្លេងស្មើ(ស្មី) ដើក*

បូរណី : ខ្ញុំព្រះនាមថាបូរណី ខ្ញុំបានប្រើភិលៀងទៅយកការពីសេនាមិនដឹងបានការដូចម្តេចទេ... ។

ភិលៀង : ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំព្រះនាង ។

បូរណី : អើ! ល្អហើយបងភិលៀង យើងប្រើឱ្យឯងទៅស៊ើបការ តើបានការយ៉ាងណាដែរភិលៀង ។

ភិលៀង : ព្រះមែម្ចាស់ ព្រះបិតាម្ចាស់បានចាប់មនុស្សាចងឆ្កាងទុកចោលកណ្តាលព្រៃ មានរូបរាងស្អាតអើយស្អាតណ៎ាម្ចាស់ ។

បូរណី : ពិនមែន! បងភិលៀង ។

ភិលៀង : ព្រះមែម្ចាស់ ពិតមែនណ៎ាម្ចាស់ ។

បូរណី : បើអញ្ចឹង បងរកកន្លែងសម្រាកចុះណ៎ាបង ។

ភិលៀង : ព្រះមែម្ចាស់ ។

បូរណី : ខ្ញុំបានឮភិលៀងនិយាយប្រាប់ហើយ ខ្ញុំដូចជាអាណិតអាសូរដល់ព្រះអង្គណាស់ បើអញ្ចឹងខ្ញុំទៅជួយព្រះអង្គសិន ។

*(ព្រះអង្គជ័យសែនចេញមុន) (ភ្លេងជើត)*

បូរណី : ខ្ញុំធ្វើដំណើរដល់ពាក់កណ្តាលព្រៃហើយ ដូច្នេះខ្ញុំផ្សង នឹងស្បៃ បើស្បៃនេះរសាត់ទៅដល់ព្រះអង្គ១ជាគូស្វាមីរបស់ខ្ញុំហើយ បើអញ្ចឹងខ្ញុំផ្សងសិន ។

*(ភ្លេងរូ)*

បូរណី : ឥឡូវនេះព្រះអង្គជាគូស្វាមីរបស់ខ្ញុំហើយ បើអញ្ចឹងខ្ញុំចូលទៅជួយព្រះអង្គសិន ។

ច្រៀង : (បទចៅដក) លំនាំបទឡាំតាត់ នាងមាសមើលទៅឯកើតស្នេហ៍ចំពោះឃើញអង្គដាក់ភ័ក្ត្រាអើយ ។

*(សាច់ភ្លេង)*

បូរណី : ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំព្រះអង្គ តើព្រះអង្គព្រះនាមអ្វីដែរព្រះអង្គ ។

ជ័យសែន : ទូលបង្គំព្រះនាមជ័យសែន ចុះព្រះនាងវិញមានព្រះនាមអ្វីដែរទៅ បានជាមកជួយយកអាសាទូលបង្គំដូច្នេះណ៎ាព្រះនាង ។

បូរណី : ខ្ញុំម្ចាស់ព្រះនាមថាបូរណី ក្រាបទូល ។ ដោយខ្ញុំម្ចាស់យល់ថាព្រះបិតាខ្ញុំម្ចាស់មានទឹកព្រះទ័យមិនល្អទើបខ្ញុំម្ចាស់មកជួយព្រះអង្គណ៎ាក្រាបទូល។

ជ័យសែន : អូ! អញ្ចឹងហ្អែសព្រះនាង ។ ទូលបង្គំសូមអរគុណហើយណ៎ា ។

បូរណី : ក្រាបទូលព្រះអង្គ បើអញ្ចឹងព្រះអង្គស្តេចយាងទៅជាមួយខ្ញុំម្ចាស់ទៅណ៎ាព្រះអង្គ ។

ជ័យសែន : អើ! ល្អហើយអូន។

(រូ+ភ្លេងជើក)

បូរណី : ឥឡូវព្រះអង្គយាងមកដល់ប្រាសាទខ្ញុំម្ចាស់ហើយ ដូច្នេះព្រះអង្គនៅផ្ទឹមជាមួយនឹងខ្ញុំម្ចាស់ហើយណាំក្រាបទូល ។

ច្រៀង : (បទត្លុំ) ស្ដេចត្រូវកំសួល ស្ដេចត្រូវកំសួលវ៉ា ព្រះពាយត្រសៀកផាត់ផាយក្លិនបុប្ផា ។

(សាច់ភ្លេង) (ភ្លេងក្រាស់ណាន)

ភិលៀង(ទី១កន្តណាស៊ុ) នែ៎! បងព្រះសូរិយាកាន់តែខ្ពស់ណាស់ហើយ យើងយកទឹកទៅស្រប់ព្រះភ័ក្ត្រាព្រះនាងណាំបង ។

ភិលៀង(ទី២ព្រីវ៉ាន់) នែ៎! បងខ្ញុំដូចជាឆ្ងល់ណាស់ សព្វដងថ្មើរណេះព្រះនាងតើនរួចស្រេចទៅហើយ ហេតុអ្វីក៏ថ្ងៃនេះព្រះនាងនៅតែមិនទាន់តើនទៀតបង។

ភិលៀងទី១ : ពិតមែនហើយបង ។ អញ្ចឹងយើងនាំគ្នាចូលទៅមើលមើល៍ ។

(សកម្មភាពភិលៀង)

ភិលៀងទី២ : នែ៎! បងៗមើលឃើញច្បាស់ដែរឬទេ ខ្ញុំមើលដូចជាមិនច្បាស់សោះ។

ភិលៀងទី១ : ខ្ញុំក៏អញ្ចឹងដែរណាំបង ។

ភិលៀងទី២ : អើ! នាយជុយ ។

នាយជុយ : មានការអីចាំ!

ភិលៀងទាំង២: នែ៎! នាយជុយ ឯងចូលទៅមើលព្រះនាងម្ដងទៀតមើល យើងដូចមើលមិនច្បាស់សោះណាំនាយជុយ ។

នាយជុយ : នែ៎! បង ខ្ញុំមិនហ៊ានចូលទៅទេបងភិលៀងចូលមើលម្ដងទៀតចុះ ។

ភិលៀង : នែ៎! បង រឿងនេះមិនស្រួលទេ ម្ចាស់យើងមានជើងដល់ទៅបួនហើយក្បាលដល់ ទៅពីរឯណោះណាំបង ។

ភិលៀងទាំង២: នែ៎! នាយជុយ រឿងនេះមិនកើតទេ ស្រួលមិនស្រួលកំបុតក្បាលទាំងអស់គ្នាហើយណាំបង ។

នាយជុយ : បើអញ្ចឹងយើងទៅទូលព្រះបិតាព្រះនាងឱ្យលោកទ្រង់ជ្រាបផងទើបបាន ។

*(ភ្លេងដើត)*

*(សកម្មភាពបូរណី+ជ័យសែនភៀសព្រះកាយចូលព្រៃ) (កន្ទុយភ្លេងមាតាបិតាចូល)*

យក្សទសរថ : នែ៎! នាយជុយមានរឿងហេតុអ្វីបានជាភ័យស្លន់ស្លោម៉្លេះ?

នាយជុយ : ក្រាបទូលម្ចាស់ៗ ព្រះនាងមានស្វាមីហើយក្រាបទូល ។

ទសរថ : យើស! នាងបូរណីចិត្តធំថ្លើមធំ ហ៊ានយកប្ដីចិត្តឯងផង... ។

មហេសីទសរថ : ក្រាបទូលព្រះស្វាមី កុំយកទោសពៃរ៍នឹងបុត្រអីក្រាបទូល អាណិតខ្ញុំម្ចាស់ផងណ៎ាព្រះស្វាមី ។

ទសរថ : ហ៊ុះ! មិនបានទេមហេសីអូនៗ នៅចាំនគរហើយបងនាំសម្លាញ់បងទៅចាប់វាមកវិញឱ្យទាល់តែបានណ៎ាមហេសីអូន សូមអូនកុំព្រួយព្រះទ័យអី ។

ទសរថ : នែ៎! សម្លាញ់យើងនាំគ្នាទៅចាប់អាមនុស្សានោះយកមកវិញឱ្យបានណ៎ាសម្លាញ់ ។

*(ដើត+ឱត)*

សាឡីបុប្ផា : បុត្រសូមក្រាបថ្វាយបង្គំ ព្រះមាតា ព្រះបិតា។

យក្សនព្វវង្ស : អើ! ល្អហើយបុត្រ តើបុត្រមានរឿងអ្វីដែរបានជាព្រះកន្សែងដូច្នេះបុត្រ ។

សាឡីបុប្ផា : ក្រាបទូលព្រះបិតាៗមិនដឹងថាបុត្រមានទឹកព្រះទ័យព្រួយប៉ុណ្ណាទេក្រាបទូល។

នព្វវង្ស : អើ! មានរឿងអីទៅបុត្រ ។

សាឡីបុប្ផា : ក្រាបទូលព្រះមាតាព្រះបិតា ព្រះស្វាមីទូលបង្គំថាលាបុត្រទៅរៀនសីលតែមួយរយៈទេហេតុអីក៏មិនឃើញព្រះអង្គស្ដេចយាងត្រឡប់មកវិញសោះក្រាបទូល ។ បុត្រសូមឱ្យព្រះបិតាជូនបុត្រទៅរកព្រះស្វាមីខ្ញុំម្ចាស់ហើយក្រាបទូល ។

នព្វវង្ស : អើ! មិនអីទេណ៎ាបុត្រ ចាំបិតាជូនបុត្រទៅ ។ នែ៎! មហេសីអូនយើងនៅមានមិត្តម្នាក់ទៀតឈ្មោះវណ្ណរាជ្យគេប្រាប់យើងថា បើមាន

រឿងអ្វីឱ្យនឹកដល់គេៗនឹងមកជួយយើងភ្លាមណាំអូន ។

សូផាណា : អូ! អញ្ជើងព្រះស្វាមី ។

នព្វវង្ស : ឱសម្លាញ់អើយ យើងសូមនឹករលឹកដល់ឯងសូមឯងជួយយើងភ្លាមណាំសម្លាញ់ ។

*(ភ្លេងរូ+ជើត)*

វណ្ណរាជ្យ : នែ៎! សម្លាញ់ឯងមានរឿងអី បានជាឯងនឹករលឹកដល់យើង ។

នព្វវង្ស : អើ! សម្លាញ់យើងចង់ពឹងឯងឱ្យទៅជួយរកបុត្រសុណិសារបស់យើងណាំសម្លាញ់ ។

សាទ្បីបុប្ផា : ក្រាបទូលព្រះបិតា សូមព្រះបិតាជូនបុត្រទៅរកព្រះស្វាមីបុត្រផងក្រាបទូល ។

វណ្ណរាជ្យ : អើ! មិនអីទេបុត្រ ចាំបិតាជូនទៅណាំបុត្រ ។

នព្វវង្ស : នែ៎! មហេសីអូននៅចាំនគរហើយបងនឹងសម្លាញ់ជូនបុត្រទៅរកជ័យសែនណាំអូន ។

សូផាណា : ព្រះពរព្រះស្វាមី ស្តេចយាងចុះក្រាបទូល ។

*(ភ្លេងជើត+ឱក) (បូរណី+ជ័យសែន មុន)*

សាទ្បីបុប្ផា : ព្រះអង្គស្តេចយាងទៅរៀនសីលអីក៏យូរម្ល៉េះ ព្រះអង្គខ្ញុំម្ចាស់នឹកព្រះអង្គសឹងតែស្លាប់ហើយក្រាបទូល ។

ជ័យសែន : ឱអូនអើយ! បងធ្វើដំណើរទៅនេះជួបឧបសគ្គច្រើនណាស់ កុំតែបាននាងបូរណីជួយយកអាសាបង ម្ល៉េះបងស្លាប់បាត់ទៅហើយណាំអូន។ នែ៎! បូរណីអូនថ្វាយបង្គំម្ចាស់បងឯងទៅណាំ ។

បូរណី : ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំម្ចាស់បង ។

សាទ្បីបុប្ផា : អើ! ល្អហើយម្ចាស់អូន ។

ជ័យសែន : ហើយនេះព្រះបិតារបស់បង ។

បូរណី : បុត្រសូមក្រាបថ្វាយបង្គំព្រះបិតា ។

នព្វវង្ស : អើ! ល្អហើយបុត្រ ។

*(ភ្លេងជើត)*

បូរណី : ក្រាបទូលព្រះបិតាកូនសូមក្រាបថ្វាយបង្គំព្រះបិតា ឱ្យកូនសុំទោសកូនបានជាខុសហើយ ។

ទសរថ : នែ៎! នាងបូរណីយើងគ្មានទោសពៃអីលើកលែងអោយនាងឯងទេ ថយចេញឱ្យឆ្ងាយទៅ ។

បូរណី : ព្រះបិតាៗ បុត្រសូមអង្វរកុំខឹងនឹងបុត្រអី ក្រាបទូល ។

ទសរថ : ហ៊ឺះ! នាងឯងចិត្តធំថ្លើមធំណាស់ហ៊ានយកប្ដីចិត្តឯង យើងមិនអត់អោនអោយឯងទេណា៎ ។

ច្រៀង : (បទនាងណាយ) អស់ឱបិតាម្ចាស់កូនអើយ អើយកូនបានជាខុសអើយៗ ព្រះបិតា។

*(សាច់ភ្លេង) (ភ្លេងឱត)*

បូរណី : ក្រាបទូលព្រះបិតា កូនបានជាខុសហើយ ឱ្យកូនសុំទោស ។

ទសរថ : នែ៎! នាងបូរណីយើងមិនអត់អោនឱ្យនាងឯងទេថយចេញឱ្យឆ្ងាយទៅ ។

ជ័យសែន : ក្រាបទូលព្រះបិតា ឱ្យកូនសុំទោស ។

ទសរថ : នែ៎! អាមនុស្សាឯងមិនបាច់សុំទោសយើងទេ ។ (ច្បាំងគ្នា)

ជ័យសែន : អញ្ចឹងបើព្រះបិតាមិនលើកទោសឱ្យបុត្រទេចាំទទួលសីល្ប៍ពីបុត្រចុះណា៎ព្រះបិតា ។

*(ភ្លេងជើត+ឱត)*

ទសរថ : នែ៎! បុត្រីបិតា បុត្រទូលស្វាមីបុត្រថា ឱ្យដោះលែងបិតាទៅ បិតាក្ដៅណាស់។

បូរណី : ក្រាបទូលព្រះបិតា ចាំបុត្រទូលថ្វាយ ។ ព្រះបិតាកុំព្រួយព្រះទ័យអី ។

បូរណី : ឱ! ព្រះស្វាមីអើយសូមព្រះស្វាមីដោះលែងព្រះបិតាទៅអាណិតប្អូនផង ។

ជ័យសែន : អើ! មិនអីទេមហេសីអូន ។ បើអញ្ចឹងខ្ញុំសូមបបួងសួងនឹកដល់ព្រះ

ឥន្ទ្រាធិរាជ សូមឱ្យខ្ញុំស្រាយចំណងបានដូចសេចក្តីប្រាថ្នា ។

*(ភ្លេងរូ)*

ជ័យសែន : ក្រាបទូលព្រះបិតា ព្រះបិតាឈប់ខឹង នឹងកូនហើយឬ?

នព្វវង្ស : អើ! ព្រះបិតាឈប់ ខឹងនឹងកូនហើយ ។

ជ័យសែន : ក្រាបទូលព្រះបិតា ឥឡូវយើងជួបជុំគ្នាអស់ហើយ បើអញ្ជើងសូមព្រះបិតាជូនបុត្រត្រឡប់ទៅនគរវិញផងណ៎ាព្រះបិតា ។

ទសរថ : អើ! មិនអីទេបុត្រ ចាំបិតាជូនបុត្រទៅណ៎ាបុត្រ ។

ជ័យសែន+សាឡីបុប្ផា+និងបូរណី... ស្តេចយាងក្រាបទូល។

*(ភ្លេងជើត)*

*រឿងជ័យសែន សូមស្លេះត្រឹមប៉ុណ្ណោះ!*



ស្ពានកំពង់ក្តី




កំណត់ត្រាដោយរូបភាព
"រឿងជ័យសែន"
(សំដែងនៅសាលចតុមុខ)

សាលមហោស្រពចតុម្មុខបានឱ្យកិត្តិយសទៅក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅ សំដែងជាលើកទី១ នៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩៩ ក្រោយពីទម្រង់ល្ខោននេះ បាត់បង់ការសំដែងរយៈពេលជិត ៥០ឆ្នាំ





ការតុបតែងកាយរបស់សិល្បការិនីល្ខោនពោលស្រី នៅរោងប្របមាត់ទន្លេ
ក្រៅរោងមហោស្រពចតុម្មុខ ។





- ការរៀបចំថតរូបភាព រឿងជ័យសែន មុនរៀបចំការសំដែងនៅសាលចតុម្មុខ ។
- នេះជារូបភាពរឿងជ័យសែន ដែលបានស្លៀកសម្លៀកបំពាក់ និងតុបតែងគ្រឿងអលង្ការទី១ នៅអតីតរោងល្ខោនពោលស្រី វត្តកៀនស្វាយក្រៅ ។

ផ្ទាំងតាប្លូរៀបចំសម្តែងល្ខោនពោលស្រីនៅសាលចតុមុខ





ការសំដែងល្ខោនពោលស្រីនៅសាលចតុម្មុខ ត្រង់ឈុតក្នុងវាំងស្តេចយក្សនព្វវង្សលា មហេសីសុផាណា និងបុត្រីសាឡីបុប្ផាទៅក្រសាលព្រៃព្រឹក្សា

លោកយាយគ្រូចាស់ៗសប្បាយរីករាយក្នុងចិត្តឥតឧបមា ដោយបានផ្ទេរចំណេះដឹងរបស់គាត់គឺក្បាច់ល្ខោនពោលស្រី និងវិធីការងារទាំងអស់ក្នុងការរៀបចំទស្សនីយភាពសំដែងល្ខោនពោលស្រីឱ្យក្មេងជំនាន់ក្រោយ (១)យាយ យឹន (២)យាយ មាស ហូ (៣)យាយ សាន់ យឹន (៤)យាយ ជា មុត ( អង្គុយទស្សនាល្ខោនពោលស្រីសំដែងជាកិត្តិយសក្នុងរោងមហោស្រពចតុម្មុខ )






(១)លោក.........ប្រធានភូមិ (២)លោកតា...........ត្រូវជាជីតារបស់ជ័យសែនកាលនៅពីកុមារ ។ លោកទាំងពីរតាមមកមើលចៅរបស់គាត់ និងសិល្បការិនីជំនាន់ក្រោយរបស់ក្រុមល្ខោនពោលស្រីវត្តកៀនស្វាយក្រៅសំដែងនៅសាលចតុម្មុខ

-ជាមួយគ្នាពេលនោះ (១)ឯកឧត្តម ពេជ្រ ទុំក្រវិល តំណាងឱ្យក្រសួងវប្បធម៌ (២)លោក ជិន ណៃ ជនជាតិជប៉ុនតំណាងខាង **UNESCO** (៣)លោក ហង្ស សុត ប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព (៤)លោក សុខ អឿន ប្រធានមន្ទីរវប្បធម៌ ខេត្តកណ្ដាល (៥)លោក ............... អនុប្រធានមន្ទីរវប្បធម៌ ខេត្តកណ្ដាល ក៏មានវត្តមានជាកិត្តិយសក្នុងឱកាសនោះដែរ ។





ជ័យសែន លាមាតាបិតា
ទៅរៀនសិល្ប៍មន្តវិជ្ជាការ

ជ័យសែនឈប់សម្រាកក្រោមដើមឈើធំមួយ ក្រោយពីបានចាប់សត្វព្រៃមកអាំងឆ្អើរចម្អែតផ្ទៃ





ស្តេចយក្សឈ្មោះ នព្វវង្ស មកដាក់មន្តសណ្តំជ័យសែន លួចយកមំសាអស់
យកទៅផ្ញើមហេសី និងបុត្រី ហើយក៏ត្រឡប់មកចាប់ជ័យសែនម្តងទៀត



ការសម្តែងរិទ្ធរបស់ស្តេច
យក្សនព្វវង្ស



ស្តេចយក្សនព្វវង្ស យាងចេញពីនគរចូលក្នុងព្រៃព្រឹក្សា (បញ្ហានេះមានទំនាក់ទំនងក្នុងបច្ចេកទេសនៃការដឹកនាំរឿង គឺដំណើររឿងវិវឌ្ឍន៍ ទីតាំងដដែល ដឹកនាំរឿងបែបល្ខោនរាប់រឿង)

ព្រះឥន្ទ្រប្រទានរបស់ទិព្វដល់ជ័យសែន ទាំងពីរអង្គច្បាំងគ្នា ស្តេចយក្សចាញ់ជ័យសែន ក៏ពរជ័យសែនហោះទៅនគរ លើកនាងបុត្រីឱ្យជាមហេសី





នាង សាឡី បុប្ផា
បុត្រីស្តេចយក្សនព្វវង្ស



ការបួរត្តរជ័យសែន
ពីតូចមកធំ ស្តេចនាំ
មហេសីក្រសាលសួន



ការរៀបរាប់លម្អបុប្ផាជាតិ



សុភមង្គលរបស់
ព្រះអង្គជ័យសែន
និងព្រះនាង សាឡីបុប្ផា



ស្ដេចយក្សឈ្មោះ វណ្ណរាជ្យ
មិត្តភក្តិស្ដេចយក្ស នព្វវង្ស
រៀបព័ស្តុភារបណ្ណាការមកស្ដី
ដណ្ដឹងនាង សាឡីបុប្ផា

ព្រះនាងសូផាណា និងស្ដេចយក្សនព្វវង្សរៀបទ័ពតទល់ និងស្ដេចយក្សវណ្ណរាជ្យ
ដោយមានការគំរាមលើកទ័ពមកកម្ទេចព្រះនគរ ព្រោះព្រះអង្គលើកបុត្រីឱ្យ
មានព្រះស្វាមីរួចទៅហើយ





ការទល់ទ័ពរវាងក្រុងមារទាំងពីរ (ដោយព្រះអង្គជ័យសែនមានអាវុធទិព្វសង្គ្រាមក៏ត្រូវបានបញ្ចប់) ស្ដេចយក្សវណ្ណរាជ្យសុំជ័យសែន ធ្វើជាកូនចិញ្ចឹមបើព្រះអង្គមានភ័យអាសន្នសូមបបួងសួងនឹកដល់ព្រះនាមស្ដេចវណ្ណរាជ្យ ស្ដេចនឹងយាងទៅជួយយកអាសាភ្លាម

ព្រះអង្គជ័យសែន សុំផ្ញើមហេសីសាឡីបុប្ផា និងព្រះបិតាព្រះមាតាដោយស្ដេចបន្ដដំណើរទៅរកលោកតាឥសី ដើម្បីរៀនសិល្បមន្តវិជ្ជាការ





ព្រះអង្គជ័យសែន ជួបស្វាពានរុងពុងនរាច្បាំងគ្នា ស្ដេចចងស្វាទាំងពីរដោយចំណងសិល្ប៍ទិព្វ ទើបស្វាទាំងពីរព្រមនាំជ័យសែន ទៅជួបព្រះមុនីឥសី



ព្រះអង្គជ័យសែន ក្រោយពីរៀនមន្តវិជ្ជាចប់សព្វគ្រប់ ក៏លាព្រះមុនីឥសីត្រឡប់ទៅនគរដោយលោកតា ជបពាជីមួយថ្វាយ និងថ្វាយពានរុងពុងនរា ជាសេនាហែរហមអមអង្គ



នាងបូរណី បុត្រីស្ដេចយក្ស ទសរថផ្សងស្នេហ៍ទៅជួយព្រះអង្គជ័យសែន រំដោះព្រះអង្គជ័យសែន ដែលយក្សទសរថចងឱ្យស្លាប់កណ្ដាលព្រៃ



ព្រះនាងបូរណី បង្ហាញសម្រស់របស់ព្រះនាង



-ព្រះនាងបូរណីនាំព្រះអង្គជ័យសែនចូលក្រឡាបន្ទំ
-ក្បាច់នេះជាក្បាច់ពិសេសបង្ហាញពីការស្រឡាញ់បំផុតស្នេហាស្រួចស្រាល់របស់ទម្រង់ល្ខោនពោលស្រី

ព្រះនាងបូរណី និងព្រះអង្គជ័យសែនផ្ទិលក់ស្កប់ស្កល់ក្នុងក្រឡាបន្ទំ





ព្រះនាង សាឡីបុប្ផ និង ព្រះអង្គ ជ័យសែន ស្ន៉ែគ្រ សុខចិត្តសុខកាយរួមរស់ជាបីអង្ការ



ព្រះនាងបូរណីថ្វាយបង្គំព្រះនាងសាឡីបុប្ផ (មហេសីទី១របស់ព្រះអង្គជ័យសែន) ស្ន៉ែគ្រស្នេះព្រមព្រៀងរួមរស់ជាមួយគ្នាជាដរាបរៀងទៅ



ព្រះអង្គជ័យសែន មានព្រះទ័យត្រេកអរយ៉ាងក្រៃលែង ចំពោះព្រះនាង សាទ្បីបុប្ផា ដែលមានអធ្យាស្រ័យល្អ ចំពោះព្រះអង្គ និងព្រះនាង បូរណី

លោកយាយគ្រូល្ខោនពោលស្រីវាយក្រាប់បន្ទរជាចង្វាក់នៅលើឆាកមុខ
អង្គរវត្ត ខេត្តសៀមរាប (ឆ្នាំ២០០០ បុណ្យឆ្លងសហស្សវត្សរ៍)





សិល្បការិនីល្ខោនពោលស្រី រាំរបាំ "ជីវភាពភូមិយើង" ក្នុងកម្មវិធីសិល្បៈលើទឹកដីអង្គរ (ហាត់សមនៅឆាកមុខអង្គរ)

ក្នុងរបាំជីវភាពភូមិយើង ក៏មានក្បាលផ្ដើមជារឿង ជ័យសែនផងដែរ (ហាត់សមនៅឆាកមុខអង្គរ)





## ប្រវត្តិរូប

**ភាគ១៤១**

លោកសាស្ត្រាចារ្យ **ចិន្ត នាគ** ឯកទេសល្ខោននិយាយ

-ជាអ្នកនិពន្ធរឿងល្ខោន (ពាក្យសំរាយ ឬ ជាកំណាព្យ) ។

-ជាអ្នករៀបរៀងពាក្យពេចន៍អត្ថបទរឿងល្ខោនជាពាក្យរាយ ឬ ជាកំណាព្យ (យករឿងចាស់មករៀបរៀងពាក្យពេចន៍អោយតួសម្តែង) ។

-ជាអ្នកដឹកនាំរឿង(ល្ខោកលើឆាក និង វីដេអូ) ។

-ជាអ្នកសម្តែង(សិល្បករល្ខោនលើឆាក វីដេអូ និងខ្សែភាពយន្ត) ។

-ជាអ្នករិះគន់សិល្បៈ (គណៈកម្មការត្រួតពិនិត្យសិល្បៈអន្តរក្រសួង) ។

-ជាសាស្ត្រាចារ្យបង្រៀនថ្នាក់ឧត្តម (បរិញ្ញាប័ត្រសិល្បៈ) និងថ្នាក់មធ្យមអំពីទ្រឹស្តីល្ខោន និងអនុវត្តជាក់ស្តែងលើឆាក នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

-ជាអ្នកស្រាវជ្រាវចងក្រងឯកសារទម្រង់ល្ខោនខ្មែរ ប្រវត្តិល្ខោនខ្មែរ និងចងក្រងឯកសារវិធីសាស្ត្របង្រៀនបច្ចេកទេស សិល្បៈល្ខោនវិនោទកម្មខ្មែរ ។

-ជាសាស្ត្រចារ្យឧទ្ទេសនាម អញ្ជើញធ្វើបវកថាតាមមូលដ្ឋានសាលារៀនតាមបណ្តាខេត្តក្រុងនានា ស្ថិតក្នុងសមាជិកគណៈកម្មការស្រាវជ្រាវវប្បធម៌សិល្បៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

-ជាប្រធាននាយកដ្ឋានរង ទទួលបន្ទុកល្ខោនគ្រប់ទម្រង់ទូទាំងប្រទេសនៅអង្គភាពនាយកដ្ឋានសិល្បៈទស្សនីយភាព ។

-ជាស្ថាបនិកក្រុមល្ខោនមួយរូប បង្កើតបានក្រុមល្ខោនពោលស្រីមួយវង់ឲ្យរស់ឡើងវិញនៅ វត្តកៀនស្វាយក្រៅ ឆ្នាំ ១៩៩៤-២០០០ (បន្ទាប់ពីទម្រង់ល្ខោននេះស្លាប់បាត់បង់ការសម្តែងអស់ជិតរយៈពេល ៥០ឆ្នាំ) និងល្ខោនកំណាព្យមួយក្រុមនៅក្លិបសិល្បៈឯកជនមួយអោយរស់ជាថ្មាំងទស្សនីយភាពដែរ (ល្ខោនកំណាព្យស្លាប់ជាង ៣០ឆ្នាំ) ។

-ជាអ្នកស្ថាបនាវណ្ណកម្មខ្សែវីដេអូ ចម្រៀងកាយវិការ វីស៊ីឌី ឌីវីឌីខារ៉ាអូខេ រឿងកំប្លែង

ខ្ញីៗ កាលណោះក្នុងនាមជាចាងហ្វាងផលិតកម្ម នាគរាជ្យភាពយន្ត ។
-ជាជំនាញការកម្ពុជា ប្រចាំក្រសួងវប្បធម៌ឡាវ ទីក្រុងវៀងច័ន្ទ ទៅធ្វើការក្នុងរយៈពេល ១ឆ្នាំ (១៩៨៥) បង្រៀនការសម្តែង និង ដឹកនាំរឿងធំ មានសិល្បករ សិល្បការិនី ៣៥០នាក់ ចូលរួមដើម្បីរំលេចប្រវត្តិសាស្ត្រជាតិឡាវ គឺរឿងដំណើរជាតិឡាវ។
-ជាស្ថាបនិកសាលាល្ខោនជាតិកម្ពុជា (ល្ខោននិយាយ) លើកទី២ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ (កាលនោះ ជាប្រធានសាលាល្ខោន សាលារបាំ និង សាលាសៀក)។
-ជាសិល្បករឯកមួយរូប (ផ្នែកល្ខោននិយាយ) ក្នុងចំណោមតួឯកប្រុស ៣-៤ របស់ក្រុមល្ខោនជាតិនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (តួអង្គព្រះវេស្សន្តរ តួលីហ្សាន់ជី តួរ៉ូមេអូ តួព្រះបាទព្រហ្មទត្ត តួឯកប្រុស តួភ្នីកង់) ។
-ជាគណៈមេប្រយោគ វាយតម្លៃស្នាដៃតែងនិពន្ធប្រលោមលោក ស្នាដៃកំណាព្យ ស្នាដៃនិពន្ធរឿងល្ខោន និងស្នាដៃទស្សនីយភាពល្ខោនលើឆាកគ្រប់ទម្រង់ ក្នុងមហោស្រពសិល្បៈ និងមហោស្រពតែងនិពន្ធ ។
-លោក ចិន្ត នាគ កើតក្នុងត្រកូលកសិករក្រីក្រ កូនរាស្ត្រសាមញ្ញ នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៤៦ នៅភូមិកុងស៊ី ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

-ឪពុកឈ្មោះ ចិន្ត ទួន (ស្លាប់)

-ម្តាយឈ្មោះ ង៉ាន សុខហ៊ី ឆ្នាំ១៩២៥ កសិករភូមិខ្សាច់ក្រោម ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

-ក្រោយពីលោកឪពុក ចិន្ត ទួន ទទួលមរណភាពទៅ អ្នកម្តាយបានរួមរស់ជាមួយលោកឪពុកទីពីរ ឈ្មោះ ជិញ លី ឆ្នាំ ១៩២៤ កសិករភូមិខ្សាច់ក្រោម ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

-លោក ចិន្ត នាគ មានបងប្អូនប្រុសស្រីរួមម្តាយតែមួយ ចំនួន ១០ រូប :

១-លោក ចិន្ត នាគ បុត្រច្បងក្នុងគ្រួសារ

២-អ្នកស្រី ចិន្ត មុយហ៊ាង (កសិករ)

៣-លោក ចិន្ត ចាន់ហោ (ស្លាប់)

៤-លោក ចិន្ត ស៊ីវអេង (ស្លាប់)

៥-លោក ចិន្ត សម្បត្តិ (ស្លាប់)

៦-លោក ជិញ សុប្រាក់ (ស្លាប់)

៧-នាង ជិញ សុខសាន្ត (កសិករ)

៨-នាង ជិញ បុណ្យហ៊ី (កសិករ)

៩-នាង ជិញ សាវុធ (កសិករ)

១០-នាង ជិញ ចន្ធូ (កសិករ)

-លោក ចិន្ត នាគអាយុ ៥ឆ្នាំ ជីតាឈ្មោះ ទ្រី ង៉ាន ជាគ្រូទស្សន៍ទាយ និងជាគ្រូហ្មព្យាបាលតាមបែបឱសថបុរាណ ជាគ្រូមានឈ្មោះល្បីល្បាញទូទាំងភូមិឃុំស្រុក បានយកទៅឱ្យនៅវត្តរៀនសូត្រ ក្នុងសំណាក់លោកគ្រូ ទុយ ស៊ុំ (វត្តក្រូចឆ្មារក្រោមហៅវត្តកញ្ចក់) ចេះលេខអក្សរមើលសាស្ត្រាបាន (រឿងចៅស្រទបចេក រឿងមរណមាតា)។ អាយុបាន ៨ ឆ្នាំ មកនៅជាមួយលោកមា ទ្រី ហេងជី បួសនៅវត្តសិរីទ្ធជោគ ហៅវត្តព្រះអង្គខ្មៅ ភូមិកោះសិរិទ្ធ ឃុំចុងកោះសំរោង ស្រុកកំពង់ចាម សិក្សាលេខអក្សរក្នុងសំណាក់លោកគ្រូ ធាម មកប្រឡងចូលរៀនថ្នាក់អាទិកដ្ឋាននៅទីរួមខេត្តកំពង់ចាមធ្លាក់ក៏ត្រឡប់ទៅរៀននៅសាលាវត្តក្រូចឆ្មាក្រោមវិញ ក្នុងសំណាក់លោកគ្រូ ផុន និងលោកគ្រូ នី ។ អាយុបាន ៩ ឆ្នាំ លោកគ្រូ ផុន បានជួយជ្រោមជ្រែង ធ្វើបញ្ជីជាតិកំណើត (សំបុត្រកំណើត) អោយហើយ បានប្រឡងចូលសាលារាជការថ្នាក់អាទិកដ្ឋានក្នុងសំណាក់លោកគ្រូ ជ្រុយ សាលាបឋមសិក្សាក្រូចឆ្មារ ។ លោកគ្រូ ហេង អ្នកគ្រូចន លោកគ្រូ ស រៀនរហូតចប់ថ្នាក់ឧត្តមដ្ឋាន លោកគ្រូ ម៉ូវ ប្រឡងចូលសាលាជិនាញ (សាលាដែក) ខេត្តកំពង់ចាមធ្លាក់ ។ អាយុ ១៣ឆ្នាំ មកនៅជាមួយមា (កូនចិញ្ចឹមកុង ទ្រី ង៉ាន) ឈ្មោះ គូ ជលីម រៀនផង ធ្វើនំបុ័ងផង ថ្នាក់ទី៦ ទំនើបជាតិទី៥ ទំនើបជាតិ ទី៤ ទំនើបជាតិ និងទី៣ ទំនើបជាតិ ប្រឡងចូលទៅរៀននៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ប្រឡងឌីប្លូម ( **D.E.S.P.C** ) ធ្លាក់លើកទី១ លើកទី២ មកប្រឡងនៅភ្នំពេញម្តងទៀត តែលោក ចិន្ត នាគ មកប្រឡងចូលសាលា

ជាតិផ្នែកល្ខោន ជាប់ជាសិស្សជំនាន់ទី ៥ (ឆ្នាំសិក្សា ១៩៦២-១៩៦៣) ។ ក្នុងអាយុ ១៨-១៩ ឆ្នាំ (១៩៦២-១៩៦៣) ត្រឡប់មកភ្នំពេញវិញ រៀននៅសាលាល្ខោនជាតិ ក្រោយមកជាមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ស្ថាក់នៅវត្តសារាវន្តតេជោ ក្នុងសំណាក់គ្រូ ឈាង ប៊ុនធន មេកុដលេខ៩) ឆ្នាំ ១៩៦៦-១៩៦៧ ជាប់សញ្ញាប័ត្រសិល្បៈ ( **Diplome es art** ) ។

-ឆ្នាំ ១៩៦៧-១៩៦៨ ចេញធ្វើជាគ្រូបង្ហាត់សិល្បៈនៅអភិរក្សមន្ទីរជាតិ នៃទស្សនីយភាពទីក្រុងភ្នំពេញ ជាសមាជិកក្រុមល្ខោនជាតិ នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

-ឆ្នាំ ១៩៧០ ខែ តុលា លោក ចិន្ត នាគ អាយុ ២៥ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា ម៉ុញ យុន បានកូនប្រុស ១ ចិន្ត ច័ន្ទរដ្ឋា ស្រី ១ ចិន្តច័ន្ទធីតា ។

-ឆ្នាំ ១៩៧១-១៩៧២ លោក ចិន្ត នាគ ដាក់ពាក្យសុំចូលរៀន ភូមិសិក្សាទី ២ សិល្បៈជាប់ស្នាតកប័ត្រសិល្បៈ ឆ្នាំសិក្សា ១៩៨១-១៩៨២ ប្រកាសជាសាស្ត្រាចារ្យសិល្បៈល្ខោន ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៨២ (ឯកទេសល្ខោននិយាយ) ដោយក្រសួងអប់រំ និងក្រសួងឃោសនាការវប្បធម៌ និងព័ត៌មានកម្ពុជា ។

-លោក ចិន្ត នាគ និងអ្នកស្រី ម៉ុញ យុន មានបុត្រចំនួន ៤ រូប :

១-លោក ចិន្ត ច័ន្ទរដ្ឋា ស្លាប់ក្នុងអាយុ ៣២ ឆ្នាំ (២០០៣)

២-នាង ចិន្ត ច័ន្ទធីតា ស្លាប់ក្នុងអាយុ ២១ ឆ្នាំ (១៩៩២)

៣-លោក ចិន្ត ច័ន្ទរតនា (០៩/០៤/១៩៨០) និស្សិតថ្នាក់ទីបញ្ចប់បរិញ្ញាប័ត្រមហាវិទ្យាល័យបុរាណវិទ្យា (អនុបណ្ឌិតនៅប្រទេសបារាំង-សិល្បៈខ្មែរ) ។

៤-កញ្ញា ចិន្ត ច័ន្ទស៊ីដា (១១/១១/១៩៨៦) និស្សិតឆ្នាំទី ៤ បរិញ្ញាប័ត្រសិល្បៈមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ។

-ឆ្នាំ ១៩៧៥-១៩៧៩ លោក ចិន្ត នាគ រស់នៅជាទាសករដូចប្រជាជនកម្ពុជា ទូទាំងប្រទេសដែរ ក្នុងសហករណ៍ភ្នំធិប្បតេយ្យ ស្រុកគាស់ក្រឡ តំបន់១ ខេត្តបាត់ដំបង ភូមិភាគពាយព្យទិស ។

## សកម្មភាពការងារទូទៅ
## លើវិស័យវប្បធម៌ និង សិល្បៈទស្សនីយភាព

## ការងារលោក ចិន្ត នាគ ក្នុងនាមជាសិល្បករសម្តែង

មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ តម្រូវអោយនិស្សិតឆ្នាំទី ៣ ទី ៤ មុនប្រឡងឌីប្លូមចុះធ្វើសកម្មភាពបម្រើមហាជនទូទាំងប្រទេសរៀងរាល់ឆ្នាំ ចាប់ពីដើមខែមករា រហូតដល់ចុងខែមេសា ឬដើមខែឧសភា ទើបបញ្ចប់សកម្មភាព "ទូរណេ" ព្រោះដើម្បី មានសិល្បៈល្ខោនបានលុះត្រាណាតែមានសម្តែងនៅចំពោះមុខទស្សនិកជនផ្ទាល់ ផ្ទាំងទស្សនីយភាពនីមួយៗត្រូវឆ្លងកាត់ទស្សនិកជនពី ១ម៉ឺន ទៅ ២ម៉ឺននាក់ក្នុងមួយយប់ សំដែងកណ្តាលវាល បើនៅតាមរោង ពី ៦០០ ទៅ ៨០០ ទៅ ១,០០០នាក់ មួយថ្ងៃមួយយប់ ជួនកាលសំដែងបីពេល (លក់សំបុត្រ) ជុំវិញទន្លេសាប ភូមិភាគព្រៀសាន ផ្លូវជាតិលេខ១ ផ្លូវជាតិលេខ២ ផ្លូវជាតិលេខ៣ ផ្លូវជាតិលេខ៤ (ចុះសំដែងរៀងតាមផ្លូវ តាមស្រុក ជួរតាមមាត់ទន្លេធំ តាមខេត្តគោរពផែនការដែលបានកំណត់ច្បាស់លាស់) ក្នុងមួយក្រុមហាត់២រឿងដើម្បីសំដែងបាន២យប់ក្នុងមួយកន្លែង។

-លោក ចិន្ត នាគ បានចូលរួមសម្តែង :

-ឆ្នាំ ១៩៦៤-១៩៦៥ តួតុលាការក្រុងឡាអេរឿងអបអរសាទរឈ្នះក្តីព្រះវិហារ

-ឆ្នាំ ១៩៦៤-១៩៦៦ តួព្រះវេស្សន្តរ ក្នុងរឿងព្រះនាងមទ្រី និងតួអ្នកស្រុកសុវណ្ណភូមិ (អ្នកស្រុកដើម) រឿងដំណើរជាតិខ្មែរ ។

-ឆ្នាំ ១៩៦៦-១៩៦៧ តួលីហ្សាន់ជីក្នុងរឿងរាត្រីនិមិត្តនាវស្សាន្តរដូវ (មួយកន្លែងលេង ២យប់) ។

-ឆ្នាំ ១៩៦៧-១៩៦៨ តួក្លីតង់ក្នុងរឿងស្វាមីចាញ់កល (សិកដង់ដាំង)

-ឆ្នាំ ១៩៦៨-១៩៦៩ តួឯកប្រុសក្នុងរឿងចិញ្ចៀនចញ្ចាំចិត្ត (រឿងនេះ tourner ជាមួយរឿងឡឺស៊ីដ) ។

-ឆ្នាំ ១៩៦៩-១៩៧០ តួរ៉ូមេអូ ក្នុងរឿង រ៉ូមេអូ និងហ្ស៊ុលីយ៉ែត ហាត់តួពីរជាមួយតួលោក អាំង គឹមស៊ិន (នៅប្រទេសបារាំង) ។

-ឆ្នាំ ១៩៧០-១៩៧១ តួព្រះបាទព្រហ្មទត្ត ក្នុងរឿង "រឿងព្រេងដ៏អស្ចារ្យ"

-ឆ្នាំ ១៩៧១-១៩៧២ តួព្រះពុទ្ធវគ្គរាគី, រាគា, តណ្ហា (រឿងពុទ្ធប្រវត្តិ) សម្តែងនៅភ្នំពេញ និងថតផ្សាយតាមទូរទស្សន៍

-ឆ្នាំ ១៩៧៤ តួឆន្នមាត្យ សម្តែងលើឆាកមហោស្រពទន្លេបាសាក់ (រឿងពុទ្ធប្រវត្តិ) ព្រមទាំងថតផ្សាយតាមទូរទស្សន៍ ។

-តួមហាតេជោ ក្នុងរឿងមេទ័ពភក្តី (ថតទូរទស្សន៍)

-តួនាយសូត្រ ក្នុងរឿងលោហិតតែមួយ (ទូរទស្សន៍) ទទួលជោគជ័យខ្លាំង

-សម្តែងក្នុងរឿង ឡវ៉ែត ឬ ត្រាក្រហម (ល្ខោនវិទ្យុ)

-តួព្រលឹងថ្ម ក្នុងរឿងប្រាង្គសិលា កញ្ញាអង្គរ (ទស្សនីយភាពលើឆាក)

-សម្តែងក្នុងរឿងស្គរធំ (ទស្សនីយភាពលើឆាក)

-សម្តែងក្នុងរឿង ជួងនៅព្រះវិហារដូរសូស៊ី (លើឆាក)

-សម្តែងក្នុងរឿង ស្នឹងកំចាយមារ (លើឆាក)

-សម្តែងក្នុងរឿង អ្នកស្រីដែលមានកូនឆ្កែ (លើឆាក)

-សម្តែងក្នុងរឿង ជ័យវរ្ម័នទី៧ (សម្តែងនៅស្តាតអូឡាំពិច មុនព្រឹត្តិការណ៍ ១៩៧០) ឆ្នាំ ១៩៧៥ បែកភ្នំពេញ ។

-ឆ្នាំ ១៩៨០ ផ្លាយបានចូលរួមសម្តែងថតខ្សែភាពយន្តជាមួយលោក ម៉េង អនិកជនមកពីសហរដ្ឋអាមេរិក ។

-ឆ្នាំ ១៩៩០ ផ្លាយបានរួមសម្តែងថតវីដេអូជាមួយលោក អ៊ី វ៉ង់ហែម ជាតួមេធាវីសម័យអ៊ីនតាក់ ។

-ឆ្នាំ ២០០៣ បានចូលរួមសម្តែងថតជាខ្សែវីដេអូ រឿងរំដួលអង្គរ ឬស្នេហ៍ឆ្លងដែនជាមួយលោក អ៊ី វ៉ង់ហែម ក្នុងតួលោកឧកញ៉ា សម្បត្តិឪពុករបស់តួឯក ។

-ក្នុងភាពយន្តសម្តេចឪ បានចូលរួមសម្តែងថតក្នុងខ្សែភាពយន្តមួយរឿង ដែលថតនៅលើប្រាសាទ ច័ន្ទ ឆាយា កាលនោះមានរន្ទះបាញ់បាក់កំពូលដូងនៅមាត់ទន្លេចំច្រកទ្វារប្រាសាទ ច័ន្ទ ឆាយា ។

## សកម្មភាពការងារក្នុងវិស័យរដ្ឋបាលវប្បធម៌ និង សិល្បៈក្រោយថ្ងៃ ៧មករា ១៩៧៩

-ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៧៩ ទីប្រឹក្សាសិល្បៈមន្ទីរវប្បធម៌ និងព័ត៌មានខេត្តបាត់ដំបង ។

-ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៧៩ គណៈកម្មការអាជីវកម្ម ក្រុមសិល្បៈសាធារណរដ្ឋប្រជាមានិតកម្ពុជា និងជាសមាជិកក្រុមល្ខោននិយាយសាលមហោស្រពទន្លេបាសាក់ ភ្នំពេញ ។

-ឆ្នាំ ១៩៨០ ស្ថាបនិកប្រធានសាលា (ល្ខោន របាំ សៀក) សាលាវិចិត្រសិល្បៈក្រសួងវប្បធម៌ និងជាសាស្ត្រាចារ្យ ឧទ្ទេសនាមទ្រឹស្តីល្ខោនជូនសាលាមុខជំនាញវប្បធម៌ និងព័ត៌មាន ចំនួន ១០វគ្គ ។

-ឆ្នាំ ១៩៨៥ ជំនាញការសិល្បៈល្ខោន ក្រសួងវប្បធម៌សាធារណរដ្ឋប្រជាធិប្បតេយ្យមានិតឡាវទីក្រុងវៀងច័ន្ទ ។

-ឆ្នាំ ១៩៨៧ ស្ថាបនិក សាកលវិទ្យាល័យវិចិត្រសិល្បៈ ក្រុមប្រឹក្សាកម្មវិធីសិក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រៀមបង្កើតថ្នាក់ឧត្តមសិល្បៈនាដសាស្ត្រ ។

-ឆ្នាំ ១៩៨៩ អនុប្រធានការិយាល័យស្រាវជ្រាវសិល្បៈល្ខោន នៅនាយកដ្ឋានសិល្បៈទស្សនីយភាពភ្នំពេញ ។

-ឆ្នាំ ១៩៩២ ប្រធានការិយាល័យនាទីវប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈភ្នំពេញ ។

-ឆ្នាំ ១៩៩៦ ប្រធាននាយកដ្ឋានរងទទួលបន្ទុកល្ខោនគ្រប់ទម្រង់ទូទាំងប្រទេសនាយកដ្ឋានសិល្បៈទស្សនីយភាពភ្នំពេញ ។

## ការងារបណ្តុះបណ្តាលបំប៉នបន្ថែម

-លោក ចិន្ត នាគ តែងបានថ្នាក់ដឹកនាំក្រសួងវប្បធម៌ យកចិត្តទុកដាក់បំពាក់បំប៉នចំណេះដឹងផ្នែកជំនាញល្ខោនជារឿយៗមានរយៈពេលវែង ។

-ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៨០ បំប៉នឯកទេសដឹកនាំរឿង និងលម្អឆាកក្រសួងវប្បធម៌ និងព័ត៌មានភ្នំពេញ ។

-ឆ្នាំ ១៩៨០-១៩៨២ គរុនិស្សិតវគ្គទី ១៣ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិត្យការក្រសួងអប់រំ និងប្រកាស ជាសាស្ត្រាចារ្យសិល្បៈល្ខោន ។

-ឆ្នាំ ១៩៨១ ទស្សនកិច្ចសិក្សា សាលាល្ខោនទី២ ទីក្រុងព្រៃនគរប្រទេសវៀតណាម ។

-ឆ្នាំ ១៩៨១ ទស្សនកិច្ចសិក្សា ៥រដ្ឋ របស់សហភាពសូវៀត ។

-ឆ្នាំ ១៩៨៧ បណ្តុះបណ្តាលជំនាញល្ខោន និងជាអ្នកគ្រប់គ្រងក្រុមល្ខោនវិទ្យាស្ថានល្ខោនសហភាពសូវៀត ទីក្រុងមូស្គូ ។

-ឆ្នាំ ១៩៨៩ ទស្សនកិច្ចតំណាងអ្នកនិពន្ធរឿងល្ខោន រដ្ឋលីទុកអានីសហភាពសូវៀត ។

-ឆ្នាំ ១៩៩៥ បណ្តុះបណ្តាលជំនាញល្ខោនថ្នាក់បណ្ឌិត **SEAMEO, SPAFA** ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។

## ការងារនិពន្ធ ដឹកនាំរឿង និង រៀបរៀងរឿងល្ខោន

-លោក ចិន្ត នាគ បាននិពន្ធដឹកនាំរឿង និងរៀបរៀងពាក្យពេចន៍រឿងចាស់ដែលមានមកហើយ អោយទៅជារឿងល្ខោនសម្រាប់សំដែងលើឆាកដោយបាននិពន្ធ និងដឹកនាំរឿងផ្ទាល់មាន ។

-ឆ្នាំ ១៩៧៤ និពន្ធរឿង រំដួលបន្ទាយស្រី ប្រឡងជាប់ចំណាត់ថ្នាក់លេខ២ ដោយគ្មាន លេខ ១ ទទួលប្រាក់រង្វាន់ ២លានរៀល (សម័យសាធារណរដ្ឋខ្មែរ) និងមានថតផ្សាយតាមទូរទស្សន៍ជាតិសំដែងនៅ សាលមហោស្រពទន្លេបាសាក់ និង

នៅសាលចតុម្មុខ ។

-ឆ្នាំ ១៩៧៩ និពន្ធរឿងព្រលឹងជោគជ័យ ឬគុកឥតជញ្ជាំង "សម្តែងដោយក្រុមសិល្បៈមន្ទីរឃោសនាការខេត្តបាត់ដំបង និងមានសំដែងដោយក្រុមសិល្បៈមន្ទីរវប្បធម៌ខេត្តកំពង់ស្ពឺ (ល្ខោននិយាយ ) ។

-ឆ្នាំ ១៩៨០ និពន្ធរឿង ខ្លែងខ្មៅគួរខ្លាច សំដែងដោយសិស្សសាលាល្ខោនជំនាន់ទី ១ នៅស្តាតអូឡាំពិក (ល្ខោននិយាយ) ។

-ឆ្នាំ ១៩៨១ និពន្ធរឿង ដំណើរទៅមុខជានិច្ចសំដែងដោយសិស្សសាលាល្ខោនជំនាន់ទី១ និងទី២ នៅសាលមហោស្រពទន្លេបាសាក់ (ល្ខោននិយាយ) ។

-ឆ្នាំ ១៩៨២ និពន្ធរឿង សុវណ្ណភូមិដីកេរ ឬដំណើរជាតិខ្មែរសំដែងដោយសិស្សសាលាល្ខោនជំនាន់ទី១ និងទី២ នៅសាលមហោស្រពចតុម្មុខ (ល្ខោននិយាយ) ។

-ឆ្នាំ ១៩៨៣ និពន្ធរឿង ស្នេហាបរិសុទ្ធ ឬមេឃក្រហមសំដែងដោយសិស្សសាលាល្ខោនជំនាន់ទិ១ និងទី២ ដឹកនាំរឿងដោយលោកខ្លូតរតនាសំដែងនៅសាលសហសិក្សា ល្ខោនក្នុងសាលាវិចិត្រសិល្បៈខាងជើង (ល្ខោននិយាយ) ។

-ឆ្នាំ ១៩៨៤ និពន្ធរឿងកុលាបមករា សម្តែងដោយសិល្បករមន្ទីរវប្បធម៌ខេត្តព្រៃវែង នៅសាលសហសិក្សាគរុកោសល្យខេត្ត (ល្ខោននិយាយ) ។

-ឆ្នាំ ១៩៨៦ រៀបរៀងរឿង ស្វាម៉ីចាញ់កល ឬសឹកដង់ដាំងជារឿងទម្រង់ល្ខោននិយាយទៅជាទម្រង់អាយ៉ៃរឿងសំដែងដោយក្រុមអាយ៉ៃនាយកដ្ឋានសិល្បៈទស្សនីយភាព សំដែងនៅសាលមហោស្រពទន្លេបាសាក់ និងរោងភាពយន្តលុច្ស ។

-ឆ្នាំ ១៩៨៧ រៀបរៀងរឿង ព្រះនាងមទ្រីបំពេញបន្ថែមទៅជារឿងមហាវេស្សន្តរជាតក ដូរទស្សនាទានពីភក្តីភាពរបស់ព្រះនាងមទ្រី ទៅជាទស្សនាទាន ទានបារមីរបស់ព្រះវេស្សន្តររៀបរៀងបញ្ចូលបាន ១២ កណ្ឌក្នុងជាតកទានបារមី រឿងព្រះវេស្សន្តរទាំង ១៣ កណ្ឌ (ដោយឥតមានសំដែងកណ្ឌទសពរ) ។ សំដែងនៅសាលមហោស្រពទន្លេបាសាក់ និងទៅសំដែងតាមបណ្តាខេត្តមួយចំនួន ។ សម្តែងដោយសិល្បកររបាំប្រពៃណីនាយកដ្ឋានសិល្បៈទស្សនីយភាព (ល្ខោននិយាយ) ។

-ឆ្នាំ ១៩៨៤ រៀបរៀងរឿងសព្វសិទ្ធជាទម្រង់ល្ខោនបាសាក់ សំដែងដោយសិល្បករ ខណ្ឌ ៧មករា នៅរោងភាពយន្តខេមរៈ ។

-ឆ្នាំ ១៩៨៤ រៀបរៀងរឿង ព្រះចន្ទ័គោរព ជាទម្រង់ល្ខោនបាសាក់ សំដែងដោយសិល្បករ ខណ្ឌ ៧ មករា នៅរោងភាពយន្តខេមរៈ ។

-ឆ្នាំ ១៩៨៨ និពន្ធរឿង ដាវអាថ្មាសឹក ឬវន្ទះដាវស្នេហ៍ជាទម្រង់ល្ខោនបាសាក់សំដែងដោយសិល្បករសង្កាត់បឹងព្រលិតសំដែងនៅរោងកុលាបកុមារកំព្រា ឬរោងភាពយន្តគីរីរម្យ និងរោងភាពយន្តភ្នំពេញ ។

-ឆ្នាំ ១៩៨៩ រៀបរៀងរឿង ចិញ្ចៀនបញ្ចាំចិត្តទៅជា **scenario** ថតវីដេអូឱ្យផលិតកម្មរស្មីកម្ពុជា ។

-ឆ្នាំ ១៩៩៣ រឿង ព្រះវេស្សន្តរ ត្រូវថតជាកាសែតសំឡេង និងថតជាកាសែតល្ខោនវីដេអូលើឆាកសំដែងដោយសិល្បករនាយកដ្ឋានសិល្បៈទស្សនីយភាព រ៉ាប់រងការថត និងដំឡើងដោយនាយកដ្ឋានភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ដែលផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា ។

-ឆ្នាំ ១៩៩៤-១៩៩៨ រៀបរៀងរឿង ជ័យសែន ជាទម្រង់ល្ខោនពោលស្រីសំដែងដោយក្រុម សិល្បការិនីសហគមន៍វត្តកៀនស្វាយក្រៅ សំដែងនៅខេត្តកណ្ដាល ភ្នំពេញ និងខេត្តសៀមរាប ចូលរួមឆ្លងសហស្សវត្សរ៍ (២០០០-២០០១) នៅលើវេទិកាឆាក មុខប្រាសាទអង្គរ ។

-ឆ្នាំ ១៩៩៩ និពន្ធរឿង សំណោកនាងប្រាង្គសិលា ជាមួយលោកពីនន់ដឹកនាំរឿងដោយលោក ចិន្ត នាគ សំដែងដោយនិស្សិតឧត្តមនាដសាស្ត្រនៅសាលចតុម្មុខ ។

-ឆ្នាំ ២០០១ និពន្ធសៀវភៅល្ខោនពោលស្រីចប់ត្រៀមបោះពុម្ពផ្សព្វផ្សាយក្នុងឆាកជាតិ និងអន្តរជាតិ (ខ្វះធនធាន) ។

-ឆ្នាំ ២០០២ រៀបរៀងរឿងមហាភារតយុទ្ធជាទម្រង់ល្ខោនកំណាព្យសំដែងជាផ្ទាំងទស្សនីយភាពដោយសិល្បករក្លឹមសិល្បៈឯកជន **MSL** សំដែងនៅរោងមហោស្រពចតុម្មុខ ។

-ឆ្នាំ ២០០២ និពន្ធប្រវត្តិល្ខោនខ្មែរ សម្រាប់បង្រៀននៅថ្នាក់ឧត្តមសម្រួលអត្ថបទសិល្បៈអាយ៉ៃឡើងវិញត្រៀមបោះពុម្ពប្រវត្តិសិល្បៈអាយ៉ៃស្រាវជ្រាវរកឃើញដោយលោក ចិន្ត នាគ ប៉ុន្តែគ្មានធនធានគ្រប់គ្រាន់ ។

-កែសម្រួលវិធីសាស្ត្របង្រៀនបច្ចេកទេសសិល្បៈល្ខោននាដកម្មដែលនិពន្ធតាំងពីឆ្នាំ ១៩៨០ និងដកពិសោធន៍សារចុះសារឡើងរយៈពេល ២៥ឆ្នាំ ត្រៀមបោះពុម្ព (គ្មានធនធាន) ។

-ឆ្នាំ ២០០២ ដឹកនាំរឿងល្ខោនសម្រាប់កុមារកេប១កូនល្អជាទម្រង់ល្ខោនប្រាមោទ្យទ័យនិពន្ធដោយអ្នកគ្រូ កែវ ណារុំ សំដែងដោយសិស្សសាលាជួតន្ត្រីផ្នែកចម្រៀងបុរាណនៅសាលចតុម្មុខ និងរោងមហោស្រពសាលកវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

-ការងារមហោស្រពដំឡើងទស្សនីយភាពធំៗ នៅលើវេទិកាមុខប្រាសាទអង្គរខេត្តសៀមរាប និងការងារដំឡើងទស្សនីយភាពធំៗ នៅភ្នំពេញល្ខោនចម្រុះរឿងដំណើរជាតិខ្មែរ លោហិតជាតិខ្មែរ និង ជីវិតជាតិខ្មែរ លោក ចិន្ត នាគ តែងតែជាដៃគូដ៏សំខាន់មួយរូបជាសហការីជំនួយការជំនាញរបស់ឯកឧត្តម ពេជ្រ ទុំក្រវិល គឺតាំងពីឯកឧត្តមស្ថិតក្នុងឋានៈជាប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាពម្ល៉េះ ។

## ការងារផលិតកាសែតវីដេអូ ស៊ីឌី និង ឌីវីឌី

-ក្នុងនាមជាចាងហ្វាងផលិតកម្មនាគរាជនៅកម្ពុជា លោក ចិន្ត នាគ បានសហការណ៍ជាមួយផលិតកម្មនៅសហរដ្ឋអាមេរិកដូចជាផលិតកម្មរស្មីកម្ពុជា ផលិតកម្មឥន្ទធនូ ផលិតកម្មអង្គរជ័យ ផលិតកម្មរស្មីពានមាស ផលិតកម្ម **Top laiser** ផលិតកម្មរបស់លោក ព្រាហ្ម សាន និងផលិតកម្មសាយណ្ណារា ។ ចាប់តាំងពីឆ្នាំ ១៩៨៩ មកផលិតកាសែតសំឡេងកាសែតរូបភាព **disque** សំឡេងរូបភាព **disque laiser, VCD DVD** កសាងវណ្ណកម្មបានពី ៨០០ ទៅ ១០០០ បទ (ទាំងរូបភាពទាំងសំឡេង) ក្នុងមួយវ៉ុលមាន ២៤ បទ និង ធ្លាប់ផលិតអោយផលិតកម្មក្នុងស្រុកដូចជាហង្សមាស និង រស្មីហង្សមាសបានចំនួន ១៨បទ (ធ្វើរូបភាព) ។

## បេសកកម្មក្នុងស្រុក និងបរទេស

-លោក ចិន្ត នាគ កាលមុនឆ្នាំ ១៩៧៥ ជាសិល្បករសំដែងចុះបំពេញបេសកកម្មតាមគ្រប់ខេត្ត ក្រុង ទូទាំងកម្ពុជាលើកលែងតែខេត្តពីររតនៈគីរី មណ្ឌលគីរី ភូមិភាគឦសានប្រទេសដែលក្រុមសិល្បៈទៅមិនដល់ជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ ១៩៦៥-១៩៦៦ មកប្តូរជុំ ប្តូរក្រុមចុះតាម ស្រុក តាមខេត្តជានិច្ច ។

-ក្រោយឆ្នាំ ១៩៧៩ បេសកកម្មក្នុងនាមជាអ្នកដឹកនាំក្រុមសិស្សសាលាល្ខោន នៅសាលាវិចិត្រសិល្បៈដឹកនាំក្រុមល្ខោនរបស់នាយកដ្ឋានសិល្បៈទស្សនីយភាពចុះទៅសំដែងតាមការអញ្ជើញរបស់ប្រជាជនតាមស្រុក តាមខេត្តនានា ។

-ឆ្នាំ ២០០៣ ខែវិច្ឆិការ ជាប្រធានគណៈប្រតិភូដឹកនាំក្រុមសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា ទៅចូលរួមសំដែងនៅទីក្រុងហាណូយ ទីក្រុងហូជីមិញ ប្រទេសវៀតណាម ក្នុងថ្ងៃបុណ្យគម្រប់ខួបទី ៥០ បុណ្យឯករាជ្យជាតិ និងខួប៥០ថ្ងៃកំណើតកងខេមរភូមិន្ទកងទព័ជើងទឹក ។

-ឆ្នាំ ២០០៤ ខែតុលា ដឹកនាំក្រុមសិល្បៈរបស់ក្រសួងវប្បធម៌ទៅប្រទេសចិន ចូលរួមបុណ្យខួបលើកទី១០ (ប្រទេសទាំង៦ជាប់ដងទន្លេមេគង្គ) ។

-ឆ្នាំ ២០០៥ ខែសីហា ចូលរួមជាគណៈប្រតិភូបុរាណវិទ្យានៅប្រទេសថៃក្នុងនាមជាអ្នកនិពន្ធរឿងល្ខោន ។

## ស្ថានភាពគ្រួសារបច្ចុប្បន្ន

លោក ចិន្ត នាគ បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង ខេន សាឯម នៅភូមិបឹងទឹង ឃុំទងត្រឡាច ស្រុកស្រីសន្ធរខេត្តកំពង់ចាម ដោយបានបុត្រី៣រូប បុត្រា១រូប

១ នាគ សោម៉ាវត្តី ៣០-០៥-២០០១

២ នាគ សោម៉ាពីសី ១១-០៥-២០០២

៣ នាគ សោម៉ារស្មី ១០-០៨-២០០៣

៤ នាគ ចិន្តកវី ១៣-១២-២០០៤

សព្វថ្ងៃស្នាក់នៅផ្ទះលេខ ២៤ សង្កាត់ ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ។

## អំពីមេដាយ និង ប័ណ្ណសរសើរ

-លោក ចិន្ត នាគ បានទទួលប័ណ្ណសរសើរ លិខិតសរសើរ ជាបន្តបន្ទាប់ពីថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

-បានទទួលការលើកសរសើរផ្នែកនិពន្ធរឿងល្ខោន លោក ចិន្ត នាគ ជាអ្នកនិពន្ធ ល្ខោននិយាយដែលបានទទួលប័ណ្ណសរសើរពីសម្តេច ជា ស៊ីម ប្រធានរដ្ឋសភាជាតិ (សព្វថ្ងៃលោកជាប្រធានព្រឹទ្ធសភា) ។

-លោក ចិន្ត នាគ បានទទួលគ្រឿងឥស្សរិយយស មេដាយប្រាក់ពីរាជរដ្ឋាភិបាលក្នុងគុណបំណាច់អ្នកធ្វើការងារល្អរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

-បានទទួលគ្រឿងឥស្សរិយយស មេដាយមាស ពីរាជរដ្ឋាភិបាល ក្នុងគុណបំណាច់អ្នកធ្វើការងារល្អរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនាឱកាសថ្ងៃប្រារព្ធទិវាវប្បធម៌ជាតិ លើកទី៦ ០៣ មេសា ២០០៤ ។

ខ្ញុំ ចិន្ត នាគ សូមអះអាងបញ្ជាក់ថា ការសរសេរប្រវត្តិរូបនេះពិតជាត្រឹមត្រូវ ហើយសូមទទួលខុសត្រូវខ្ពស់បំផុត បើមានចំណុចណាមួយប្រាសចាកពីការពិត ។

រាជធានីភ្នំពេញ. ថ្ងៃទី...... ខែ.......ឆ្នាំ ២០០៤

ហត្ថលេខា

**ចិន្ត នាគ**



លោក ចិន្ត នាគ

- សាស្ត្រាចារ្យសិល្បៈ (ផ្នែកល្ខោននិយាយ) ។
- អនុប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព (នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។
- កើត ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៤៦ ។
- នៅភូមិកុងស៊ី ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។
- ជាកូន លោក ចិន្ត ឡូន (ស) អ្នកម្ដាយ ថាន សុខហ៊ី (ស) ។

ISBN 99950-150-0-1

បោះពុម្ពលើកទី១
ដោយរោងពុម្ព